# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# យន្តការការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឯម លក្ខិណា**

**ឯក ប៉ាន់ហ្រេក្កកម៉ី**

សាស្ត្រាចារ្យណែនាំ

**លោក៖ នី វិចិត្រ**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឯម លក្ខិណា** ព្រមទាំងនាងខ្ញុំឈ្មោះ **ឯក ប៉ាន់ប្រេីណ្ដកមុី** ជានិស្សិតសិក្សានៅផ្នែកនីតិសាស្ត្រជំនាន់ទី២០ ក្រុម L4A6 នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលកំពុងតែធ្វើការស្រាវជ្រាវសរសេរសារណាថ្នាក់បរិញ្ញាប័ត្រ នៅក្នុងបំណងដើម្បីបញ្ចាប់ការសិក្សា ក្រោមប្រធានបទស្ដីពី **យន្តការការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងកិច្ចសន្យា**

នាងខ្ញុំសុំថ្លែងអំណរគុណ និងសម្ដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ៖

- លោកឪពុក **ឯក ប៉ាន់ជន** ព្រមទាំងអ្នកម្ដាយ **ទ្រី ឌួចនាង**
- លោកឪពុក **ឯម ញ៉** ព្រមទាំងអ្នកម្ដាយ **ស្រ៊ុន ចាន់ធឿន**

ដែលជាអ្នកមានគុណដល់ធំធេងចំពោះ រូបកូនដែលមិនអាចមានអ្វីមកកាត់ថ្លៃបានដោយលោកឪពុកនិងអ្នកម្ដាយបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនប្រកបដោយព្រហ្មវិហារធម៌ទាំង ៤។ លោកឪពុកនិងអ្នកម្ដាយបានធ្វើការទំនុកបំរុង គ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ថវិការ ស្មារតី សេចក្ដីស្រឡាញ់ និងបានផ្ដល់នូវដំបូន្មានល្អៗ និងផ្ដល់ឱកាស ព្រមទាំងជំរុញទឹកចិត្តរូបកូនឱ្យខិតខំសិក្សារៀនសូត្ររហូតឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាប័ត្រនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំក៏សូមអរគុណដល់បងប្អូនបង្កើតដែលតែងតែស្រឡាញ់ ណែនាំ និងជាកម្លាំងចិត្តដល់រូបយើងខ្ញុំរហូតមក។

- ឯកឧត្តម សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក និងលោកស្រីសាស្ត្រាចារ្យ និង បុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា និងបណ្ណារក្ស នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំអស់ពីកម្លាំងចិត្តកម្លាំងកាយ ដែលបានដឹកនាំ ជួយជ្រោងជ្រែង និង បង្ហាត់បង្រៀនផ្ទេរនូវចំណេះដឹងល្អៗ គ្រប់ផ្នែកយ៉ាងច្រើន ព្រមទាំងបទពិសោធន៍នៃជីវិតនៅក្នុងសង្គមដល់រូបយើងខ្ញុំផងដែរ។
- លោកសាស្ត្រាចារ្យ **នី វិចិត្រ** ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំ ព្រមទាំងចំណាយពេលដល់មានតម្លៃរបស់លោកមកណែនាំ ផ្ដល់យោបល់ បង្ហាត់បង្ហាញ ជំរុញលើកទឹកចិត្តពួកខ្ញុំ ក្នុងការស្រាវជ្រាវទៅលើអត្ថបទនេះ លោកក៏បានជួយណែនាំ កែសម្រួល និងជួយជាគំនិត និងឯកសារពាក់ព័ន្ធដល់រូបយើងខ្ញុំ។
- មិត្តភក្តិទាំងអស់ដែលតែងតែជួយណែនាំ និងលើកទឹកចិត្ត និងព្រួយបារម្ភចំពោះយើងខ្ញុំ។

ជាចុងក្រោយយើងខ្ញុំសូមជូនពរដល់លោកឪពុកនិងអ្នកម្ដាយទាំងបួននាក់ លោកសាកលវិទ្យាធិការសកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកការិយាល័យទាំងអស់ លោកសាស្ត្រាចារ្យនី វិចិត្រ ឱ្យជួបតែសម្បត្តិ ៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ។

# អនុមោទនា

ក្នុងរយៈពេលនៃការសិក្សារបស់យើងខ្ញុំ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលបួនឆ្នាំមកនេះ យើងខ្ញុំទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើន។ ដោយក្នុងអំឡុងពេលនៃការសិក្សានេះផងដែរ យើងខ្ញុំសម្លឹងឃើញនូវចំណុចខ្វះខាតមួយចំនួនទៅលើទ្រឹស្តី ព្រមទាំងការអនុវត្តន៍ទៅលើវិស័យកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជាយើង ដើម្បីឱ្យការសិក្សាកាន់តែមានភាពជោគជ័យ និងឈានទៅមុខកាន់តែប្រសើរ និងជាការបញ្ចប់ជាស្ថាពរនៃការសិក្សាកម្រិតបរិញ្ញាប័ត្រសារណានេះ យើងខ្ញុំសរសេរឡើងក្នុងគោលបំណងឆ្លុះបញ្ចាំងទៅលើការសិក្សាដែលយើងខ្ញុំទទួលបានកន្លងមក ដែលជាការប្រៀបធៀបរវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងជាការសរសេរសារណាសម្រាប់បញ្ចប់ការសិក្សាដែលយើងខ្ញុំបានសិក្សាអស់ជិតរយៈពេល ៤ឆ្នាំមកនេះ។ ដោយនៅក្នុងរយៈពេលនៃការសិក្សាកន្លងមក យើងខ្ញុំបានសង្កេតឃើញថា និស្សិតមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើនីតិកម្មសិទ្ធិបញ្ញា ព្រោះជានីតិដែលកំពុងមានការអភិវឌ្ឍនៅក្នុងវិស័យច្បាប់ ព្រមទាំងមានការរីកចំរើនយ៉ាងខ្លាំងក្នុងការអនុវត្តនៅក្នុងសង្គមបច្ចុប្បន្ន ហេតុនេះមាននិស្សិតជាច្រើនយកចិត្តទុកដាក់ និងចង់ស្រាវជ្រាវបន្ថែម ដោយឡែកឯកសារនៅក្នុងបណ្ណាល័យ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដែលទាក់ទង នឹងវិស័យកម្មសិទ្ធិបញ្ញានេះ គឺនៅមានកម្រិត ដែលមិនអាចផ្គត់ផ្គង់ទៅតាមតម្រូវការ របស់និស្សិត។ ជាពិសេសយើងខ្ញុំបានសង្កេតឃើញពីសារៈសំខាន់នៃវិស័យកម្មសិទ្ធិបញ្ញា នៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសំខាន់សម្រាប់បញ្ហាដែលសង្គមយើងកំពុងប្រឈមនាពេលបច្ចុប្បន្ន ហើយចាំបាច់ក្នុងគោលបំណងចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិនេះ យើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ ដែលទាក់ទងទៅនិង វិស័យកម្មសិទ្ធិបញ្ញានេះដែលមានចំណងជើងថា **យន្តការការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងកិច្ចសន្យា** មកធ្វើការស្រាវជ្រាវ។ យ៉ាងណាមិញប្រធានបទមួយនេះជាប្រធានបទថ្មីដែលពុំទាន់មាននិស្សិត ធ្លាប់ធ្វើការស្រាវជ្រាវទៅលើប្រធានបទនេះពីមុនមកទេ តែយើងខ្ញុំមើលឃើញពីភាពចាំបាច់នៃប្រធានបទនេះ ព្រោះពុំទាន់មានការតាក់តែងជាប្បញ្ញាត្តិណាមួយកំណត់ពី ការការពារការសម្ងាត់ពាណិជ្ជកម្មនេះឡើង ប៉ុន្តែវាជាការចាំបាច់ក្នុងការប្រើប្រាស់លើវិស័យពាណិជ្ជកម្មយើងប្រចាំថ្ងៃ ហើយខ្ញុំសង្ឃឹមថា និង មាននិស្សិតជំនាន់ក្រោយលើកយកប្រធានបទនេះមកធ្វើការស្រាវជ្រាវបន្ថែម រែកញែកទៅលើបញ្ហាផ្សេងៗ។ បើទោះជាយើងខ្ញុំប្រឹងប្រែងក្នុងសរសេរសារណានេះឱ្យបានល្អប្រសើរយ៉ាងណាក្តី តែយើងខ្ញុំច្បាស់ថាសារណានេះនៅមានចំនុចខ្វះខាតជាច្រើនដែលត្រូវបំពេញ និងទាមទារការស្រាវជ្រាវបន្ថែមទៀត។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែសង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងអាចជួយជាចំណែកមួយក្នុងការចូលរួមជាគំនិតយោបល់ ដល់អ្នកដែលកំពុងសិក្សាទៅលើផ្នែកនេះ ក៏ដូចជានិស្សិតអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងធ្វើចង់សិក្សាស្វែងយល់ទៅលើផ្នែកនេះ ដើម្បីជាប្រយោជន៍ដល់ការងារ ឬ ការសិក្សាឱ្យមានភាពរីកចម្រើនដើម្បីជាការសម្រេចដល់ប្រសើរ។

យើងខ្ញុំសង្ឃឹមថាអត្ថបទដែលយើងខ្ញុំបានធ្វើការស្រាវជ្រាវនេះនិង ក្លាយជាផ្នែកមួយដែលជួយឱ្យមានការរីកចំរើនកាន់តែខ្លាំងទៅលើវិស័យនីតិកម្មសិទ្ធិបញ្ញា ហើយនិងអាចយកវិធានការនៃការស្រាវជ្រាវរបស់យើងខ្ញុំ យកទៅពង្រឹងការអនុវត្តនៅក្នុងវិស័យនេះឱ្យកាន់តែមានភាពរីកចម្រើន និងល្អប្រសើរ ហើយយើងខ្ញុំក៏សូមអរគុណចំពោះការកែលម្អរបស់មិត្តអ្នកអាន អ្នកសិក្សាគ្រប់ជំនាន់ទាំងអស់ដែលនិងចូលរួមជាគំនិតយោបល់ដែល និង ធ្វើឱ្យប្រធានបទនេះកាន់តែមានភាពច្បាស់លាស់ និងកាន់តែប្រសើរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................................................................ ១

**ជំពូកទី១៖ ការកំណត់ចរិតលក្ខណៈនៃការសម្ងាត់ពាណិជ្ជកម្ម**

**ផ្នែកទី១៖ ការកំណត់អត្ថសញ្ញាណនៃការសម្ងាត់ពាណិជ្ជកម្ម** ............................................. ៣

**កថាខណ្ឌ១៖ ការកំណត់និយមន័យ** ................................................................................... ៣

១.ច្បាប់អន្តរជាតិដែលទាក់ទងនឹងការសម្ងាត់ពាណិជ្ជកម្ម ...................................................... ៣

១.១.កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិនទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា (TRIPs) មាត្រា៣៩ ................................................................................................................... ៣

១.២ .កិច្ចព្រមព្រៀងពាណិកម្មដោយសេរីរបស់អាមេរិកខាងជើង NAFTA ............................... ៥

១.៣. សហភាពអឺរ៉ុប European Union .......................................................................... ៦

២. ច្បាប់ជាតិដែលពាក់ព័ន្ធនឹងការសម្ងាត់ពាណិជ្ជកម្ម ............................................................ ៧

២.១. ការសម្ងាត់ពាណិជ្ជកម្មក្នុងលក្ខខណ្ឌកិច្ចសន្យាការងារ ................................................ ៨

**កថាខណ្ឌ២ ៖ ការកំណត់ប្រភេទព័ត៌មានដែលចាត់ទុកថាជាការសម្ងាត់ពាណិជ្ជកម្ម** ៩

**ផ្នែកទី២ លក្ខខណ្ឌក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម** ................................................. ១០

**កថាខណ្ឌ១៖ លក្ខខណ្ឌគ្រឹះ** ...................................................................................... ១០

**កថាខណ្ឌ២ ៖ លក្ខខណ្ឌចុះបញ្ជី** ............................................................................... ១០

**ជំពូកទី២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងកិច្ចសន្យាការងារ**

**ផ្នែកទី១៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងកិច្ចសន្យាការងារ** ................................ ១១

**កថាខណ្ឌ១៖ ទំនាក់ទំនងនិយោជិត និងនិយោជកក្នុងការការសម្ងាត់ពាណិជ្ជកម្ម** .. ១១

**កថាខណ្ឌ២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងពេលអនុវត្តកិច្ចសន្យាការងារ.** ................................................................................................ ១៣

១.ការអប់រំនិយោជិតអំពីគោលការណ៍ការពារការសម្ងាត់ពាណិជ្ជកម្មនិងតាមដានការអនុវត្តរបស់និយោជិត ............ ១៣

២. ការអនុវត្តតាមគោលនយោបាយក្រុមហ៊ុន ............ ១៤

៣. ការកម្រិតសិទ្ធិនិយោជិតនៅក្នុងកិច្ចសន្យាការងារ ............ ១៥

៣.១. សិទ្ធិក្នុងបានការទទួលព័ត៌មាន ............ ១៥

៣.២. សិទ្ធិក្នុងការប្រើប្រាស់ឧបករណ៍ក្រុមហ៊ុន ............ ១៥

៣.៣. ការរក្សាការសម្ងាត់កុំព្យូទ័រ ............ ១៦

៤. ថេរវេលានៃការការពារការសម្ងាត់ពាណិជ្ជកម្ម. ............ ១៦

**ផ្នែកទី២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្រោយពេលបញ្ចប់កិច្ចសន្យាការងារ ............ ១៧**

**កថាខណ្ឌ១៖ ស្ថានភាពនៅពេលដែលទំនាក់ទំនងការងារបានបញ្ចប់ដោយស្របច្បាប់ ............ ១៧**

**កថាខណ្ឌ២៖ ការការពារព័ត៌មានសម្ងាត់និង ការសម្ងាត់ពាណិជ្ជកម្ម ............ ១៧**

១. អនុវត្តកិច្ចសន្យាមិនប្រកួតប្រជែង (Non-competition clause) ............ ១៨

១.១. កម្មវត្ថុ. ............ ១៨

១.២. ការការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់ ............ ១៩

ក.ការទំនាក់ទំនងអតិថិជន ............ ១៩

ខ.ព័ត៌មានសម្ងាត់ ............ ១៩

១.៣. ថេរវេលានៃកិច្ចព្រមព្រៀងមិនចូលរួមប្រកួតប្រជែង ............ ២០

១.៤. វិសាលភាពនៃកិច្ចព្រមព្រៀងមិនចូលរួមប្រកួតប្រជែង . ............ ២០

២.កិច្ចសន្យាដើម្បីប្រគល់ឯកសារនិង ប្រព័ន្ធផ្សព្វផ្សាយសម្ងាត់ ............ ២០

**ជំពូកទី៣៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងកិច្ចសន្យាពាណិជ្ជកម្ម**

**ផ្នែកទី១៖ យន្តការនៃការពារការសម្ងាត់ពាណិជ្ជកម្មមុនពេលបង្កើតកិច្ចសន្យាពាណិជ្ជកម្ម ............ ២២**

**កថាខណ្ឌ១៖ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់** NDA( Non-disclosure Agreement ) ......២៣
១.ការបង្កើតកិច្ចសន្យារក្សាព័ត៌មានសម្ងាត់(NDA)........................................................................ ២៤
១.១.លក្ខខណ្ឌគ្រឹះ ........................................................................................................ ២៤
ក.ការព្រមព្រៀង ................................................................................................... ២៤
ក.១. សំណើរ.......................................................................................................... ២៤
ក.២. ស្ទីការ.......................................................................................................... ២៥
ខ.ការព្រមព្រៀងដោយជៀសវាងវិការៈ .................................................................... ២៥
គ.ថេរវេលា.......................................................................................................... ២៧
២.ការអនុវត្តកិច្ចសន្យារក្សារព័ត៌មានសម្ងាត់ ....................................................................... ២៨
២.១.ករណីយកិច្ចនៃកិច្ចសន្យារក្សាព័ត៌មានសម្ងាត់ ........................................................ ២៨
២.២.អានុភាពនៃកិច្ចសន្យារក្សាព័ត៌មានសម្ងាត់............................................................ ២៨
**ផ្នែកទី២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្ម ក្នុងការអនុវត្តកិច្ចសន្យាពាណិជ្ជកម្ម** .... ៣០
**កថាខណ្ឌ១៖ កិច្ចសន្យារក្សាការសម្ងាត់** ( mutual nondisclosure agreement ) .............៣០
១.ព័ត៌មានសម្ងាត់............................................................................................................ ៣០
២.ថេរវេលា..................................................................................................................... ៣០
**កថាខណ្ឌ២៖ លក្ខខណ្ឌក្នុងការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម**.............................៣១
១.សិទ្ធិក្នុងការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម.................................................................. ៣១
២.កាតព្វកិច្ចក្នុងការប្រើប្រាស់សម្ងាត់ពាណិជ្ជកម្ម.................................................................៣២
**ផ្នែកទី៣៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្រោយបញ្ចប់កិច្ចសន្យាពាណិជ្ជកម្ម** ៣៣
**កថាខណ្ឌ១៖ កិច្ចព្រមព្រៀងមិនមានការប្រកួតប្រជែង**( NoncompeteAgreement ) .. ៣៣
១.កម្មវត្ថុ ....................................................................................................................... ៣៣
២.ការកំណត់ក្នុងកិច្ចព្រមព្រៀងមិនមានការប្រកួតប្រជែង...................................................... ៣៣
៣.អានុភាពនៃកិច្ចព្រមព្រៀងមិនមានការប្រកួតប្រជែង...........................................................៣៤

**សេចក្ដីសន្និដ្ឋាន**.....................................................................................................៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នីតិកម្មសិទ្ធិបញ្ញា ត្រូវបានគេចាត់ទុកថាជា អាវុធដ៏រឹងមាំក្នុងការនាំឱ្យមានការការពារម្ចាស់កម្មសិទ្ធិទៅតាមវិស័យនានា ជាពិសេសគឺវិស័យពាណិជ្ជកម្ម។ នីតិកម្មសិទ្ធិបញ្ញា គឺជាកត្តាលីករដែលបានជម្រុញឱ្យមានការសហការគ្នារវាងប្រទេសមួយទៅនឹងប្រទេសមួយទៀតឱ្យកាន់តែមានភាពរីកចម្រើន ដោយសារវាបានបង្កើតឱ្យមានសេចក្តីទុកចិត្ត និងសុវត្ថិភាពក្នុងការការពារផលប្រយោជន៍ដៃគូរពាណិជ្ជកម្ម ដោយកំណត់នូវភាពច្បាស់លាស់នូវការប្រើប្រាស់សិទ្ធិ និងដែនកំណត់ដែលអាចទាញបាននូវផលប្រយោជន៍ ដែលជាហេតុនាំឱ្យមានការវិនិយោគទុនកាន់តែច្រើន ជាពិសេសការវិនិយោគទុនមកពីក្រៅប្រទេស។ អាស្រ័យដោយកត្តានេះហើយ ទើបប្រព័ន្ធកម្មសិទ្ធិបញ្ញា បានដើរតួយ៉ាងសំខាន់ក្នុង ការអភិវឌ្ឍន៍ដល់ប្រទេសជាតិឱ្យកាន់តែមានភាពជឿនលឿន ដែលជាហេតុនាំឱ្យប្រទេសកម្ពុជាឈានដល់ការចូលរួមនូវ ការអនុវត្តទៅលើកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ។

សម្រាប់ប្រទេសកម្ពុជាវិញ កម្ពុជាបានក្លាយទៅជាសមាជិកនៃ អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ១៩៩៥ និងបានចូលជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីស នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៨។ លើសពីនេះទៅទៀតផងដែរ កម្ពុជាបានចូលរួមជាផ្លូវការនៅក្នុងកិច្ចព្រមព្រៀងអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញានៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩៩៩។[1] ការចូលរួមក្លាយខ្លួនជាសមាជិករបស់កិច្ចព្រមព្រៀងអន្តរជាតិនេះផងដែរ បានបង្ហាញឱ្យយើងឃើញថាកម្ពុជាកំពុងតែមានភាពអភិវឌ្ឍន៍ទៅមុខលើ វិស័យពាណិជ្ជកម្ម និងនាំឱ្យមានភាពរីកចម្រើនយ៉ាងខ្លាំងទៅលើវិស័យកម្មសិទ្ធិបញ្ញា។ បើយើងក្រឡេកទៅមើលវិស័យពាណិជ្ជកម្មវិញ ពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេសង្កេតឃើញថាមានភាពរីកដុះដាលយ៉ាងខ្លាំង ដែលកម្ពុជាគឺជាតំបន់សេដ្ឋកិច្ចដ៏វិសេសវិសាលមួយនៅក្នុងអាស៊ីសាគ្នេយ៍ផងដែរ។ អាស្រ័យហេតុនេះហើយ ទើបកម្ពុជាមានតម្រូវការយ៉ាងខ្លាំង ទៅលើកម្មសិទ្ធិបញ្ញា ដើម្បីការពារនូវកម្មសិទ្ធិផ្សេងៗរបស់ម្ចាស់ពាណិជ្ជកម្ម ព្រមទាំងសិទ្ធិរបស់ និយោជិត និងនិយោជកក្នុងអំឡុងពេលបំពេញការងារផងដែរ។ម្យ៉ាងវិញទៀត ដើម្បីដំណើរការពាណិជ្ជកម្មរបស់យើង ឱ្យកាន់តែមានភាពរលូនទៅមុខ វាបានទាមទារឱ្យមានការរក្សាទុកនូវទិន្នន័យ ឬឯកសារសំខាន់ៗរបស់ម្ចាស់កម្មសិទ្ធិអាចជា និយោជក ម្ចាស់សហគ្រាស ឬអាជីវករផ្សេងៗដែលជាដៃគូសហការ ដែលការរក្សាទុកនេះយើងអាចហៅបានថា ការសម្ងាត់ពាណិជ្ជកម្ម។

ការសម្ងាត់ពាណិជ្ជកម្ម គឺជាបញ្ហាដ៏សំខាន់បំផុតរបស់ក្រុមហ៊ុន ដែលត្រូវបានរក្សាទុកយ៉ាងសម្ងាត់ដើម្បីផ្តល់ជាអត្ថប្រយោជន៍សម្រាប់ម្ចាស់កម្មសិទ្ធិ ក៏ដូចជាដើម្បីលាក់បាំងព័ត៌មាននានា ពីដៃគូប្រកួតប្រជែង

[1] កម្មសិទ្ធិបញ្ញា(Intellectual Property Right)

ពាណិជ្ជកម្មរបស់ក្រុមហ៊ុនខ្លួន។ ការសម្ងាត់ពាណិជ្ជកម្ម ត្រូវបានការពារដោយច្បាប់ និងត្រូវបានគេយកមកអនុវត្តផ្សេងៗគ្នា ទៅតាមបណ្តាប្រទេសនីមួយៗ។ ដោយឡែកចំពោះប្រទេសកម្ពុជាយើងបច្ចុប្បន្នវិញ កម្ពុជានៅមិនទាន់បានអនុម័តនូវច្បាប់ជាក់លាក់ណាមួយ ដែលទាក់ទងទៅនឹងការសម្ងាត់ពាណិជ្ជកម្មនៅឡើយទេ។[2] យ៉ាងណាមិញ សេចក្តីព្រៀងច្បាប់ ដែលទាក់ទងទៅ និង ការសម្ងាត់ពាណិជ្ជកម្ម កំពុងតែស្ថិតនៅក្នុងស្ថានភាពដែលចរចារនៅឡើយ។ ដរាបណាកម្ពុជានៅមិនទាន់អនុម័តនូវច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម ព័ត៌មានដែលចាំបាច់ត្រូវរក្សាទុកទាំងនោះ អាចនឹងត្រូវបានគេការពារ នៅក្រោមច្បាប់ដទៃទៀត ជាពិសេសនីតិកិច្ចសន្យា។ ឧទាហរណ៍៖ ដើម្បីរក្សាព័ត៌មាន នៅក្នុងអំឡុងពេលអនុវត្តការងារ ឬនៅក្នុងទំនាក់ទំនងកិច្ចសន្យានានា ព័ត៌មានដែលត្រូវបិទបាំងជាចាំបាច់ ឬរក្សាទុកជាសម្ងាត់ ត្រូវបានគេការពារនៅក្រោមច្បាប់កិច្ចសន្យា។

ដោយមើលឃើញពីភាពខ្វះខាតមួយចំនួន ក៏ដូចជាសារៈសំខាន់របស់ការសម្ងាត់ពាណិជ្ជកម្មនេះហើយ ទើបក្រុមនាងខ្ញុំ សម្រេចចិត្តធ្វើការសិក្សាទៅលើប្រធានបទ យន្តការការពារការសម្ងាត់ពាណិជ្ជកម្ម ដើម្បីជាការអភិវឌ្ឍន៍ទៅលើវិស័យកម្មសិទ្ធិបញ្ញា ក៏ដូចជាវិស័យពាណិជ្ជកម្ម នៅក្នុងប្រទេសកម្ពុជាឱ្យមានភាពកាន់តែប្រសើរជាងមុន។

នៅក្នុងការសិក្សាស្រាវជ្រាវលើសារណានេះ យើងខ្ញុំបានធ្វើការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវតាមរយៈប្រព័ន្ធអ៊ីនធើណេត តាមរយៈសៀវភៅ របាយការណ៍សិក្សា និង ឯកសារផ្សេងៗ ព្រមទាំងទិន្នន័យមួយចំនួនដែលទាក់ទងនឹងប្រធានបទយើងខ្ញុំ។ ហេតុដូចនេះហើយ ដើម្បីធ្វើការសិក្សាឱ្យកាន់តែស៊ីជម្រៅ និងមានភាពលម្អិតថែមទៀតនោះ យើងនឹងធ្វើការស្រាវជ្រាវ ហើយធ្វើការបែងចែកជា ៣ ជំពូកធំៗ គឺ

- ជំពូកទី១៖ ការកំណត់អត្តសញ្ញាណនៃការសម្ងាត់ពាណិជ្ជកម្ម
- ជំពូកទី២៖ យន្តការការពារការសម្ងាត់ពាណិជ្ជម្មនៅក្នុងកិច្ចសន្យាការងារ
- ជំពូកទី៣៖ យន្តការការពារការសម្ងាត់ពាណិជ្ជម្មនៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម

[2] ការការពារការសម្ងាត់នៅកម្ពុជា

# ជំពូកទី១៖ ការកំណត់ចរិតលក្ខណៈនៃការសម្រាត់ពាណិជ្ជកម្ម

## ជំពូកទី១៖ ការកំណត់ចរិតលក្ខណៈនៃការសម្ងាត់ពាណិជ្ជកម្ម

នៅក្នុងជំពូកទីមួយនៃ ការសិក្សាស្រាវជ្រាវដែលចងក្រងឡើង ជាសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ យើងនឹងមកធ្វើការសិក្សាទៅលើពីរផ្នែកធំៗ ដោយ **(ផ្នែកទី១)** យើង និង ធ្វើការសិក្សាទៅលើ ការកំណត់អត្តសញ្ញាណនៃការសម្ងាត់ពាណិជ្ជកម្ម ដែលមាននៅក្នុងច្បាប់អន្តរជាតិ និងច្បាប់ជាតិ ។ រីឯ**(ផ្នែកទី២)** យើងនឹងធ្វើការសិក្សាទៅលើ លក្ខខណ្ឌក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម ដែលមានកំណត់ពីលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌចុះបញ្ជី ជាដើម។

## ផ្នែកទី១៖ ការកំណត់អត្តសញ្ញាណនៃការសម្ងាត់ពាណិជ្ជកម្ម

សម្រាប់ផ្នែកទី១ នេះយើងនឹងធ្វើការសិក្សាទៅលើពីរចំនុចធំៗ ដែលនៅក្នុង កថាខណ្ឌទី១ យើងនឹងធ្វើការសិក្សាទៅលើនិយមន័យរបស់ការសម្ងាត់ពាណិជ្ជកម្មដែលមានចែងនៅក្នុងច្បាប់ជាតិ និង ច្បាប់អន្តរជាតិទាំងឡាយ។ ចំនែកឯ កថាខណ្ឌទី២ យើងនឹងធ្វើការសិក្សាការកំណត់នូវរាល់ប្រភេទព័ត៌មានដែលអាចចាត់ទុកថាជាការសម្ងាត់ពាណិជ្ជកម្ម។

### កថាខណ្ឌ១៖ ការកំណត់និយមន័យ

និយមន័យរបស់ការសម្ងាត់ពាណិជ្ជកម្មត្រូវបានគេរកឃើញទៅតាមទម្រង់ផ្សេងៗគ្នាទៀតដែលមាននៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានា។ យ៉ាងណាមិញ និយមន័យរបស់វាមិនត្រូវបានគេចែងយ៉ាងទូលំទូលាយនោះទេ។ ហេតុដូចនេះ នៅក្នុងផ្នែកនេះយើងនឹងធ្វើការក្រឡេកទៅមើលនិយមន័យការសម្ងាត់ពាណិជ្ជកម្មដែលអាចកំណត់ពីអត្តសញ្ញាណរបស់វា ទាំងនៅក្នុងច្បាប់ជាតិ និង អន្តរជាតិ។

### ១. ច្បាប់អន្តរជាតិដែលទាក់ទងនឹងការសម្ងាត់ពាណិជ្ជកម្ម

បច្ចុប្បន្នកាល កម្មសិទ្ធិបញ្ញា និង ការការពាររបស់កម្មសិទ្ធិបញ្ញាបានបង្កើតឡើងជា ផ្នែកមួយដ៏សំខាន់នៃការធ្វើពាណិជ្ជកម្ម ។ ទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិរវាង ប្រទេសផ្សេងគ្នាបានអភិវឌ្ឍឥតឈប់ឈរ ដោយប្រទេសទាំងនោះចូលរួមគ្រប់ ទំនាក់ទំនងរួមមានកម្មសិទ្ធិបញ្ញាផងដែរ ។ ជាអកុសល វិសាលភាពនៃការការពារ និង ការអនុវត្តនៃកម្មសិទ្ធិបញ្ញាមានភាពខុសគ្នាទូទាំងពិភពលោក។[3] បញ្ហានេះដែលធ្វើឱ្យ មានការបង្កើតនូវច្បាប់កម្មសិទ្ធិបញ្ញាអន្តរជាតិថ្មី ដើម្បីផ្តល់ឱ្យមានការការពារកម្មសិទ្ធិបញ្ញា រួមមានការសម្ងាត់ពាណិជ្ជកម្មឱ្យបានគ្រប់គ្រាន់។ ហេតុដូចច្នេះនៅក្នុងផ្នែកមួយនេះ យើងនឹងធ្វើការពិភាក្សា ដោយក្រឡេកទៅមើលពីកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយចំនួនដែលទាក់ទងនឹងការសម្ងាត់ពាណិជ្ជកម្ម ។

#### ១.១. កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា (TRIPs) មាត្រា ៣៩

[3] កម្មសិទ្ធិបញ្ញា៖ការការពារនិងការចូលជាធរមាន(Intelletual Property: protection and enforcement)

កិច្ចព្រមព្រៀងនេះបានធ្វើការបង្ហាញពីកម្រិតជាក់លាក់នៃការការពារ ដែលសមាជិកទាំងអស់ ត្រូវតែគោរពតាម ផ្នែកទី ១ នៃកិច្ចព្រមព្រៀងបានធ្វើការគ្របដណ្តប់លើបទប្បញ្ញត្តិទូទៅព្រមទាំង គោលការណ៍នៃកិច្ចព្រមព្រៀងដែលរដ្ឋជាសមាជិកត្រូវតែអនុវត្ត (ដូចជាការបញ្ចូលការអនុវត្តទៅក្នុងច្បាប់ជាតិ)។ កិច្ចព្រមព្រៀងនេះក៏បានពន្យល់បន្ថែមទៅលើ ប្រធានបទសំខាន់ៗនៃការការពារសិទ្ធិទទួលបានការលើកលែង និងពេលវេលានៃការការពារ។ ជាងនេះទៅទៀតផងដែរ អនុសញ្ញាមុន ៗ មួយចំនួន ដូចជា អនុសញ្ញាទីក្រុងប៉ារីសឆ្នាំ ១៩៦៧ អនុសញ្ញាប៊ែន អនុសញ្ញាទីក្រុងរ៉ូម ក៏នៅតែត្រូវអនុវត្តដោយគោរពតាមគោលការណ៍កិច្ចព្រមព្រៀង TRIPs ផងដែរ។ ចំណែកឯ ផ្នែកទីពីរនៃកិច្ចព្រមព្រៀងនេះវិញ បានធ្វើការបង្ហាញពីការប្រើប្រាស់និងលទ្ធភាពក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញា។ ខណៈពេលដែលផ្នែកទីបី បានគ្របដណ្តប់លើការអនុវត្តសិទ្ធិ និងដំណោះស្រាយដែលអាចរកបាន ក្នុងករណីដែលមានការរំលោភបំពាន។ រីឯ ផ្នែកចុងក្រោយ បានពិភាក្សា ទៅលើការផ្ទេរសិទ្ធិនិង វិធីដោះស្រាយវិវាទផ្សេងៗ។

ជាក់ស្តែងនៅក្នុងមាត្រា ៣៩ នៃកិច្ចព្រមព្រៀង TRIPs នេះមិនបានកំណត់នូវអ្វីដែលជា" ព័ត៌មានសម្ងាត់" ឡើយ។ យ៉ាងណាមិញ វាគ្រាន់តែបញ្ជាក់ពីលក្ខណៈវិនិច្ឆ័យនូវព័ត៌មានចាំបាច់មួយចំនួនដែលត្រូវបំពេញតាមលក្ខខណ្ឌដើម្បីចាត់ទុកថាជាការសម្ងាត់ពាណិជ្ជកម្ម។

យោងតាមមាត្រា ៣៩ កថាខណ្ឌទី២ នៃកិច្ចព្រមព្រៀង TRIPs ការសម្ងាត់ពាណិជ្ជកម្មគឺជាប្រភេទនៃព័ត៌មានដែលត្រូវបិទបាំងជាចាំបាច់ដោយត្រូវអនុលោមតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ដូចតទៅ៖

- ព័ត៌មានដែលជាការសម្ងាត់ គឺជាព័ត៌មាន ដែលមិនត្រូវបានគេស្គាល់ជាទូទៅឬ មិនអាចទទួលបានយ៉ាងងាយស្រួលចំពោះមនុស្សដែលមានប្រាស្រ័យទាក់ទងធម្មតាទៅនឹងប្រភេទនៃព័ត៌មាន។
- ព័ត៌មានដែលមានតម្លៃពាណិជ្ជកម្មពីព្រោះវាជាការសម្ងាត់។
- ព័ត៌មានដែលស្ថិតនៅក្រោមកាលៈទេសៈសមហេតុផល ដែលត្រូវគ្រប់គ្រងព័ត៌មានដោយបុគ្គលស្របច្បាប់ដើម្បីរក្សាការសម្ងាត់។[4]

លក្ខណៈវិនិច្ឆ័យទីមួយ បានចែងថាព័ត៌មានមិនគួរត្រូវបានដឹងជាទូទៅ ឬអាចទទួលបានដោយងាយស្រួលនោះទេហើយ ខ្លឹមសារនៃការសម្ងាត់ពាណិជ្ជកម្មក៏មិនគួរត្រូវបានបង្ហាញដែរ។ លក្ខណៈវិនិច្ឆ័យទីមួយដែលបានចែងថា ព័ត៌មានមិនគួរត្រូវបានដឹងជាទូទៅ ឬ អាចទទួលបានដោយងាយស្រួលទេ ហើយខ្លឹមសារនៃការសម្ងាត់ពាណិជ្ជកម្មមិនគួរត្រូវបានបង្ហាញ។ ទោះបីជាព័ត៌មានមានតម្លៃជាលក្ខណៈ ពាណិជ្ជកម្មក៏ដោយ ប្រសិនបើវាជាកម្មសិទ្ធិសាធារណៈ វាមិនអាចចាត់ទុកបានថាជាសម្ងាត់ពាណិជ្ជកម្មបានទេរ។ នោះហើយជា

[4] មាត្រា៣៩ នៃកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា

មូលហេតុដែលអាថ៌កំបាំងពាណិជ្ជកម្មអាចត្រូវបានគេដឹង មិនត្រឹមតែចំពោះម្ចាស់ក្រុមហ៊ុនរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែគាត់អាចប្រាប់រឿងនេះដល់និយោជិត ឬ មនុស្សផ្សេងទៀតបាន ដោយមានការសន្និដ្ឋានអំពីកិច្ចសន្យារក្សាការសម្ងាត់ (nondisclosure agreement) ដូច្នេះ អាថ៌កំបាំងពាណិជ្ជកម្ម នឹងមិនបាត់បង់តម្លៃទេ។ ក្នុងន័យនេះផងដែល សំណួរសំខាន់ គឺថា "តើត្រូវផ្សព្វផ្សាយពត៌មានទូលំទូលាយយ៉ាងណាដែលអាច បញ្ឈប់ការចាត់ទុកជាពាណិជ្ជកម្មសម្ងាត់បាន?"

ចំនែកឯ លក្ខណៈវិនិច្ឆ័យទីពីរវិញ សម្រាប់ព័ត៌មានដើម្បីជាការសម្ងាត់ពាណិជ្ជកម្មគឺត្រូវតែជាព័ត៌មានត្រូវតែមានតម្លៃពាណិជ្ជកម្ម។ ដោយឡែក ការសម្ងាត់ពាណិជ្ជកម្មត្រូវតែផ្តល់លទ្ធភាពឱ្យដល់ម្ចាស់ក្រុមហ៊ុនរបស់ខ្លួននូវអត្ថប្រយោជន៍សេដ្ឋកិច្ចជាងដៃគូប្រកួតប្រជែង។ ដោយសារតែតម្លៃពាណិជ្ជកម្មរបស់វា ព័ត៌មានទាំងនោះអាចមានប្រយោជន៍និងអាចផ្តល់នូវអត្ថប្រយោជន៍ទៅដល់ម្ចាស់ក្រុមហ៊ុន។ ផលប្រយោជន៍ទាំងនោះអាចលេចឡើង តាមរយៈការទទួលបានប្រាក់ចំណេញពីការសំរេចបាននូវផលិតផលដែលត្រូវបានផលិតដោយប្រើបច្ចេកវិទ្យាសម្ងាត់។ ជាក់ស្តែង ក្រុមហ៊ុនដែលជាដៃគូប្រកួតប្រជែងអាចកំពុងព្យាយាមចង់ បានព័ត៌មានទាំងនេះដើម្បីដឹងពីតម្លៃរបស់វា ក្នុងការទទួលបានផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច។

ចំពោះលក្ខណៈវិនិច្ឆ័យទី៣វិញ វាចាំបាច់សម្រាប់ ម្ចាស់ការសម្ងាត់ក្នុងការដាក់ចេញនូវ វិធានការសម្រាប់ការពារការសម្ងាត់ពាណិជ្ជកម្ម ពីភាគីទីបី។ ឧទាហរណ៍ដូចជា កិច្ចព្រមព្រៀងនៅក្នុងកិច្ចសន្យាជាដើម។

ហេតុដូច្នេះហើយ មាត្រា ៣៩ នៃកិច្ចព្រមព្រៀង TRIPs មិនបានផ្តល់និយមន័យច្បាស់លាស់នៃការសម្ងាត់ពាណិជ្ជកម្មនោះទេ ប៉ុន្តែ វាបានទាមទារឱ្យរដ្ឋជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដាក់ចេញនូវវិធានការដើម្បីធានាការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងច្បាប់ក្នុងស្រុក។ ជាលទ្ធផលព័ត៌មានសម្ងាត់ទាំងនោះចាំបាច់ ត្រូវតែបំពេញទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចដែលបានរៀបរាប់ខាងលើនេះដើម្បីចាត់ទុកថាជាការសម្ងាត់ពាណិជ្ជកម្ម។

### ១.២. កិច្ចព្រមព្រៀងពាណិជ្ជកម្មដោយសេរីរបស់អាមេរិកខាងជើង NAFTA

កិច្ចព្រមព្រៀងពាណិជ្ជកម្ម ដោយសេរីរបស់អាមេរិកខាងជើង (NAFTA) បានចូលជាធរមានក្នុងឆ្នាំ ១៩៩៤។ កិច្ចព្រមព្រៀងមួយនេះ ត្រូវបានគេចាត់ទុកថាជាការបង្កើតរបបពាណិជ្ជកម្ម ដោយសេរីដ៏ធំបំផុតក្នុងពិភពលោកនិងបានបង្កើតនូវ រចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងរហ័សរវាងប្រទេស ដែលមានកំណើនពាណិជ្ជកម្មបី គឺប្រទេសកាណាដា សហរដ្ឋអាមេរិក និងម៉ិកស៊ិក។[5]

សហរដ្ឋអាមេរិកបានចាប់ផ្តើមការពិភាក្សាពាណិជ្ជកម្មជាមួយប្រទេសកាណាដា ហើយក៏បានបង្កើតនូវ

[5] ច្បាប់ការពារការសម្ងាត់ពាណិជ្ជកម្ម៖ ករណីសិក្សានៅLatvia

កិច្ចព្រមព្រៀងពាណិជ្ជកម្មដោយសេរី រវាងសហរដ្ឋអាមេរិកនិងកាណាដា។ កិច្ចព្រមព្រៀងបានចូលជាធរមាននៅក្នុងខែមករាឆ្នាំ១៩៨៩ ហើយក្នុងឆ្នាំ១៩៩១ ក៏មានការចាប់ផ្ដើមកើតឡើងនូវការពិភាក្សារវាងសហរដ្ឋអាមេរិកនិងម៉ិកស៊ិក ដោយក្រោយមកប្រទេសកាណាដាក៏បានចូលរួមជាបន្ទាប់។ ការពិភាក្សាមួយនេះបានបណ្ដាលឱ្យមានការបង្កើតពាណិជ្ជកម្មដោយសេរី និងលុបបំបាត់នូវរាល់ព័ន្ធនូវការនាំចេញ នាំចូលនិងការរឹតត្បិតទៅលើបរិមាណទំនិញផ្សេងៗ។

កិច្ចព្រមព្រៀងនេះផងដែរ ក៏បានកំណត់ពីការសម្ងាត់ពាណិជ្ជកម្មដែល ការសម្ងាត់ពាណិជ្ជកម្មត្រូវបានគេកំណត់ថាជា ព័ត៌មានលម្អិតដែលមិនត្រូវបើកបង្ហាញជាសាធារណៈ និងមិនត្រូវបានគេស្គាល់ជាលក្ខណៈទូទៅនោះទេ។ ជាងនេះទៀត វាបានកត់សម្គាល់ថាការសម្ងាត់ពាណិជ្ជកម្ម គឺមានតម្លៃពាណិជ្ជកម្ម ហើយបុគ្គលដែលជាម្ចាស់កម្មសិទ្ធិត្រូវតែមានមធ្យោបាយគ្រប់គ្រាន់ដើម្បីការការពារសម្ងាត់នេះ។

ទោះបីជាកិច្ចព្រមព្រៀងមួយនេះ បានកំណត់ពីនិយមន័យរបស់វា បានយ៉ាងច្បាស់លាស់យ៉ាងណាក្ដីសម្រាប់កិច្ចព្រមព្រៀង TRIPs វិញគឺបានផ្ដល់និយមន័យមួយនេះយ៉ាងទូលំទូលាយជាខ្លាំង ដោយសារតែវាមានសក្ដានុភាពនិងតម្លៃជាក់ស្ដែងនៅ ក្នុងវិស័យពាណិជ្ជកម្ម។ ការសម្ងាត់ពាណិជ្ជកម្មអាចត្រូវបាន រួមបញ្ចូលទាំងព័ត៌មានដែលត្រូវបានប្រើក្នុងអាជីវកម្មនិងព័ត៌មានដែលមិនអាចបើកបង្ហាញ ប៉ុន្តែអាចយកទៅប្រើប្រាស់នាថ្ងៃអនាគត។

**១.៣. សហភាពអឺរ៉ុប** European Union

សហភាពអឺរ៉ុប គឺជាអង្គការអន្តរជាតិដែលបានបង្កើតឡើងដោយមានរដ្ឋជាសមាជិកចំនួន ២៨រដ្ឋ។ ច្បាប់របស់សហភាពអឺរ៉ុបមួយនេះត្រូវបង្កើតឡើងដោយសភាអឺរ៉ុបនិងក្រុមប្រឹក្សារបស់វា។ បន្ទាប់ពីច្បាប់ត្រូវបានបង្កើតឡើង គេរំពឹងថានឹងត្រូវវាបានអនុវត្តនៅក្នុងរដ្ឋជាសមាជិកទាំងអស់ ពួកគេនឹងត្រូវបានទទួលខុសត្រូវប្រសិនបើមានរដ្ឋណាមួយ មិនអនុវត្តតាមច្បាប់ទាំងនោះ។ យ៉ាងណាមិញ សហភាពអឺរ៉ុបនៅមិនទាន់មានការរៀបចំយ៉ាងជាក់លាក់ទៅលើការសម្ងាត់ពាណិជ្ជកម្មនោះទេ។[6] ប្រទេសនីមួយៗ នៅក្នុងសហភាពអឺរ៉ុបមានការអនុវត្តនូវការការពារពាណិជ្ជកម្មនេះទៅតាមទស្សនៈនិងច្បាប់ផ្សេងៗគ្នា។ ឧបសគ្គដ៏ធំរបស់ សហភាពអឺរ៉ុបនៅក្នុងការអនុវត្តការការពារនេះគឺ ដោយសារតែកម្រិតនៃច្បាប់របស់ជាសមាជិក ដែលមានលក្ខណៈចម្រុះទៅតាមច្បាប់ជាតិនីមួយៗរបស់រដ្ឋនោះ។ នៅក្នុងសហគមន៍អឺរ៉ុបគឺ មិនមានបទបញ្ញត្តិណាដែលចែងច្បាស់លាស់ទៅលើការការពារសម្ងាត់ពាណិជ្ជកម្មនោះទេ។ យ៉ាងណាមិញរដ្ឋដែលជាសមាជិកនីមួយៗ មានច្បាប់ជាតិផ្ទាល់ខ្លួនសម្រាប់ការអនុវត្តចំពោះបញ្ហានេះដោយអាស្រ័យទៅ តាមការបែងចែកនៅក្នុងនីតិការងារ នីតិព្រហ្មទណ្ឌនិងវិធានមួយចំនួនដែលកើតចេញពី វិស័យឧស្សាហកម្មនានាទៅនឹងការសម្ងាត់ក្នុងការអនុវត្តវិជ្ជាជីវៈដូចជា ធនាគារ

[6] ច្បាប់ការពារការសម្ងាត់ពាណិជ្ជកម្ម៖ ករណីសិក្សានៅLatvia

ហិរញ្ញវត្ថុ វេជ្ជសាស្ត្រ ។ល។

សហភាពអឺរ៉ុបបានប្រឈមមុខ នឹងបញ្ហាជាច្រើនដោយសារតែកង្វះខាតនូវការការពារគ្រប់គ្រាន់ទៅលើការសម្ងាត់ពាណិជ្ជកម្ម។ លទ្ធផលនេះបានធ្វើឱ្យគណៈកម្មការអឺរ៉ុបបានចាប់ផ្ដើមធ្វើការស្រាវជ្រាវមួយ ដោយបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១២ដែលស្ដីពីការការពារ ការសម្ងាត់ពាណិជ្ជកម្មក្នុងចំណោមរដ្ឋដែលជាសមាជិករបស់ខ្លួន។ ការសិក្សាមួយនេះបានបង្ហាញពីយុត្តាធិការខុសៗគ្នា នៃការអនុវត្តដោយមានរដ្ឋខ្លះនៅតែមានការការពារយ៉ាងតិចតួចបំផុត។ ដោយឡែក មានតែប្រទេសស៊ុយអែតតែប៉ុណ្ណោះដែលមានច្បាប់ចែងច្បាស់លាស់ទៅលើការសម្ងាត់ពាណិជ្ជកម្ម ខណៈដែលប្រទេសផ្សេងទៀតនៅតែបន្តពឹងផ្អែកនៃការការពារនេះលើច្បាប់ដែលពាក់ព័ន្ធផ្សេងៗដូចជា នីតិកិច្ចសន្យា និងច្បាប់ដែលដោះស្រាយនៅតាមតុលាការជាដើម។ នៅក្នុងឆ្នាំ២០១៣ការសិក្សាចុងក្រោយសម្រាប់គណៈកម្មការនេះត្រូវបានផ្សព្វផ្សាយ ព្រមទាំងបានគេពិនិត្យមើលថាតើការសម្ងាត់ពាណិជ្ជកម្មនេះមានសារៈសំខាន់យ៉ាងណា ដើម្បីធានាបាននូវការខិតខំប្រឹងប្រែង របស់ក្រុមហ៊ុនផ្សេងៗនីមួយក្នុងទីផ្សារ។ ទោះបីជាយ៉ាងណាក្ដី ក្រុមប្រឹក្សាអឺរ៉ុបនិងសហភាពអឺរ៉ុបបានផ្ដល់សច្ចាប័នយ៉ាងរួចរាល់លើសារាចរណែនាំរបស់សភាអឺរ៉ុបនិងក្រុមប្រឹក្សាស្ដីពីការការពារចំណេះដឹងនិងព័ត៌មានពាណិកម្ម ឬការសម្ងាត់ពាណិជ្ជកម្មដែលប្រឆាំងនឹងការប្រើប្រាស់និងលាតត្រដាងនូវព័ត៌មានដោយមិនមានលក្ខណៈត្រឹមត្រូវ។ គោលបំណងនៃការបង្កើតសារាចរនេះគឺ ដើម្បីការពារការលួចនិងការប្រើប្រាស់ខុសច្បាប់នៃការសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុននានានៅសហភាពអឺរ៉ុប ដែលវិធីនេះផងដែលនឹងបណ្ដាលឱ្យមានមធ្យោបាយជាស្ដង់ដារមួយនៅក្នុងការការពារសហភាពអឺរ៉ុបទាំងមូល។ រដ្ឋជាសមាជិកត្រូវបានផ្ដល់ឱ្យនូវរយៈពេលកំណត់ពីរឆ្នាំ សម្រាប់ដាក់បញ្ចូលនូវសេចក្ដីណែនាំមួយនេះនៅក្នុងច្បាប់ជាតិរបស់ខ្លួន។ សេចក្ដីណែនាំនេះនឹងចូលជាធរមាននៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៨ និងមានគោលបំណងផ្ដល់នូវ យន្តការមួយតាមរយៈម្ចាស់ពាណិជ្ជកម្មដើម្បីបញ្ឈប់ការប្រើប្រាស់ និងការលាតត្រដាងនូវអាថ៌កំបាំងក៏ដូចជាទាមទាររាល់ការខូចខាត ដែលបណ្ដាលមកពីការប្រើប្រាស់ខុសច្បាប់ ឬការបង្ហាញនូវការសម្ងាត់ពាណិជ្ជកម្មនេះ។

យ៉ាងណាមិញ សហភាពអឺរ៉ុបពុំបានបញ្ជាក់ច្បាស់លាស់ពីនិយមន័យ នៃការសម្ងាត់ពាណិជ្ជកម្មទេ ដោយផ្ទុយទៅវិញការសម្ងាត់ពាណិជ្ជកម្មត្រូវតែបំពេញតាមលក្ខណៈជាការសម្ងាត់ពាណិជ្ជកម្ម។ នាពេលកន្លងមក ប្រទេសជាច្រើនរួមបញ្ចូលទាំងសហភាពអឺរ៉ុបមិនបានបង្កើតច្បាប់ដែលចែងពីការសម្ងាត់ផ្នែកពាណិជ្ជកម្មនេះទេ ដោយឡែកប្រទេសខ្លះបានកំណត់និយមន័យរបស់វាតាមរយៈករណីដែលកើតមានឡើងផ្សេងៗ។

**២. ច្បាប់ជាតិដែលពាក់ព័ន្ធនឹងការសម្ងាត់ពាណិជ្ជកម្ម**

ការសម្ងាត់ពាណិជ្ជកម្ម គឺជាព័ត៌មានអាជីវកម្មដែលបានផ្ដល់ឱ្យនូវសហគ្រាស ឬក្រុមហ៊ុននូវការប្រកួតប្រជែង។ ការសម្ងាត់ពាណិជ្ជកម្ម ដែលមានលក្ខណៈការផលិតរបស់ផលិតកម្ម ដែលអាចជាដំណើរការមួយនៃ

ការផលិត រូបមន្ត វត្ថុធាតុដើមក្នុងការផលិត ឬក៏ជាដំណើរការនានានៃការផលិតផងដែល ដូចជាក្រុមហ៊ុនផលិតចំណីអាហារ ភេសជ្ជៈ ឬផលិតផលប្រើប្រាស់គ្រប់ប្រភេទ។[7] ការសម្ងាត់ពាណិជ្ជកម្មក៏អាចជាទិន្នន័យផ្សេងៗដែលមានសារៈសំខាន់សម្រាប់ក្រុមហ៊ុន ឬសហគ្រាស ដូចជាបញ្ជីអតិថជន បញ្ជីបង្ហាញពីផែនការ គម្រោង ឬបញ្ជីនៃការចំណាយ ប្រាក់ចំណូល ឬប្រាក់ចំណេញ ឬបញ្ជីបុគ្គលិក និងការគ្រប់គ្រងរបស់ក្រុមហ៊ុន ឬម្ចាស់សហគ្រាស ណាមួយ។ ព័ត៌មានសម្ងាត់ដែលទាក់ទងទៅនិងការបង្កើតបច្ចេកវិទ្យា ព័ត៌មានសម្ងាត់ក្នុងវិស័យឧស្សាហកម្ម និងអាជីវកម្មផ្សេងៗក៏ចាត់ទុកជាការសម្ងាត់ពាណិជ្ជកម្មដែរ។

រាល់ការបង្ហើបបង្ហាញ ឬប្រើប្រាស់ព័ត៌មានសម្ងាត់ពាណិជ្ជកម្មដោយតតិយជន អាចចាត់ទុកថា មានលក្ខណៈផ្ទុយទៅនិង ការអនុវត្តពាណិជ្ជកម្មដោយស្មោះត្រង់។

«សម្ងាត់» មានន័យថា៖

- នៅក្នុងទម្រង់ទាំងមូល ឬជារូបសណ្ឋានជាក់លាក់ ឬបណ្តុំសមាសភាពរបស់វា ដែលគេមិនទាន់ដឹងឬស្គាល់ក្នុងចំណោម ឬមិនអាចនឹង ធ្លាយដឹងលឺដល់បុគ្គលដែលស្ថិតនៅក្នុងជួរក្រុម ដែលជាធម្មតាទាក់ទងនឹងប្រភេទព័ត៌មានបែបនេះ។
- មានតម្លៃពាណិជ្ជកម្មពិតប្រាកដឬតម្លៃពាណិជ្ជកម្មជាសក្តានុពលដោយសារតែភាពជាសម្ងាត់របស់វា។
- ជាកម្មវត្ថុនៃជំហាននៃការរក្សាជាសម្ងាត់ដ៏សមស្របទៅតាមស្ថានភាព ដោយបុគ្គលដែលមានសិទ្ធិក្នុងការគ្រប់គ្រងព័ត៌មាននេះ។

«ព័ត៌មាន» សម្រាប់ប្រើប្រាស់ក្នុងការសម្ងាត់ពាណិជ្ជកម្មមានន័យថា ជាព័ត៌មានដែលបង្កើតជា ឬមាននៅក្នុង ឬបញ្ចូលជា រូបមន្ត គំរូ ផែនការ ផលិតផល ការព្យាករណ៍ទីផ្សារ យុទ្ធសាស្ត្រ បញ្ជីអតិថជន ទិន្នន័យគណនីលក់ បញ្ជីគណនេយ្យ វិធីសាស្ត្រ បច្ចេកទេស ដំណើរការផលិត ។ល។[8]

### ២.១. ការសម្ងាត់ពាណិជ្ជកម្មក្នុងលក្ខខណ្ឌកិច្ចសន្យាការងារ

កិច្ចសន្យាការងារកើតពីការព្រមព្រៀងរវាងនិយោជក និងនិយោជិត ដែលមានការកំណត់នូវលក្ខខណ្ឌផ្សេងៗ ដូចជាប្រាក់ឈ្នួល និងកិច្ចការពលកម្ម ដែលនិយោជិតត្រូវបំពេញឬលក្ខខណ្ឌផ្សេងៗទៅតាមប្រភេទ និងលក្ខខណ្ឌរបស់និយោជក។[9] កិច្ចសន្យាការងារត្រូវធ្វើឡើងដោយជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ចំពោះកិច្ចសន្យាដែលធ្វើឡើង ដោយផ្ទាល់មាត់ត្រូវបានចាត់ទុកថាជាការព្រមព្រៀងរបស់និយោជក និង

[7] និយមន័យកម្មសិទ្ធិបញ្ញា(នាយកដ្ឋានកម្មសិទ្ធបញ្ញា)

[8] មាត្រា២២ នៃអត្ថបទព្រៀងច្បាប់ស្តីពីព័ត៌មានសម្ងាត់ និងការផ្តល់អាជ្ញាប័ណ្ណបង្ខំសម្រាប់សុខភាពសាធារណៈ និងការសម្ងាត់ពាណិជ្ជកម្ម

[9] មាត្រា ៦៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

និយោជិតតាមលក្ខខណ្ឌដែលចែងក្នុងបទបញ្ជាការងារបើទោះជាមិនមានបញ្ជាក់ច្បាស់លាស់ក៏ដោយ។[10]

ក្នុងការកំណត់លក្ខខណ្ឌក្នុងកិច្ចសន្យា ដែលមានកំណត់ពីការសម្ងាត់ពាណិជ្ជកម្ម ត្រូវតម្រូវឱ្យនិយោជិតធ្វើការរក្សាជាសម្ងាត់នូវព័ត៌មាននៃទិន្នន័យ ឬរូបមន្ត គំរូ ឬការបង្កើត ឬបញ្ជី ផ្សេងៗ ដែលនិយោជកបានធ្វើការកំណត់នៅក្នុងកិច្ចសន្យានោះ។ ក្នុងករណីដែលនិយោជិតបានធ្វើការបង្ហើបបង្ហាញនូវព័ត៌មានទាំងនោះ ទៅដល់តតិយជន ឬជាសាធារណៈ ឬយកទៅប្រើប្រាស់ ក្នុងសណ្ឋានដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់និយោជក នោះនិយោជកអាចធ្វើការរំលាយនូវកិច្ចសន្យាការងារដែលបាន ធ្វើឡើងរវាងកម្មករនិយោជិត និងនិយោជកដោយដោយក្រោមសណ្ឋានដោយនិយោជិតបានប្រព្រឹត្តិនូវកំហុសដែលធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់និយោជក។[11]

**កថាខណ្ឌ២៖ ការកំណត់ប្រភេទព័ត៌មានដែលចាត់ទុកថាជាការសម្ងាត់ពាណិជ្ជកម្ម**

ជាទូទៅរាល់ព័ត៌មានអាជីវកម្មណាមួយដែលផ្តល់ដល់សហគ្រាសនូវការប្រកួតប្រជែង នឹងមិនត្រូវបានស្គាល់ជាសាធារណៈជន អាចត្រូវបានការពារជាការសម្ងាត់ពាណិជ្ជកម្ម។

ព័ត៌មានដែលអាចមានលក្ខណៈគ្រប់គ្រាន់ជាការសម្ងាត់ពាណិជ្ជកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

1. ការសម្ងាត់ពាណិជ្ជកម្មអាចមានព័ត៌មានទាក់ទងនឹងរូបមន្ត គំរូឧបករណ៍ ឬការចងក្រងព័ត៌មានផ្សេងទៀតដែលត្រូវបានប្រើប្រាស់ក្នុងរយៈពេលដ៏យូរនៅក្នុងអាជីវកម្ម។
2. ការសម្ងាត់ពាណិជ្ជកម្មគឺជាព័ត៌មានបច្ចេកទេសដែលត្រូវបានប្រើនៅក្នុងដំណើរការសម្រាប់ការផលិតទំនិញណាមួយ។
3. ការសម្ងាត់ពាណិជ្ជកម្មអាចទាក់ទងទៅ នឹងយុទ្ធសាស្ត្រទីផ្សារការនាំចេញឬការលក់ ឬវិធីនៃការរក្សាបញ្ជីឈ្មោះ ឬបែបបទនៃការគ្រប់គ្រងអាជីវកម្ម ឬនីតិវិធីផ្សេងទៀតរួមទាំង Software ដែលត្រូវបានប្រើសម្រាប់គោលបំណងអាជីវកម្មផ្សេងៗ។[12]

ឧទាហរណ៍មួយចំនួនទៀតដែលទាក់ទង នឹងការសម្ងាត់ពាណិជ្ជកម្មដែលមានសក្តានុពលអាចរួមមានព័ត៌មានបច្ចេកទេស វិទ្យាសាស្ត្រ ឬហិរញ្ញវត្ថុដូចជាផែនការអាជីវកម្ម ដំណើរការអាជីវកម្ម បញ្ជីអតិថិជនសំខាន់បញ្ជីអ្នកផ្គត់ផ្គង់ដែលអាចទុកចិត្តបាន ឬពិសេសការបញ្ជាក់ពីផលិតផល លក្ខណៈផលិតផល តម្លៃទិញវត្ថុធាតុដើមសំខាន់ៗ ទិន្នន័យសាកល្បង គំរូ ឬគំនូរព្រាងបច្ចេកទេសវិស្វកម្ម រូបមន្តដែលកម្មសិទ្ធិផ្ទាល់ខ្លួន។ ខ្លឹមសារនៃសៀវភៅកំណត់ត្រា មន្ទីរពិសោធន៍រចនាសម្ព័ន្ធប្រាក់ខែរបស់ក្រុមហ៊ុនអត្រាផលិតផល និងអត្រាការផ្សាយ

[10] មាត្រា៦៥ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧

[11] មាត្រា៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧

[12] ការសម្ងាត់ពាណិជ្ជកម្ម

ពាណិជ្ជកម្មប្រភពនៃមូលដ្ឋានទិន្នន័យនិង ការចងក្រងទិន្នន័យអេឡិចត្រូនិចកិច្ចព្រមព្រៀង ដែលមានព័ត៌មានលំម្អិតអំពីការផ្សារភ្ជាប់ទីផ្សារការផ្សព្វផ្សាយ ឬសម្ភារៈផ្សព្វផ្សាយកំពុងត្រូវបានអភិវឌ្ឍក៏ត្រូវបានគេចាត់ទុកថាជាព័ត៌មាននៃការសម្ងាត់ពាណិជ្ជកម្មផងដែរ។

## ផ្នែកទី២៖ លក្ខខណ្ឌក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម

សម្រាប់ផ្នែកទី២នេះវិញ យើងនឹងធ្វើការសិក្សាទៅលើពីរចំនុចធំៗ ដែលនៅក្នុងកថាខណ្ឌទី១ យើងនឹងធ្វើការសិក្សាទៅលើ លក្ខខណ្ឌគ្រឹះក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម។ ចំនែកឯកថាខណ្ឌទី២ យើងនឹងធ្វើការសិក្សា ទៅលើលក្ខខណ្ឌចុះបញ្ជីវិញម្តង។

### កថាខណ្ឌ១៖ លក្ខខណ្ឌគ្រឹះ

ដើម្បីឱ្យព័ត៌មានត្រូវបានការពារជាការសម្ងាត់ពាណិជ្ជកម្មត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យខាងក្រោម៖

- ព័ត៌មានត្រូវតែជាការសម្ងាត់ ហើយការសម្ងាត់នោះមិនចាំបាច់មានលក្ខណៈដាច់ខាតទេ។ ឧទាហរណ៍ ការសម្ងាត់ពាណិជ្ជកម្ម អាចត្រូវបានរក្សាទុកដោយភាគី ជាច្រើនដរាបណាវាមិនត្រូវបានគេស្គាល់ដល់មនុស្សផ្សេងទៀតដែលធ្វើការនៅក្នុងវិស័យនេះ។
- វាត្រូវតែមានតម្លៃពាណិជ្ជកម្មជាក់ស្តែងឬមានសក្តានុពលពាណិជ្ជកម្មព្រោះវាជាការសម្ងាត់។
- វាត្រូវតែជាកម្មវត្ថុនៃមធ្យោបាយសមហេតុផល ដោយអ្នកកាន់ព័ត៌មានស្របច្បាប់ ដើម្បីរក្សាការសម្ងាត់ (ឧទាហរណ៍តាមរយៈកិច្ចព្រមព្រៀងរក្សាការសម្ងាត់)។[13] ខណៈពេលដែលមធ្យោបាយ សមហេតុផលអាចពឹងផ្អែកលើកាលៈទេសៈនៃករណីនីមួយៗ ដូចជាការសម្គាល់ឯកសារសម្ងាត់ ការដាក់កម្រិតរូបមន្តនិងអេឡិចត្រូនិចដើម្បីទទួលបានព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ការណែនាំប្រព័ន្ធត្រួតពិនិត្យនិងការលើកកម្ពស់ការយល់ដឹងរបស់និយោជិតគឺជាវិធានការណ៍ដើម្បីការពារការសម្ងាត់ពាណិជ្ជកម្ម។

### កថាខណ្ឌ២៖ លក្ខខណ្ឌចុះបញ្ជី

ខុសពីកម្មសិទ្ធិបញ្ញាដទៃទៀត ដែលរួមមានដូចជា ប៉ាតង់ សិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែលគំនូរឧស្សាហកម្មផ្សេងៗដែលតម្រូវឱ្យមានការចុះបញ្ជី ការសម្ងាត់ពាណិជ្ជកម្មមិនតម្រូវឱ្យមានការចុះបញ្ជីដើម្បីទទួលបានការការពារនោះទេ ដោយឡែកការការពារនៃការសម្ងាត់ពាណិជ្ជកម្ម នឹងត្រូវធ្វើទៅតាមរូបភាពផ្សេងៗ ដោយពឹងផ្អែកលើលក្ខខណ្ឌគ្រឹះដូចដែលបានរៀបរាប់ខាងលើ។

[13] មូលដ្ឋានគ្រឹះនៃការសម្ងាត់ពាណិជ្ជកម្ម

# ជំពូកទី២៖ យន្តការការពារការសម្រាប់
# ពាណិជ្ជកម្មក្នុងកិច្ចសន្យាការងារ

## ជំពូកទី២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងកិច្ចសន្យាការងារ

នៅក្នុងជំពូកទីពីរនៃការសិក្សាស្រាវជ្រាវដែលចងក្រមជា សារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ យើងនឹងមកធ្វើការសិក្សាទៅលើពីរផ្នែកធំៗ ដោយ **(ផ្នែកទី១)** យើងនិងធ្វើការសិក្សាទៅលើ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាការងារ ដោយធ្វើការសិក្សាផ្តោតទៅលើវិធាន និង យន្តការផ្សេងៗ ក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម ដែលកើតចេញពីទំនាក់ទំនងនិយោជិត និងនិយោជក។ ចំណែកឯ **(ផ្នែកទី២)** យើងនឹងធ្វើការសិក្សាទៅលើយន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងក្រោយពេលបញ្ចប់កិច្ចសន្យាការងារ ដោយនឹងធ្វើការសិក្សាលម្អិត ដែលទាក់ទងពីកាតព្វកិច្ចរបស់និយោជិតក្នុងការពារការសម្ងាត់ពាណិជ្ជកម្មរបស់អតីតនិយោជកក្រោយពេលបញ្ចប់ការងាររបស់ខ្លួន។

### ផ្នែកទី១៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងកិច្ចសន្យាការងារ

សម្រាប់ផ្នែកទី១ នេះយើងនឹងធ្វើការសិក្សាទៅលើបីចំនុចធំៗ ដោយ រួមមានទំនាក់ទំនងនិយោជិតនិងនិយោជកក្នុងការការសម្ងាត់ពាណិជ្ជកម្ម យន្តការការពារការសម្ងាត់ពាណិជ្ជកម្ម ក្នុងពេលអនុវត្តកិច្ចសន្យាការងារ ព្រមទាំង ថេរវេលានៃការការពារការសម្ងាត់ពាណិជ្ជកម្ម។

#### កថាខណ្ឌ១៖ ទំនាក់ទំនងនិយោជិត និងនិយោជកក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម

និយោជកអាចការពារនូវ ការសម្ងាត់ពាណិជ្ជកម្មរបស់ពួកគេតាមរយៈ ការធ្វើកិច្ចសន្យារក្សាការសម្ងាត់រវាងនិយោជិតសំខាន់នីមួយៗ ឬដោយពឹងផ្អែកលើវិធានបញ្ញត្តិរួមមួយរបស់ទីភ្នាក់ងារក្រុមហ៊ុនឬ គោលការណ៍ណាមួយដែលក្រុមហ៊ុនបានបង្កើតឡើង។ និយោជិតមានកាតព្វកិច្ចមិនបើកបង្ហាញនូវព័ត៌មានសម្ងាត់ណាមួយដែលគាត់បានទទួលបានតាមរយៈ ការងាររបស់គាត់ទៅឱ្យតតិយជននោះឡើយ។ ព័ត៌មានសម្ងាត់ត្រូវតែរក្សាទុកដោយភាពទុកចិត្តសម្រាប់និយោជក។[14]

ជាងនេះទៅទៀត និយោជិតមានកាតព្វកិច្ចយ៉ាងជាក់លាក់មួយក្នុងការរក្សានូវព័ត៌មានទាំងឡាយណាដែលជាកម្មសិទ្ធិរបស់និយោជកឱ្យនៅជាការសម្ងាត់។ យ៉ាងណាមិញ ការបង្ហាញកាតព្វកិច្ចនេះ គឺត្រូវធ្វើឡើងតាមរយៈ កិច្ចសន្យាសមរម្យណាមួយ ដែលនិយោជិតត្រូវយល់ព្រមទទួលថា រាល់ព័ត៌មានសំខាន់ៗដែលទទួលបានក្នុងពេលបំពេញការងារគឺត្រូវតែរក្សាជាការសម្ងាត់ និងជាការសម្ងាត់ពាណិជ្ជកម្ម របស់និយោជកដែលមិនអាចបើកបង្ហាញបាន។ បន្ថែមពីលើនេះទៀត រាល់ការការរក្សាព័ត៌មានសម្ងាត់នេះនិយោជកគួរតែមានការកំណត់នូវអត្តសញ្ញាណព័ត៌មានឱ្យបានកាន់តែច្បាស់លាស់ សម្រាប់និយោជិត របស់ខ្លួនតាមដែលអាចធ្វើទៅបាន

[14] ការសម្ងាត់ពាណិជ្ជកម្មនិងនិយោជិតជំនាញនៅក្នុងវិស័យបច្ចេកវិទ្យា(Trade Secrets and Skilled Employee in Computer Industry)

ចំពោះព័ត៌មានណាដែលខ្លួនគិតថាជាព័ត៌មានសម្ងាត់ និងជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬជាការសម្ងាត់ពាណិជ្ជកម្ម។[15]

ទោះបីជានៅក្នុងប្រព័ន្ធច្បាប់ common law បានផ្តល់នូវការការពារដល់និយោជក ពីនិយោជិតដែលបានប្រើប្រាស់ព័ត៌មានពាណិជ្ជកម្ម ក្នុងគោលបំណងផ្ទុយពីផ្លូវច្បាប់យ៉ាងក៏ដោយ និយោជកចាំបាច់ត្រូវតែឱ្យនិយោជិតចុះហត្ថលេខា លើកិច្ចសន្យាស្តីពីការសម្ងាត់ មុនពេលចាប់ផ្តើមនូវការអនុវត្តការងារ ដើម្បីការពារនូវអត្ថប្រយោជន៍ផ្សេងៗរបស់ក្រុមហ៊ុនជាពិសេស ក្នុងករណីដែលនិយោជិតព្យាយាមលួចការសម្ងាត់ពាណិជ្ជកម្មក្នុងកំឡុងពេលឬក្រោយពេលធ្វើការ។ ជាងនេះទៅទៀត សមត្ថភាពរបស់និយោជកក្នុងការការពារការសម្ងាត់ពាណិជ្ជកម្មរបស់ខ្លួននឹងអាស្រ័យទៅលើកម្រិត ដែលចំណេះដឹង ឬព័ត៌មានមូលដ្ឋាន ដែលត្រូវបានដឹងដោយតតិយជន ឬអាចនិយាយបានថាដើម្បីទទួលបានការការពារការសម្ងាត់ពាណិជ្ជកម្ម ព័ត៌មានទាំងនោះត្រូវបានតែចាត់ទុកថាជាការសម្ងាត់។ ប្រសិនបើនិយោជកមិនប្រុងប្រយ័ត្នចំពោះអ្នកដែលមានសិទ្ធិទទួលបានព័ត៌មានដែលពួកគេអះអាងថាជា ការសម្ងាត់ពាណិជ្ជកម្មនោះ វានឹង មានភាពលំបាកក្នុងការ ប្រគល់សំណងណាមួយ ប្រសិនបើព័ត៌មាននោះមានភាពមិនត្រឹមត្រូវ។ ជាលទ្ធផល និយោជកគួរតែគ្រប់គ្រងយ៉ាងតឹងរឹង នូវសិទ្ធិដែលទទួលបានការសម្ងាត់ពាណិជ្ជកម្ម ហើយអនុញ្ញាតឱ្យនិយោជិតអាចទទួលយកបានព័ត៌មានសម្ងាត់នោះដោយឈរលើគោលការណ៍ចាំបាច់។ បញ្ហានេះអាចតម្រូវឱ្យនិយោជកតំឡើងនូវប្រព័ន្ធត្រួតពិនិត្យនិងរៀបចំឯកសារថ្មីឱ្យកាន់តែមានភាពប្រសើរឡើង។[16]

នៅក្នុងបណ្តាប្រទេសភាគច្រើន និយោជិតដាច់ខាតមិនត្រូវបង្ហាញអាកប្បកិរិយាណាមួយដែលបង្កឱ្យមានភាពអន្តរាយដល់ និយោជករបស់ខ្លួនក្នុងកំឡុងពេលធ្វើការនោះឡើយ។ បញ្ហានេះរួមបញ្ចូល ទាំងកាតព្វកិច្ចក្នុងការរក្សាព័ត៌មានសម្ងាត់ណាមួយរបស់ និយោជកផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តាប្រទេសនីមួយៗ បានអនុវត្តខុសៗគ្នាទៅតាមកម្រិតនៃច្បាប់ ក្នុងការការពារការសម្ងាត់ពាណិជ្ជកម្មរបស់ពួកគេ។

ចំពោះវិស័យកម្មសិទ្ធិបញ្ញាវិញ ត្រូវបានគេរកឃើញថា វាមានទម្រង់ផ្សេងៗគ្នាក្នុងការការពារនូវរាល់អត្ថប្រយោជន៍របស់ក្រុមហ៊ុន ដើម្បីធានាបានថាក្រុមហ៊ុននឹង ទទួលបានប្រយោជន៍ពីកម្លាំងពលកម្មរបស់និយោជិតខ្លួន ដែលចំនុចនេះក៏អាចបង្កជាបញ្ហាផងដែរ ។ ក្រុមហ៊ុនមិនមែនជាអ្នកច្នៃប្រឌិតនូវផលិតកម្មនោះទេ ផ្ទុយមកវិញ និយោជកដែលបានធ្វើការឱ្យពួកគេ ទើបជាអ្នកដែលបាន បង្កើតឧបករណ៍ថ្មី ឬចនារូបរាងផលិតផលថ្មីជាដើម។ លើសពីនេះទៅទៀត វាត្រូវបានគេកត់សម្គាល់ទៅតាមប្រទេសភាគច្រើនថា នៅពេល

---

[15] ការការពារការសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុនពីការបើកបង្ហាញ(Protectiong your Company's Trade Secrets From disclosure)

[16] ការការពារការសម្ងាត់ពាណិជ្ជកម្មក្រោយការចាកចេញរបស់និយោជិត(Protecting Trade Secrets when Employees Depart)

ដែលក្រុមហ៊ុនផ្តល់ការងារឱ្យនរណាម្នាក់ ដើម្បីបំពេញការងារឱ្យខ្លួនដែល ជាថ្នូរនឹងការបង់ប្រាក់ឈ្នួល នោះក្រុមហ៊ុននឹងក្លាយជាម្ចាស់ កម្មសិទ្ធិលើផលិតលកម្មដែលបានច្នៃប្រឌិតឡើង។ ដូច្នោះហើយ ការច្នៃប្រឌិតនិងការបង្កើតនូវផលិតកម្មដែលកើតឡើង ក្នុងអំឡុងពេលអនុវត្តការងារ ត្រូវបានគេចាត់ទុកថាជាកម្មសិទ្ធិរបស់និយោជក។[17]

## កថាខណ្ឌ២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងពេលអនុវត្តកិច្ចសន្យាការងារ

### ១. ការអប់រំនិយោជិតអំពីគោលការណ៍ការពារការសម្ងាត់ពាណិជ្ជកម្មនិងតាមដានលើការអនុវត្តរបស់និយោជិត

គោលដៅនៃគោលការណ៍ការពារការសម្ងាត់ពាណិជ្ជកម្មគឺ ធ្វើឱ្យមានផលលំបាកឬ មិនអាចទៅរួចសម្រាប់ដៃគូប្រជែងរបស់ខ្លួនក្នុងការ ទទួលបាននូវការសម្ងាត់ពាណិជ្ជកម្មរបស់ពួកគេ។ និយោជិតរបស់ក្រុមហ៊ុននីមួយៗ អាចជាការគំរាមកំហែងធ្ងន់ធ្ងរដល់គោលដៅនោះ ដោយសារ និយោជិតជារឿយៗ អាចបង្ហាញពីការសម្ងាត់ពាណិជ្ជកម្មដោយចៃដន្យ។ លើសពីនេះទៅទៀត និយោជិតដែលមិនស្មោះត្រង់អាចបង្ហាញពីការសម្ងាត់ពាណិជ្ជកម្មដើម្បីជាផលប្រយោជន៍ផ្ទាល់ខ្លួន ហើយនិយោជិតដែលបានបញ្ឈប់ពីការងារក៏អាចបង្ហាញពីការសម្ងាត់ពាណិជ្ជកម្មសម្រាប់ការសងសឹកផងដែរ។ ហេតុដូចនេះ និយោជកចាំបាច់ត្រូវអប់រំបុគ្គលិករបស់ខ្លួនអំពីសារៈសំខាន់ នៃការការពារការសម្ងាត់ពាណិជ្ជកម្ម ដើម្បីកាត់បន្ថយនូវហានិភ័យនានា ដែលអាចកើតមានឡើងប្រសិនបើពួកគេរំលោភនូវ នីតិវិធីនៃការសម្ងាត់ពាណិជ្ជកម្ម ឬក្នុងករណីដែលការសម្ងាត់ពាណិជ្ជកម្មត្រូវបានបើកបង្ហាញ។

ការការពារការសម្ងាត់ពាណិជ្ជកម្មគួរតែត្រូវបានពិភាក្សាជាមួយនិយោជិត មុនពេលពួកគេត្រូវបានជួលមកបំពេញការងារ និងពេលចាកចេញពីក្រុមហ៊ុន។ នៅក្នុងអំឡុងពេលសម្ភាសន៍ការងារ និយោជិតថ្មីគួរតែត្រូវបានផ្តល់ជូននូវព័ត៌មានដែលទាក់ទង នឹងច្បាប់ស្តីពីការការពារការសម្ងាត់ពាណិជ្ជកម្ម និងតម្រូវឱ្យនិយោជិតបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការការពារការសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ ម្យ៉ាងវិញទៀត និយោជកគួរតែបញ្ជាក់ឱ្យច្បាស់ចំពោះនិយោជិតថ្មីទាំងអស់ ថាការបង្ហាញការសម្ងាត់ពាណិជ្ជកម្មអាចបណ្តាលឱ្យមានការបញ្ឈប់ពីការងារ ហើយការរំលោភបំពាននូវកាតព្វកិច្ចក្នុងការកាពារការសម្ងាត់របស់ក្រុមហ៊ុននឹង ត្រូវបានចាត់ចែងទៅតាមនីតិវិធីផ្លូវច្បាប់។ និយោជិតដែលមានលទ្ធភាពទទួលបាននូវការសម្ងាត់ពាណិជ្ជកម្ម គួរតែតម្រូវឲ្យមានការចុះហត្ថលេខា ទៅលើកិច្ចសន្យារក្សាការសម្ងាត់ ដែលមានកាតព្វកិច្ចចាំបាច់ដើម្បីរក្សានូវរាល់ការសម្ងាត់ពាណិជ្ជកម្មក្រុមហ៊ុនរបស់ខ្លួន។[18]

[17] យុទ្ធសាស្ត្រ១០យ៉ាងក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម(Ten Strategies For Trade Secret Protection)

[18] ការអនុវត្តល្អបំផុតក្នុងការជួយនិយោជិដើម្បីការពារការសម្ងាត់ពាណិជ្ជកម្ម

ជុំវិញការការពារការសម្ងាត់ពាណិជ្ជកម្ម និយោជកក៏ត្រូវណែនាំឱ្យមានការប្រជុំ និងរៀបចំនូវបទបង្ហាញទៅដល់និយោជិត តាមកាលកំណត់ជាប្រចាំក្នុងគោលបំណងពង្រឹងលើគោលដៅ និងនីតិវិធីនៃការពារការសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ ការប្រជុំទាំងនេះគួរតែត្រូវបានធ្វើឡើងយ៉ាងហោច ណាស់ម្តងក្នុងមួយឆ្នាំ ហើយចាំបាច់ត្រូវតែមានការចូលរួមពីនិយោជក និងនិយោជិតគ្រប់រូប។ វត្តមាននៃការចូលរួមរបស់និយោជិត គឺមានភាពចាំបាច់ណាស់ក្នុងការអភិវឌ្ឍនិង ពង្រឹងការប្តេជ្ញាចិត្ត ក៏ដូចជាការប្រុងប្រយ័ត្នរបស់ពួកគេទៅលើការសម្ងាត់ផ្សេងៗរបស់ក្រុមហ៊ុន។

លើសពីនេះទៅទៀត មុនពេលនិយោជិតចាកចេញពីក្រុមហ៊ុន មិនថាក្នុងលក្ខខណ្ឌចូលនិវត្តន៍ ការទទួលយកការងារផ្សេងទៀត ឬដោយសារការបញ្ឈប់ពីការងារ វាចាំបាច់ត្រូវកំណត់ឱ្យមានការសំភាសន៍ជាមួយនិយោជិតមុនពេលចាកចេញ។ នៅក្នុងបទសម្ភាសន៍ និយោជកគួរតែរំលឹកដល់និយោជិត អំពីកាតព្វកិច្ចរបស់ខ្លួន ដែលប្រកបដោយក្រមសីលធម៌និងស្របតាមផ្លូវច្បាប់ ដើម្បីរក្សាការសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ ទោះបីជានិយោជិតបានចុះហត្ថលេខាលើ កិច្ចសន្យារក្សាការសម្ងាត់រួចរាល់ហើយយ៉ាងណាក្តី និយោជកគួរតែត្រួតពិនិត្យសារឡើងវិញនូវកិច្ចសន្យាទាំងនោះ។ លើសពីនេះទៀត និយោជកក៏ត្រូវណែនាំឱ្យនិយោជិតធ្វើការចុះហត្ថលេខាលើការទទួលស្គាល់និងយល់ស្របពីកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់របស់គាត់។ និយោជកគួរតែធ្វើការស្នើសុំឱ្យនិយោជិតរបស់ខ្លួន ប្រគល់មកវិញនូវកំណត់ត្រា និងឯកសារសំខាន់ទាំងអស់ដែលទាក់ទងនឹងព័ត៌មានក្រុមហ៊ុនទៅឱ្យនិយោជកវិញ។

**២.ការអនុវត្តតាមគោលនយោបាយក្រុមហ៊ុន**

ដើម្បីការពារការសម្ងាត់ពាណិជ្ជកម្ម និយោជកគួរតែអនុវត្តនូវគោលនយោបាយ ដែលទាក់ទងនឹងការចូលប្រើប្រើប្រាស់និងការបង្ហាញការសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុន នៅអំឡុងពេលចាប់ផ្តើមអនុវត្តការងារ។ និយោជកក៏ត្រូវពិចារណាឱ្យបានម៉ត់ចត់ក្នុងការផ្តល់ព័ត៌មានជាក់លាក់ណាមួយ ទៅដល់និយោជិតដែលមានលទ្ធភាពទទួលបាននូវព័ត៌មានសម្ងាត់របស់ក្រុមហ៊ុន។[19]

ជាការពិតណាស់ គោលការណ៍មួយមានប្រយោជន៍ និងមានប្រសិទ្ធិភាពលុះត្រាតែវាត្រូវបានអនុវត្តជាក់ស្តែង។ ចំនែក គោលការណ៍មួយចំនួនវិញ វាអាចនឹងមើលទៅល្អនៅលើក្រដាស ប៉ុន្តែវាមិនអាចដំណើរការបានឡើយ នៅពេលដែលត្រូវបានយកមកអនុវត្តជាក់ស្តែង។ ឧទាហរណ៍ បទប្បញ្ញត្តិស្តីពីការរក្សាការសម្ងាត់អាចផ្តល់ថា រាល់ការបង្ហាញព័ត៌មានសម្ងាត់ដល់ភាគីទីបីត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរដោយនិយោជក។ យ៉ាងណាមិញ ដំណើរការទាំងនេះមិនត្រូវបានអនុវត្តយ៉ាងរលូននោះទេ ដោយសារនិយោជកអាច

[19] ការអនុវត្តល្អបំផុតក្នុងការជួលនិយោជិតដើម្បីការពារការសម្ងាត់ពាណិជ្ជកម្ម(Best Practices in Hiring to Protect Trade Secrets)

នឹងមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការ ដើម្បីពិនិត្យទៅលើគ្រប់សកម្មភាពរបស់និយោជិតខ្លួន។ ហេតុដូចនេះ និយោជកត្រូវតែធានាថា និយោជិតរបស់ខ្លួននឹងអនុវត្តគោលការណ៍របស់ក្រុមហ៊ុន ឱ្យបានខ្ជាប់ខ្ជួនទាំងក្នុងទ្រឹស្តី ទាំងក្នុងការអនុវត្តជាក់ស្តែងហើយការអនុវត្តនោះត្រូវតែធ្វើឡើង ដោយមិនត្រូវរំខានដល់ប្រតិបត្តិការរបស់ក្រុមហ៊ុនឡើយ។

ក្រុមហ៊ុនក៏គួរតែចៀសវាងធ្វើសេចក្តីព្រាងគោលការណ៍ណាមួយដែលមានភាពច្របូកច្របល់ មិនសមហេតុសមផល ឬមិនសមនឹងផលិតផល ឬគំរូអាជីវកម្មរបស់ក្រុមហ៊ុន។ ប្រសិនបើ និយោជក និងនិយោជិតផ្ទាល់របស់ក្រុមហ៊ុនមិនយល់ពីគោលការណ៍ណាមួយរបស់ក្រុមហ៊ុននោះ គោលការណ៍ទាំងនោះមិនគួរត្រូវបានអនុវត្តទាំងមានភាពមិនច្បាស់លាស់ និងមិនមានភាពស៊ីចង្វាក់ឡើយ។

## ៣. ការកម្រិតសិទ្ធិនិយោជិតនៅក្នុងកិច្ចសន្យាការងារ

### ៣.១. សិទ្ធិក្នុងការទទួលបានព័ត៌មាន

មនុស្សដែលស្គាល់អាថ៌កំបាំងកាន់តែច្រើន វានឹងកាន់តែមានភាពពិបាកក្នុងការរក្សាព័ត៌មានសម្ងាត់។ ដើម្បីកាត់បន្ថយហានិភ័យ នៃការបង្ហាញការសម្ងាត់ពាណិជ្ជកម្ម ក្រុមហ៊ុនគួរតែកំណត់ចំនួននិយោជិតឱ្យបានច្បាស់លាស់ក្នុងការទទួលបានព័ត៌មាន។ ហេតុដូចនេះហើយ ដើម្បីការពារការសម្ងាត់ពាណិជ្ជកម្មឱ្យបានពេញលេញ និយោជកគួរតែកំណត់នូវចំនួននិយោជិតដែលមានលទ្ធភាពទទួលបាន ព័ត៌មាន ដើម្បីបំពេញភារកិច្ចរបស់ពួកគេសម្រាប់ក្រុមហ៊ុន។ លើសពីនេះទៀត ចំនួន និងលក្ខណៈប្រភេទនៃព័ត៌មានសម្ងាត់ពាណិជ្ជកម្មដែលបានបង្ហាញដល់និយោជិត គួរតែពឹងផ្អែកតែលើតម្រូវការនៃកាតព្វកិច្ចរបស់គាត់ក្នុង ការបំពេញការងារ។ ប្រសិនបើនិយោជិត អាចបំពេញការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាពជាមួយនឹងព័ត៌មានដែលបានកំណត់ដូច្នេះគាត់គួរតែទទួលបាននូវចំនួនព័ត៌មានតាមដែលត្រូវការតែប៉ុណ្ណោះ។

### ៣.២. សិទ្ធិក្នុងការប្រើប្រាស់ឧបករណ៍ក្រុមហ៊ុន

ការសម្ងាត់ពាណិជ្ជកម្ម មានភាពខុសគ្នាពីវត្ថុមានតម្លៃដទៃទៀត ដែលវាមិនមានទម្រង់ជាក់ស្តែងណាមួយក្នុងការកំណត់នូវវិធាននៃការការពារនោះទេ ប៉ុន្តែ វាមានតម្លៃចាំបាច់ណាស់ក្នុងការរក្សាព័ត៌មាន ឱ្យមានសុវត្ថិភាព។ ការសម្ងាត់ពាណិជ្ជកម្មអាចត្រូវបានរក្សាទុកនៅក្នុងឯកសារដែលបានបោះពុម្ព ស៊ីឌី ឬឌីវីឌីឯកសារកុំព្យូទ័រនិងសូម្បីតែនៅក្នុងការចងចាំរបស់អ្នក។ ដោយសារតែវាមានផលលំបាកក្នុងការអនុវត្ត ដើម្បីរក្សាការសម្ងាត់ពាណិជ្ជកម្មឱ្យនៅស្ថិតស្ថេរនោះ ការរក្សាការសម្ងាត់ ពាណិជ្ជកម្មឱ្យមានសុវត្ថិភាព ជាធម្មតាការសម្ងាត់ពាណិជ្ជកម្មនឹងត្រូវបានការពារតាមរយៈ ការកម្រិតនូវសិទ្ធិនិយោជកក្នុងអំឡុងពេលអនុវត្តការងារ។[20]

ការប្រើប្រាស់នូវបច្ចេកទេសដូចជាច្ចេកវិទ្យាព័ត៌មាន (អាយធី) មានភាពចាំបាច់ណាស់ដើម្បីការពារការ

[20] ការការពារការសម្ងាត់ពាណិជ្ជកម្មនៅតំបន់អាស៊ីអាគ្នេយ៍(Protecting Your Trade Secret in South-East Asia)

សម្ងាត់ពាណិជ្ជកម្មដែលបាន រក្សាទុកក្នុងឯកសារអេឡិចត្រូនិច នៅលើកុំព្យូទ័រ ឬម៉ាស៊ីនមេទិន្នន័យសំខាន់របស់ក្រុមហ៊ុន។ ច្បាប់មូលដ្ឋាននៃសន្តិសុខព័ត៌មានវិទ្យាគឺថាព័ត៌មានដែលកាន់តែមានតម្លៃ កាន់តែពិបាកចំណាយកាន់តែច្រើន និងមានភាពកាន់តែពិបាកក្នុងការការពារ។ និយោជកគួរតែធ្វើការពិគ្រោះជាមួយអ្នកជំនាញខាងសន្តិសុខព័ត៌មានវិទ្យា ដែលអាចជួយខ្លួនបានក្នុងការរចនា ប្រព័ន្ធសន្តិសុខព័ត៌មានវិទ្យាដែលមានតម្លៃទាប។ ទោះយ៉ាងណាក៏ដោយ មធ្យោបាយសាមញ្ញនិងមានតំលៃថោកនៃវិធានការសុវត្ថិភាពព័ត៌មានវិទ្យាអាចត្រូវបានប្រើប្រាស់ ដូចជាការប្រើលេខសម្ងាត់ត្រឹមត្រូវ កម្រិតនូវការទទួលបានព័ត៌មានពាណិជ្ជកម្ម និងលក្ខខណ្ឌពិសេសនៃការប្រើប្រាស់ព័ត៌មានជាដើម។ លើសពីនេះទៀត វាជាការសំខាន់ណាស់ដែលត្រូវមានគោលការណ៍បច្ចេកវិទ្យាជាលាយលក្ខណ៍អក្សរ ដែលអាចធានាបានថានិយោជិតរបស់អ្នកគោរពតាមគោលការណ៍បច្ចេកវិទ្យា។ ឧទាហរណ៍ វាមានភាពងាយស្រួលបំផុតសម្រាប់និយោជិតរបស់អ្នកផ្ញើអ៊ីមែលឯកសារសំខាន់ទៅកាន់ភាគីទីបី ឬផ្ទេរឯកសារដោយប្រើ ដ្រាយយូអេសប៊ី ឬស៊ីឌី ឬឌីវីឌីជាដើម។ ហេតុដូចនេះហើយនិយោជកគួរតែពិចារណា ក្នុងការរឹតត្បិតសមត្ថភាពរបស់និយោជិតរបស់ខ្លួនក្នុងការប្រើប្រាស់ ដ្រាយយូអេសប៊ី USB ស៊ីឌី ឬ ឌីវីឌីទាំងនោះ។ ជាពិសេសនិយោជិត គួរតែត្រូវបានផ្តល់ឱ្យនូវច្បាប់ចម្លងនៃគោលការណ៍បច្ចេកវិទ្យារបស់ក្រុមហ៊ុនខ្លួន ដែលបានសរសេរជាភាសាអង់គ្លេស និងភាសាក្នុងស្រុកដែលពាក់ព័ន្ធ (អាចជាឧបសម្ព័ន្ធនៃកិច្ចសន្យាការងាររបស់ពួកគេ) ហើយត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើ កិច្ចព្រមព្រៀងដែលពួកគេបានទទួល និងយល់ដឹងពីគោលការណ៍នេះ។

### ៣.៣. ការរក្សាការសម្ងាត់កុំព្យូទ័រ

ការសម្ងាត់ពាណិជ្ជកម្មនៅក្នុងឯកសារកុំព្យូទ័រ គឺសំខាន់ដូចទៅនឹងឯកសារទាំងឡាយណាដែលមានលក្ខណៈជា ឯកសារជាលាយលក្ខណ៍អក្សរផងដែរ។ ដូច្នេះ វាចាំបាច់ណាស់ក្នុងការគ្រប់គ្រងការចូលប្រើឯកសារកុំព្យូទ័រទាំងអស់ដែលមានផ្ទុកនូវការសម្ងាត់ពាណិជ្ជកម្ម។ ជាពិសេស ការចូលប្រើឯកសារកុំព្យូទ័រ ដែលមានផ្ទុកនូវ ការសម្ងាត់ពាណិជ្ជកម្មគួរតែត្រូវបានរឹតត្បិត ចំពោះនិយោជិតដែលមានលទ្ធភាពទទួលបានការអនុញ្ញាតក្នុងការប្រើប្រាស់នូវប្រព័ន្ធកុំព្យូទ័រ។ លើសពីនេះទៀត ខ្សែអាត់កុំព្យូទ័រ ឌីសនិងឧបករណ៍ផ្ទុកទិន្នន័យផ្សេងទៀតគួរតែត្រូវបានបំបែកចេញពីគ្នា និងផ្ទុកនូវកន្លែងផ្សេងគ្នា និងគ្រប់គ្រងតាមរបៀបដូចគ្នាទៅ នឹងឯកសារសម្ងាត់ដទៃទៀត។ក្នុងកាលៈទេសៈជាក់លាក់ណាមួយ និយោជកគួរតែណែនាំអំពីការរឹតត្បិតនូវសិទ្ធិក្នុងការចូលប្រើស្ថានីយកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រផ្សេងទៀតទៅដល់និយោជិតឱ្យយល់កាន់តែច្បាស់ផងដែរ។[21]

### ៤. ថេរវេលានៃការការពារការសម្ងាត់ពាណិជ្ជកម្ម

ការការពារការសម្ងាត់ពាណិជ្ជកម្ម មិនមានកំណត់ពេលវេលាច្បាស់លាស់ណាមួយ ដែលបានផ្តល់ថាវា

[21]ការការពារការសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុនពីការបើកបង្ហាញ

ត្រូវបានរក្សាទុកពីសាធារណៈទេ។ ផ្ទុយពីទម្រង់ដទៃទៀតនៃវិស័យកម្មសិទ្ធិបញ្ញា ដូចជាប៉ាតង់និងសិទ្ធិថតចម្លងដែលមានរយៈពេលកំណត់ ដោយឡែកការសម្ងាត់ពាណិជ្ជកម្មអាចទទួលបានការការពារគ្មានដែនកំណត់ដរាបណាការសម្ងាត់ពាណិជ្ជកម្មនៅតែជាការសម្ងាត់។

## ផ្នែកទី២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្រោយពេលបញ្ចប់កិច្ចសន្យាការងារ

សម្រាប់ផ្នែកទី២ នេះយើងនឹងធ្វើការសិក្សាទៅលើបីចំនុចធំៗ ដោយ រួមមាន ស្ថានភាពនៅពេលដែលកិច្ចសន្យាការងារបានបញ្ចប់ មធ្យោបាយការពារការសម្ងាត់ពាណិជ្ជកម្មក្រោយពេលបញ្ចប់កិច្ចសន្យាការងារ រួមទាំង កិច្ចសន្យានានាដែលត្រូវប្រើប្រាស់ក្រោយពេលបញ្ចប់កិច្ចសន្យាការងារ។

### កថាខណ្ឌ១៖ ស្ថានភាពនៅពេលដែលទំនាក់ទំនងការងារបានបញ្ចប់ដោយស្របច្បាប់

ការការពារការសម្ងាត់ពាណិជ្ជកម្ម បានបង្កើតឱ្យមានបញ្ហាក្នុងការសម្រុះសម្រួលគោលការណ៍ផ្ទុយគ្នានៅក្នុងការបង្កើតច្បាប់ជាអាទិ៍៖ សិទ្ធិរបស់ពាណិជ្ជករដែលត្រូវបានការពារប្រឆាំង នឹងការប្រកួតប្រជែងដោយអយុត្តិធម៌ផ្តើមចេញ ពីការលួចសម្ងាត់ពាណិជ្ជកម្ម និងសិទ្ធិរបស់បុគ្គលក្នុងការទទួលបានការងារមួយដែលសមស្រប និងដោយគ្មានការរំខានពីអ្នកដ៏ទៃ។ ជំហរនីមួយៗ បានតភ្ជាប់ខាងផ្នែកសេដ្ឋកិច្ចសង្គមជាមូលដ្ឋាន។ បច្ចុប្បន្នភាពយើងសង្កេតឃើញថាការវិត្តន៍ផ្នែកបច្ចេកវិទ្យាបានផ្តល់ អត្ថប្រយោជន៍យ៉ាងច្រើនដល់សង្គម ដូច្នេះបើគ្មានមធ្យោបាយការពារសម្ងាត់ពាណិជ្ជកម្មក្រោយពេលបញ្ចប់ការងារ ដើម្បីធានានូវកម្មសិទ្ធិរបស់និយោជកផ្តាច់មុខទេ នោះនិយោជកនឹងមិនអាចមានលទ្ធភាពឧបត្ថម្ភការស្រាវជ្រាវ ឬក៏អភិវឌ្ឍនូវវិធីសាស្ត្រនានា ក្នុងអាជីវកម្មបច្ចុប្បន្នបានទេ។

ម៉្យាងវិញទៀត ទម្រង់ណាមួយនៃការរឹតត្បិតក្រោយពេលបញ្ចប់ការងារបានកាត់បន្ថយភាពចល័តផ្នែកសេដ្ឋកិច្ចរបស់និយោជិត និង កំណត់សេរីភាពបុគ្គលក្នុងការបន្តមុខជំនាញវិជ្ជាជីវៈដែលខ្លួនពេញចិត្ត។ ហើយនិយោជកក៏ត្រូវបានរឹតត្បិតក្នុងការបង្កើនជំនាញ របស់គាត់នៅក្នុងឧស្សាហកម្មដែលគាត់មានផលិតភាពច្រើនដែរ។[22] ក្នុងន័យនេះ វាគួរតែចង្អុលបង្ហាញយ៉ាងច្បាស់ថា ចំណេះដឹងផ្នែកជំនាញ និង បទពិសោធន៍ទូទៅរបស់អតីតនិយោជិតមិនអាចត្រូវបានហាមឃាត់ទេ។ ដូច្នេះ និយោជិតដែលចាកចេញពីក្រុមហ៊ុន គួរតែត្រូវបានរំលឹកអំពីការទទួលខុសត្រូវជាបន្តរបស់ពួកគេ និង អំពីតម្រូវការក្នុងការប្រគល់ព័ត៌មាន ឬ ឯកសារណាមួយដែលអាចមានសម្ងាត់ពាណិជ្ជកម្ម។

### កថាខណ្ឌ២៖ ការការពារព័ត៌មានសម្ងាត់ និង ការសម្ងាត់ពាណិជ្ជកម្ម

ដោយផ្អែកលើប្រព័ន្ធច្បាប់ ការការពារការសម្ងាត់ពាណិជ្ជកម្មជាផ្នែកមួយយ៉ាងសកម្មនៃគំនិតទូទៅនៃ

[22] ច្បាប់នៃការការពារការសម្ងាត់ពាណិជ្ជកម្ម(The Legal Protection of Trade Secrets)

ការការពារប្រឆាំងនឹងការប្រកួតប្រជែងដោយអយុត្តិធម៌ ឬ ផ្អែកលើបទប្បញ្ញត្តិជាក់លាក់ ឬ ច្បាប់ស្តីពីការការពារព័ត៌មានសម្ងាត់។ ជាគោលគំនិត និយោជិតដែលពាក់ព័ន្ធនឹងការការពារសម្ងាត់ពាណិជ្ជកម្ម គួរតែឱ្យនិយោជិតទាំងអស់ដែលមានសិទ្ធិទទួលបានការសម្ងាត់ពាណិជ្ជកម្ម ចុះហត្ថលេខាលើកិច្ចសន្យារក្សាការសម្ងាត់ ឬ កិច្ចព្រមព្រៀងមិនបង្ហាញ។ ការធ្វើការចុះហត្ថលេខាលើ ប្រយោគដែលមានអត្ថន័យមិនមានការប្រកួតប្រជែង (non-competition clause) ក៏អាចមានភាពសមស្របផងដែរ ពោលគឺ ក្នុងករណីដែលនិយោជិតទទួលបានសិទ្ធិទទួល បាននូវសម្ងាត់ពាណិជ្ជកម្មរបស់ក្រុមហ៊ុន ដូចជា ប្រសិនបើពួកគេចាកចេញពីក្រុមហ៊ុនទៅចូលរួមជាមួយដៃគូប្រកួតប្រជែង នោះនិយោជកនឹង ទទួលរងការខូចខាតយ៉ាងខ្លាំង។ តាមនិយមន័យឃ្លាដែលមិនមែនជាការប្រកួតប្រជែង(Non-competition clause) គឺជាឃ្លាដែលនិយោជិតប្តេជ្ញាចិត្ត ថាតើពួកគេគួរតែចាកចេញពីក្រុមហ៊ុនដើម្បីមិនធ្វើការដោយឯករាជ្យ ឬ សម្រាប់និយោជកផ្សេងទៀតនៅក្នុងវិស័យតែមួយដូចគ្នានឹងអតីតនិយោជករបស់ពួកគេដែរ ឬ ទេ។[23]

កិច្ចសន្យាមិនប្រកួតប្រជែង បានផ្តល់ការការពារកាន់តែប្រសើរឡើងដល់និយោជក ដោយបង្កើតជារបាំងដល់សកម្មភាពនៃ ការប្រកួតប្រជែងរបស់អតីតនិយោជិតរបស់ខ្លួន ដែលបានរារាំងពួកគេពីការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម និង ព័ត៌មានសម្ងាត់របស់និយោជក។ ក្នុងចំណោមគោលការណ៍ផ្សេងទៀត និយោជិតត្រូវតែបង្ហាញថា ការរឹតត្បិតពីការប្រកួតប្រជែងគឺ សមហេតុផលក្នុងវិសាលភាព ឧទាហរណ៍ ដូចជា ទីតាំង និង ពេលវេលា។[24]

**១. អនុវត្តកិច្ចសន្យាមិនប្រកួតប្រជែង** ( Non-competition clause )

ដើម្បីអនុវត្តកិច្ចសន្យាដែលមិនប្រកួតប្រជែងជាមួយអតីតបុគ្គលិកក្រុមហ៊ុនត្រូវបង្ហាញ៣លក្ខខណ្ឌ៖

- កិច្ចសន្យាមិនចូលរួមប្រកួតប្រជែងត្រូវមានកម្មវត្ថុ នៅពេលដែលបានចុះហត្ថលេខា។
- កិច្ចសន្យាត្រូវការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់របស់និយោជក។
- កិច្ចសន្យាត្រូវមានលក្ខណៈសមហេតុសមផលក្នុងការការពារនិយោជកដោយមិនឲ្យមានបន្ទុកធ្ងន់ហួសហេតុលើសិទ្ធិរបស់និយោជិតក្នុងការរកចំណូល។

**១.១.កម្មវត្ថុ**

កិច្ចសន្យាជាទូទៅ ទាមទារឱ្យមានកម្មវត្ថុដើម្បីអនុវត្តកិច្ចសន្យា មានន័យថាភាគីជាប់សន្យាត្រូវតែ

[23] វិធីការពារការសម្ងាត់ពាណិជ្ជកម្មបន្ទាប់ពីការចាកចេញរបស់និយោជិត (How to Protect Trade Secrets Following the Departure of a key Employee)

[24] ការការពារការសម្ងាត់ពាណិជ្ជកម្មនិងព័តមានសម្ងាត់របស់និយោជក(Protection of Employers′ Trade Secrets and Confidential Information)

ទទួលបានអ្វីមួយដែលមានតម្លៃជាថ្នូរនឹងការសន្យា។ នៅពេលដែលកិច្ចសន្យា មិនចូលរួមប្រកួតប្រជែង ត្រូវបានចុះហត្ថលេខាមុនពេល និយោជិតចាប់ផ្ដើមការងារ ការងារនោះ នឹងចងភ្ជាប់ទៅ នឹងកម្មវត្ថុជាដាច់ខាត។ ប្រសិនបើនិយោជិតចុះហត្ថលេខា លើកិច្ចសន្យាបន្ទាប់ពីបានចាប់ផ្ដើមការងារ បានន័យថាការងារនោះមិនត្រូវបានចាត់ទុកថាជាសមស្របទៅនឹងកម្មវត្ថុនោះទេ ដោយទ្បែកនិយោជិតត្រូវទទួលបានអ្វីផ្សេងទៀត ដែលមានតំលៃជាថ្នូរនឹងកិច្ចសន្យា ដូចជាការតំឡើងឋានៈ ឬ អត្ថប្រយោជន៍សំខាន់ផ្សេងទៀត ដែលនឹងមិនមានប្រសិនបើនិយោជិតមិនបានចុះហត្ថលេខាលើកិច្ចសន្យានោះ។

**១.២. ការការពារផលប្រយោជន៍អាជីវកម្មស្របច្បាប់**

ផលប្រយោជន៍អាជីវកម្មស្របច្បាប់ ដែលអាចត្រូវបានការពារដោយកិច្ចសន្យា មិនចូលរួមប្រកួតប្រជែងរួមមាន (ក) ការទំនាក់ទំនងអតិថិជន និង (ខ) ព័ត៌មានសម្ងាត់។

**ក. ការទំនាក់ទំនងអតិថិជន**

ឆន្ទៈក្នុងការទំនាក់ទំនង អតិថិជនដែលត្រូវបានថែរក្សានិង អភិវឌ្ឍដោយនិយោជិតក្នុងកំឡុងពេលការងារគឺ ចាត់ទុកថាជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់និយោជក។ ដូច្នេះ និយោជកអាចប្រើកិច្ចព្រមព្រៀងមិនប្រកួតប្រជែង ដើម្បីរារាំងអតីតនិយោជិត ពីការប្រើទំនាក់ទំនងអតិថិជននេះ ដើម្បីប្រកួតប្រជែងជាមួយនឹងខ្លួន។ កិច្ចសន្យាមិនប្រកួតប្រជែងត្រូវបានអនុវត្តជាញឹកញាប់ ដើម្បីការពារអតីតនិយោជិត ពីការស្នើសុំអតីតអតិថិជនរបស់ខ្លួន ឱ្យទិញផលិតផល ឬ សេវាកម្មប្រកួតប្រជែងពីនិយោជកថ្មី។[25]

**ខ. ព័ត៌មានសម្ងាត់**

កិច្ចសន្យាប្រកួតប្រជែង ត្រូវបានអនុវត្តនៅពេលដែល "ព័ត៌មានសម្ងាត់" របស់អតីតនិយោជកអាចត្រូវបានប្រើ ឬ ត្រូវបានបង្ហាញ លើកលែងតែក្នុងករណីនិយោជិតត្រូវបានរារាំងមិនឱ្យប្រកួតប្រជែង។ និយោជកត្រូវតែបង្ហាញជាទូទៅថា ខ្លួនបានរក្សាព័ត៌មានជាការសម្ងាត់ពីសាធារណជន និង អ្នកប្រកួតប្រជែង ហើយព័ត៌មាននោះផ្ដល់ឱ្យនិយោជកនូវគុណសម្បត្តិប្រកួតប្រជែងខ្លះ ឬ ថាវាមានប្រយោជន៍សម្រាប់គូប្រជែង។ ព័ត៌មានសម្ងាត់គឺត្រូវតែជាព័ត៌មានមិនចេញពីប្រភពសាធារណៈឡើយ។ វាអាចទាក់ទង នឹង ផលិតផល ដូចជាផែនការទីផ្សារ ផែនការយុទ្ធសាស្ត្រ ទិន្នន័យលក់ និង ការព្យាករណ៍ និង ទិន្នន័យអតិថិជន។ ដូចគ្នានេះផងដែរ ព័ត៌មានសម្ងាត់ ត្រូវតែ ជាព័ត៌មានផ្សេងពី ជំនាញចំណេះដឹង និង បទពិសោធន៍ទូទៅរបស់និយោជិត ដែលទទួលបានពេលកំពុងអនុវត្តការងារ ដែលនិយោជិតអាចប្រើដោយសេរីក្នុងការប្រកួតប្រជែងជាមួយអតីតនិយោជក។ ប៉ុន្តែ

[25] វិធីការពារការសម្ងាត់ពាណិជ្ជកម្មបន្ទាប់ពីការចាកចេញរបស់និយោជិតក (How to Protect Trade Secrets Following the Departure of a key Employee)

ការបែកចែក រវាងព័ត៌មានសម្ងាត់របស់និយោជកនិង ចំណេះដឹងនិង បទពិសោធន៍ទូទៅរបស់និយោជិត ពិបាកនឹងគូសបង្ហាញ ហើយ វាត្រូវពឹងផ្អែកលើអង្គហេតុជាក់លាក់នៃករណីនីមួយៗ។ ដោយឡែក ទោះបីជាគ្មានកិច្ចសន្យាមិនប្រកួតប្រជែងក៏ដោយ និយោជិតមានកាតព្វកិច្ចដោយមិនត្រូវប្រើប្រាស់ ព័ត៌មានសម្ងាត់របស់អតីតនិយោជក ដើម្បីប្រកួតប្រជែងជាមួយនិយោជកនោះឡើយ។ ជាក់ស្តែង ការអនុវត្តកាតព្វកិច្ចមានភាពពិបាកលើកលែងតែក្នុងករណីមានកិច្ចសន្យាមិនចូលរួមប្រកួតប្រជែង ដែលជាមូលហេតុដែលនិយោជិតប្រើប្រាស់វាជាញឹកញាប់ក្នុងអំឡុង ឬ ក្រោយពេលបញ្ចប់កិច្ចសន្យាការងាររបស់និយោជិត។[26]

### ១.៣. ថេរវេលានៃកិច្ចសន្យាមិនប្រកួតប្រជែង

រយៈពេលសមហេតុផលសម្រាប់ការ អនុវត្តកិច្ចសន្យាមិនប្រកួតប្រជែង គឺអាស្រ័យទៅលើអង្គហេតុដែលជាក់លាក់។ ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដើម្បីការពារព័ត៌មានសម្ងាត់ នោះរយៈពេលរបស់វាមិនគួរលើសពីពេលវេលាដែលព័ត៌មានត្រូវបានគេរំពឹងថានឹងផុតអាយុកាលនោះទេ។ ក្នុងករណី បើកិច្ចសន្យាត្រូវបានរចនាឡើង ក្នុងគោលបំណងការពារទំនាក់ទំនងអតិថិជន នោះវាមិនគួរមានរយៈពេលយូរជាងរយៈពេលដែលចាំបាច់ ដើម្បីលុបចោលការផ្សារភ្ជាប់គ្នារវាងអតីតនិយោជិតនិង និយោជកដែលមាននៅក្នុងគំនិតរបស់អតិថិជនឡើយ។ ជាទូទៅ រយៈពេលមួយឆ្នាំ ហើយពេលខ្លះ ២ ឬ ៣ ឆ្នាំ គឺជារយៈពេលសមហេតុផលក្នុងការអនុវត្តកិច្ចសន្យាមិនប្រកួតប្រជែង។

### ១.៤. វិសាលភាពនៃកិច្ចព្រមព្រៀងមិនចូលរួមប្រកួតប្រជែង

តំបន់ដែលគ្របដណ្តប់ក្នុងកិច្ចសន្យាមិនប្រកួតប្រជែងគឺអាចចាត់ទុកថា សមហេតុផលគឺអាស្រ័យទៅលើ ស្ថានភាពជាក់លាក់ដែលត្រូវបានអនុវត្តផ្ទាល់ដោយនិយោជិត និង ផលប្រយោជន៍របស់និយោជកផងដែរ។ ជាទូទៅ ការអនុវត្តកិច្ចព្រមព្រៀងមិនប្រកួតប្រជែង មិនបានរារាំងអតីតនិយោជិត ពីការធ្វើការនៅក្នុងតំបន់ដែលអតីតនិយោជកមិនធ្វើជំនួញឡើយ។[27]

## ២. កិច្ចសន្យាដើម្បីប្រគល់ឯកសារ និង ប្រព័ន្ធផ្សព្វផ្សាយសម្ងាត់

តាមនីតិវិធីជាក់ស្តែង ដើម្បីជួយបង្កើតអត្ថិភាពនៃ "ការសម្ងាត់ពាណិជ្ជកម្ម" និង ដើម្បីការពារប្រឆាំងនឹងការបង្ហាញនូវអ្វីដែលពួកគេមិនចង់បង្ហាញ និយោជិតគួរមានទំនួលខុសត្រូវក្នុងការប្រគល់ សម្ភារៈសម្ងាត់ទាំងអស់របស់និយោជកមកវិញ។ កិច្ចសន្យាការងារ ឬកិច្ចសន្យាជាលាយលក្ខណ៍អក្សរផ្សេងទៀតដូចជាកិច្ច

[26] វិធីការពារការសម្ងាត់ពាណិជ្ជកម្មបន្ទាប់ពីការចាកចេញរបស់និយោជិត

[27] កិច្ចព្រមព្រៀងដោយបង្ខំក្នុងការមិនប្រកួតប្រជែង

សន្យារក្សាការសម្ងាត់គួរតែតម្រូវឱ្យនិយោជិតវិលត្រឡប់មកវិញ នៅពេលបញ្ចប់ទំនាក់ទំនងការងារ ឯកសារសៀវភៅកំណត់ត្រា និង ប្រព័ន្ធផ្ទុកព័ត៌មានជាដើមនៅពេលបញ្ចប់ទំនាក់ទំនងការងារ ។[28]

[28] ការការពារការសម្ងាត់ពាណិជ្ជកម្មដោយប្រើប្រាស់កិច្ចសន្យាការងារ (Protecting Trade Secrets Using Employment Agreement)

# ជំពូកទី៣៖យន្តការការពារការសម្រាត់ពាណិជ្ជកម្មក្នុងកិច្ចសន្យាពាណិជ្ជកម្ម

# ជំពូកទី៣៖យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងកិច្ចសន្យាពាណិជ្ជកម្ម

កិច្ចសន្យាពាណិជ្ជកម្ម គឺជាកិច្ចសន្យាដែលធ្វើដោយការព្រមព្រៀងរវាងពាណិជ្ជករនិង ពាណិជ្ជករ ដែលធ្វើការលក់អាជីវកម្ម ឬរួមបញ្ចូលអាជីវកម្ម ដែលស្ថិតនៅក្នុងវង្វង់សកម្មភាពពាណិជ្ជកម្មនានា។ សកម្មភាពពាណិជ្ជកម្មទាំងនេះ ត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដើម្បីគ្របដណ្តប់ទៅលើកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ។ ធុរៈកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មជាអាទិ៍មានដូចជាកិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ការផ្លាស់ប្តូរទំនិញ សេវាកម្មផ្សេងៗ កិច្ចព្រមព្រៀងនៃការបែងចែកតំណាង ឬទីតាំងភ្នាក់ងារពាណិជ្ជកម្ម ការទិញលក់គណនីក្រុមហ៊ុន ការជួលទីតាំងឬសម្ភារៈវត្ថុ ការងារស្ថាបនាការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ និងធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចម្រុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្មដឹកជញ្ជូនទំនិញ ឬអ្នកធ្វើដំណើរតាមផ្លូវអាកាស ព្រមទាំងអ្នកធ្វើដំណើរតាមផ្លូវទឹក និងផ្លូវអាកាស។[29] កិច្ចសន្យាពាណិជ្ជកម្មធ្វើឡើងនៅពេលដែលសំណើ និងស្ទីការ មានលក្ខណៈត្រូវគ្នា។ កិច្ចសន្យាពាណិជ្ជកម្មអាចធ្វើជាការលាយលក្ខណ៍អក្សរដែលមានហត្ថលេខាគូរភាគី ឬដោយមធ្យោបាយ ដូចជាមធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលទទួលស្គាល់ដោយច្បាប់ ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីកិច្ចសន្យា ឬដោយលិខិតយថាភូតជាដើម។[30]

ប៉ុន្តែទទឹមនឹងនេះ យើងឃើញថា មុននឹងមានការកកើតនៃកិច្ចសន្យាពាណិជ្ជកម្ម ពាណិជ្ជករ តែងធ្វើការបង្កើតនូវកិច្ចសន្យាគោលមួយ ដែលជាកិច្ចសន្យារក្សានូវការសម្ងាត់នានានៃពាណិជ្ជកម្ម។ កិច្ចសន្យាការរក្សាការសម្ងាត់ពាណិជ្ជកម្មនេះ បង្កើតឡើងដោយគូរភាគីនៃពាណិជ្ជករ ក្នុងគោលបំណងការពារនូវការសម្ងាត់របស់ពាណិជ្ជកម្ម ដើម្បីជាប្រយោជន៍ និងដើម្បីទប់ស្កាត់នូវការកើតមាននូវការប្រកួតប្រជែងមិនស្មោះត្រង់ដោយការបែកធ្លាយការសម្ងាត់ពាណិជ្ជកម្ម។ កិច្ចសន្យានេះត្រូវបានគេធ្វើឡើងនៅក្នុងដំណាក់កាលនៃការចរចារបស់ ដៃគូភាគីពាណិជ្ជកម្ម។

## ផ្នែកទី១៖យន្តការនៃការពារការសម្ងាត់ពាណិជ្ជកម្មមុនពេលបង្កើតកិច្ចសន្យាកិច្ចសន្យាពាណិជ្ជកម្ម

ដើម្បីជាការការពារផលប្រយោជន៍របស់ខ្លួន ពាណិជ្ជករនីមួយៗដែលនៅក្នុងករណីជាការចរចាធុរៈកិច្ចដែលជាប្រភេទពាណិជ្ជកម្ម បានបង្កើតនូវកិច្ចសន្យាគោលមួយជាមួយនិងដៃគូរពាណិជ្ជកររបស់ខ្លួនដែលកំពុងធ្វើការចរចា និងវិនិច្ឆ័យក្នុងការសហការទៅលើអាជីវកម្មរបស់ខ្លួន គឺជាកិច្ចសន្យារក្សាការសម្ងាត់ពាណិជ្ជកម្ម។

[29] មាត្រា៣ នៃសេចក្តីព្រាងច្បាប់ស្តីពីច្បាប់កិច្ចសន្យាណិជ្ជកម្មឆ្នាំ២០០៩

[30] មាត្រា៦ នៃសេចក្តីព្រាងច្បាប់ស្តីពីច្បាប់កិច្ចសន្យាណិជ្ជកម្មឆ្នាំ២០០៩

កិច្ចសន្យារក្សាការសម្ងាត់ពាណិជ្ជកម្ម ដែលធ្វើឡើងមុនពេលការកើតឡើងនូវកិច្ចសន្យាពាណិជ្ជកម្មកើតមានគឺគូរភាគីពាណិជ្ជករ ធ្វើការព្រមព្រៀងគ្នាដោយមិនបញ្ចេញនូវព័ត៌មាន ទិន្នន័យ រូបមន្ត វត្ថុធាតុដើម គំរូ គម្រោងការ វិធីសាស្ត្រផ្សេងៗ ដែលគេចាត់ទុកជាព័ត៌មានសម្ងាត់ពាណិជ្ជកម្មដែលមានតម្លៃជាផលប្រយោជន៍។ ពេលប្រសិនបើក្រោយការចរចា ទទួលបានភាពជោគជ័យ ដោយសហការគ្នា ឬមិនបទទួលបានភាពជោគជ័យដោយសម្រេចចិត្តមិនសហការគ្នា ក៏ដោយក៏ភាគីនៃកិច្ចសន្យាមិនអាចបង្ហើបព័ត៌មានណាមួយដែលទាក់ទង់ទៅនឹងពាណិជ្ជកម្មដែលបានកំណត់នៅក្នុងកិច្ចសន្យាទៅឱ្យតតិយជនណាមួយដឹងឡើង។

**កថាខណ្ឌ១៖ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់** NDA( Non-disclosure Agreement )

កិច្ចសន្យារក្សាព័ត៌មានសម្ងាត់ គឺជាកិច្ចព្រមព្រៀងដែលអនុវត្តបាន ដោយស្របច្បាប់ដែលបង្កើតការសម្ងាត់រវាងគូរភាគីទាំងពីរ គឺម្ខាងជាម្ចាស់នៃព័ត៌មានសម្ងាត់ និងម្ខាងទៀតជាអ្នកដែលនិងទទួលបានព័ត៌មានសម្ងាត់។ តាមរយៈការចុះហត្ថលេខាទៅ លើកិច្ចសន្យារក្សាព័ត៌មានសម្ងាត់ អ្នកចូលរួមយល់ព្រមយល់ព្រមការពារព័ត៌មានសម្ងាត់ដែលបានចែករំលែកនៃគូរភាគីទាំងពីរ ហេតុដូចនេះភាគីមិនអាចធ្វើការបង្ហាញ បញ្ចេញនូវព័ត៌មានសម្ងាត់នោះឡើង ព្រមទាំងមិនអាចធ្វើការចម្លង ឬកែប្រែព័ត៌មានសម្ងាត់នោះដោយគ្មានការយល់ព្រមពីម្ចាស់ព័ត៌មានសម្ងាត់នោះឡើយ។ ការបង្កើតនូវកិច្ចសន្យារក្សាព័ត៌មានសម្ងាត់ ជាទម្រង់បែបបទដែលអាចជួយអ្នកឱ្យជៀសវាង បញ្ហាជាច្រើនក្នុងនាមជាម្ចាស់អាជីវកម្ម។[31] បើគ្មានកិច្ចព្រមព្រៀងមិនបង្ហាញព័ត៌មាននោះទេ ព័ត៌មានសម្ងាត់របស់អ្នក អាចត្រូវបានបង្ហាញជាសាធារណៈ ឬ បើមិនដូច្នេះទេ ត្រូវបានប្រើដោយនិយោជិត អ្នកលក់អតិថិជន ឬអ្នកផ្សេងទៀតដែលអ្នកចែករំលែកជាមួយ។ កិច្ចព្រមព្រៀងមិនបង្ហាញព័ត៌មានអនុញ្ញាតឱ្យអ្នកទទួលព័ត៌មាន ដែលមានកម្មសិទ្ធិរបស់អ្នកដឹងថាអ្នករំពឹងថានឹងមានការសម្ងាត់ហើយវាអនុញ្ញាតឱ្យអ្នកចាត់វិធានការតាមច្បាប់ប្រសិនបើកិច្ចសន្យាត្រូវបានរំលោភបំពាន។

❖ ព័ត៌មានសម្ងាត់ជាធម្មតាអាចរួមបញ្ចូលធាតុដូចជា៖

- កំណត់ត្រាអាជីវកម្មនិងផែនការ
- ព័ត៌មានហិរញ្ញវត្ថុ
- អាថ៌កំបាំងពាណិជ្ជកម្មនិងការស្រាវជ្រាវដើម
- គំនិតច្នៃប្រឌិតនិងគំនិតផលិតផល
- ទិន្នន័យបច្ចេកទេសឬការរចនា
- ព័ត៌មានលម្អិតអំពីកិច្ចសន្យាឬបញ្ជីដៃគូ
- ការលក់នាំមុខនិងព័ត៌មានលំអិតអតិថិជនឬអតិថិជន
- រចនាសម្ព័ន្ធតម្លៃឬបញ្ចុះតម្លៃ

[31] កិច្ចសន្យារក្សាការសម្ងាត់(Non-Disclosure Agreement)

❖ ព័ត៌មានសម្ងាត់ជាទូទៅមិនរាប់បញ្ចូលៈ

- ព័ត៌មានដែលជាចំណេះដឹងសាធារណៈរួចហើយ
- ព័ត៌មានទទួលបានដោយស្របច្បាប់ពីភាគីទីបី
- ព័ត៌មានដែលត្រូវបានបង្កើតឡើងដោយឯករាជ្យឬរកឃើញដោយអ្នកទទួល
- ព័ត៌មានដែលម្ចាស់បានផ្តល់ការយល់ព្រមឱ្យអ្នកទទួលរួចហើយដើម្បីបង្ហាញ
- ពត៌មានផ្សេងទៀតដែលភាគីទាំងពីរយល់ព្រមជាលាយលក្ខណ៍អក្សរគឺមិនមានការសម្ងាត់ទេ។[32]

ជាទូទៅ រយៈពេលត្រូវបានកំណត់ដរាបណាព័ត៌មានសម្ងាត់ត្រូវបានចាត់ទុកថាមានប្រយោជន៍។ ដោយផ្អែកលើលក្ខណៈនៃព័ត៌មាន ដែលត្រូវបានផ្លាស់ប្តូរចំនួនពេលវេលាខ្លីឬសមហេតុផលដូចជាមួយឆ្នាំអាច ត្រូវបានអនុវត្តតាមច្បាប់។ ទោះយ៉ាងណាក៏ដោយ ព័ត៌មានដូចជាអាថ៌កំបាំងពាណិជ្ជកម្ម អាចនឹងទទួលបាន អត្ថប្រយោជន៍ពីការរក្សាការសម្ងាត់ក្នុងរយៈពេលមិនកំណត់។

**១.ការបង្កើតកិច្ចសន្យារក្សាព័ត៌មានសម្ងាត់**(NDA)

**១.១.លក្ខខណ្ឌគ្រឹះ**

**ក.ការព្រមព្រៀង**

នៅពេលបុគ្គលពីរ ឬច្រើននាក់មានបំណងចង់បង្កើតកិច្ចសន្យា ត្រូវតែមានការព្រមព្រៀងគ្នាជាមុន ពោលគឺត្រូវមាន ជំនួបនៃឆន្ទៈដែលនាំឱ្យកិច្ចសន្យាមានសុពលភាព នេះជាគោលការណ៍ដែលមានចែងក្នុង មាត្រា៣៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។[33] ម្យ៉ាងវិញទៀតការព្រមព្រៀងមួយដែលពុំមានគុណវិបត្តិនោះ គឺ ត្រូវតែជាការព្រមព្រៀងដែលជៀសវាងវិការៈ។

**ក.១.សំណើ**

ដំណាក់កាលដំបូងនៃការបង្កើតកិច្ចសន្យាគឺត្រូវតែមានភាគីម្ខាងចង់សម្តែងឆន្ទៈ បង្កើតនូវកាតព្វកិច្ច ចំពោះភាគីម្ខាងទៀត ហើយការសម្តែងឆន្ទៈនោះហៅថា "សំណើ"។ សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើ ឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណី ដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះ សំណើនោះ។ សំណើមានសុពលភាពទៅបានលុះត្រាតែអ្នកធ្វើសំណើនោះធានាបានថា ប្រសិនបើមានស្វីការ មកនោះនឹងនាំឱ្យកើតកិច្ចសន្យា។ ហេតុនេះ អ្នកធ្វើសំណើត្រូវតែបង្ហាញពីបំណងរបស់ខ្លួនយ៉ាងពិតប្រាកដក្នុង ការភ្ជាប់ខ្លួនជាមួយកាតព្វកិច្ចដែលនឹងកើតឡើង។ ទន្ទឹមនឹងនេះសំណើត្រូវមានអានុភាពនៅពេលដែលសំណើ នោះបានមកដល់ភាគីម្ខាងទៀត។ ពីព្រោះភាគីម្ខាងទៀតមិនអាចធ្វើស្វីការបានឡើយ ប្រសិនបើមិនបានទទួល

[32]កិច្ចសន្យារក្សាការសម្ងាត់ (non-Disclosure agreement)

[33] មាត្រា៣៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដំណឹងការមកដល់នៃសំណើនោះទេ។ ប៉ុន្តែប្រសិនបើដំណឹងនៃការដកសំណើវិញដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬមុនពេលសំណើដល់នោះអានុភាពនៃសំណើមិនត្រូវកើតឡើយ។ សំណើក៏ត្រូវបានបែងចែកជាសំណើដែលកំណត់អំឡុងពេលសម្រាប់ធ្វើស្វីការ និងសំណើគ្មានកំណត់អំឡុងពេលសម្រាប់ធ្វើអ្វីការ។[34]

**ក.២. ស្វីការ**

នៅពេលមានការស្នើសុំបង្កើតកិច្ចសន្យាហើយភាគីម្ខាងទៀតដែលព្រមទទួលសំណើហើយ ភាគីនោះនឹងបង្ហាញឆន្ទៈក្នុងការបង្កើតកិច្ចសន្យា ហើយការបង្ហាញឆន្ទៈតបនោះហៅថា"ស្វីការ" ។ ស្វីការគឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។ ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការមកដល់ឬមុនពេលធ្វើស្វីការដល់នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ។ស្វីការមានសុពលភាពត្រូវតែធ្វើឡើងដោយមានការកែប្រែលក្ខខណ្ឌណាមួយនៃសំណើ ប៉ុន្តែប្រសិនបើស្វីការដែលមានការកែប្រែលក្ខខណ្ឌដែលមិននាំឱ្យខុសពីសារជាតុនៃសំណើទេ ហើយអ្នកស្នើមិនតវ៉ាភ្លាមទេ សំណើនោះនៅតែមានសុពលភាព។ ផ្ទុយទៅវិញប្រសិនស្វីការមានការកែប្រែនូវលក្ខខណ្ឌសារជាតុនៃសំណើ ស្វីការនោះគ្មានសុពលភាពទេ ហើយនឹងក្លាយជាសំណើថ្មី ។

**ខ.ការព្រមព្រៀងដោយវៀសវាងវិការៈ**

ក្រោយមានជំនួបនៃឆន្ទៈ គឺនឹងនាំឱ្យមានអត្ថិភាពនៃកិច្ចសន្យាកើតឡើង។ ប៉ុន្តែប្រសិនបើមានភាគីណាម្ខាងបានបង្ហាញឆន្ទៈដោយមានគុណវិបត្តិប្រាសចាកពីភាពប្រក្រតីនោះ គឺអ្នកបង្ហាញឆន្ទៈដែលមានគុណវិបត្តិមានសិទ្ធិលុបចោលកិច្ចសន្យា។ ដូចនេះការព្រមព្រៀងត្រូវ តែគ្មានគុណវិបត្តិពោល គឺជៀសវាងនូវវិការៈទាំងឡាយមានដូចជា ៖ ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការគម្រាមកំហែង និងអំពើកេងយកចំណេញហួសហេតុ។

- ការភាន់ច្រឡំ៖ការភាន់ច្រឡំ គឺសកម្មភាពភាគីនៃកិច្ចសន្យាបានបង្ហាញឆន្ទៈផ្ទុយពីបំណងរបស់ខ្លួន ហើយប្រសិនបើភាគីនោះបានដឹងពីការភាន់ច្រឡំនោះ នឹងមិននាំឱ្យមានការព្រមព្រៀងឡើយ។ ការភាន់ច្រឡំអាចជា ការភាន់ច្រឡំឯកតោភាគី (ភាគីតែម្ខាងភាន់ច្រឡំ) ឬឧភតោភាគី"(ភាគីទាំងពីរភាន់ច្រឡំ)។ ការភាន់ច្រឡំឯកតោភាគី គឺសកម្មភាពដែលភាគីម្ខាងភាន់ច្រឡំលើចំណុចដែលសំខាន់ៗ នៃកិច្ចសន្យា ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ ហើយភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពបានដឹងពីចំណុចសំខាន់នោះដែរ។ ករណីនេះភាគីដែលបង្ហាញឆន្ទៈដែលមានការភាន់ច្រឡំនោះមានសិទ្ធិលុប

[34] មាត្រា៣៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ចោលកិច្ចសន្យាបាន។ ចំណែកឯការភាន់ច្រឡំឧភតោភាគី គឺជាសកម្មភាពដែលភាគីទាំងសងខាងមានការភាន់ច្រឡំ អំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬចំណុចនៃកិច្ចសន្យា ដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងទៀតមិនមានលទ្ធភាពអាចដឹងពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលកិច្ចសន្យាបានដែរ។[35]

- ការឆបោកៈការឆបោក គឺជាទង្វើរបស់ភាគីណាមួយ ឬតតិយជន មានចេតនាទុច្ចរិត ដោយប្រើនូវឧបាយកល បញ្ឆោត ឬមធ្យោបាយណាមួយ ក្នុងគោលបំណងដើម្បីឱ្យភាគីម្ខាងទៀតបង្ហាញឆន្ទៈតាមខ្លួនចង់បាន។ ដូចនេះ ការបង្ហាញឆន្ទៈដោយមានការឆបោកគឺជាការបង្ហាញឆន្ទៈមានវិការៈហើយភាគីរងគ្រោះនោះមានសិទ្ធិលុបចោលកិច្ចសន្យា។ ប៉ុន្តែក្នុងករណីដែលការបង្ហាញឆន្ទៈ បានធ្វើឡើងដោយសារតែការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈដោយមានការឆបោកនោះអាចលុបចោលនូវកិច្ចសន្យាបាន លុះត្រាតែ ភាគីម្ខាងទៀតនៃកិច្ចសន្យា បានដឹង ឬអាចដឹងពីការឆបោក។[36]
- ព័ត៌មានមិនពិតៈ ព័ត៌មានមិនពិតគឺជាការធ្វើកិច្ចសន្យាដោយមានភាគីម្ខាងបានលើកឡើងនូវហេតុណាមួយខុសពីការពិតហើយ ភាគីម្ខាងទៀតនោះបានបង្ហាញឆន្ទៈដោយជឿជាក់ថាហេតុនោះជាការពិត។ ប៉ុន្តែប្រសិនបើ ភាគីដែលបង្ហាញឆន្ទៈដោយសារព័ត៌មានមិនពិតនោះដឹងពីហេតុមិនពិតនោះក៏ខ្លួនមិនបង្ហាញឆន្ទៈដែរ។ ករណីនេះពិបាកក្នុងការបែងចែកឱ្យដាច់រវាងការឆបោក និងព័ត៌មានមិនពិត។ ប៉ុន្តែការឆបោកគឺមានការប្រើប្រាស់ឧបាយកលណាមួយ ចំណែកព័ត៌មានមិនពិតវិញដែលមាន លក្ខណៈជាសេចក្តីថ្លែងនូវហេតុមិនពិតអំពីខ្លឹមសារដែលពិតមួយទៅកាន់ភាគីម្ខាងទៀតដើម្បីឱ្យភាគីនោះបង្ហាញឆន្ទៈ ។[37]
- ការរំលោភបំពានលើស្ថានភាពៈ ការរំលោភបំពានលើស្ថានភាពមានន័យថា ការធ្វើកិច្ចសន្យាមួយដែលភាគីទាំងពី រស្ថិតក្នុងស្ថានភាពណាមួយមិនស្មើគ្នាដែលផ្ទុយពីគោលការណ៍សមភាព។ ការរំលោភបំពានលើស្ថានភាពមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៣៤៩ ប្បញ្ញត្តិថា ៖ "នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យា បានប្រើឋានៈអាទិភាពជាងភាគីម្ខាងទៀតនៃកិច្ចសន្យាខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬបានប្រើស្ថានភាពផ្សេងទៀត(ដោយមិនត្រឹមត្រូវ)ដែលភាគីម្ខាងទៀត

[35] មាត្រា៣៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[36] មាត្រា៣៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[37] មាត្រា៣៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។[38]

- ការគម្រាមកំហែង៖ ការគម្រាមកំហែងគឺស្ថានភាពមួយ ដែលបុគ្គលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬតតិយជន។ ការគម្រាមកំហែងអាចធ្វើតាមរយៈពាក្យសំដីហឹង្សា និងរូបភាពនៃការគម្រាមកំហែងដទៃទៀត ក្នុងគោលបំណងឱ្យភាគីម្ខាងទៀតបង្ហាញឆន្ទៈតាមដែលខ្លួនចង់បាន។[39]
- អំពើកេងយកចំណេញហួសហេតុ៖ ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬភាពល្ងង់ខ្លៅ ឬការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ដោយករណីនេះច្រើនកើតមានឡើងផងដែរ។[40]

**គ.ថេរវេលា**

ក្រៅពីកំណត់កម្មវត្ថុនៃកិច្ចសន្យាឱ្យបានជាក់លាក់ ភាគីក៏ត្រូវតែដឹងឱ្យច្បាស់ពីវិធីអនុវត្តតាវកាលិក និងរយៈពេលនៃការអនុវត្តឱ្យបានច្បាស់លាស់ផងដែរ។ ជាគោលការណ៍ទូទៅនៃការបង្កើត កិច្ចសន្យាមិនទាមទារឱ្យមានការកំណត់ថិរវេលាទេ ព្រោះជាសេរីភាពនៃឆន្ទៈបុគ្គលឯកជន។ តែជាអញ្ញត្រកម្មកិច្ចសន្យាពិសេសមួយចំនួន តម្រូវឱ្យភាគីកំណត់នូវអំឡុងពេល នៃកិច្ចសន្យាឱ្យបានច្បាស់លាស់ ព្រោះការកំណត់បែបនេះនាំឱ្យយើងធ្វើចំណាត់ថ្នាក់ បានថាវាជាប្រភេទនៃកិច្ចសន្យាណាមួយ។ ជាក់ស្តែងរយៈពេលនៃ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់ បង្ហាញថា តើកិច្ចសន្យារក្សាព័ត៌មានសម្ងាត់ រយៈពេលប៉ុន្មានដើម្បីឱ្យសកម្ម។ ជាធម្មតាការប្រើប្រាស់ ស្តង់ដារសម្រាប់ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់ មានចាប់ពី ១ ឆ្នាំទៅ ៥ ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយទាំងអស់នេះអាស្រ័យលើលក្ខណៈនៃ ប្រតិបត្តិការឬលក្ខខណ្ឌទីផ្សារ។ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់ និងធ្វើឡើងកំណត់ចំនួនពេលវេលាសមស្របដើម្បី ការពារផលប្រយោជន៍របស់ភាគីដែលបានបង្ហាញ។ ការកំណត់ពេលវេលាសមស្របសម្រាប់ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់របស់អ្នក គឺមានសារៈសំខាន់ជាពិសេសប្រសិនបើជម្លោះកើតឡើង។

ប្រសិនបើពេលវេលាមិនត្រូវបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងភាគីនានាអាចសន្និដ្ឋានថា កិច្ចសន្យារក្សាព័ត៌មានសម្ងាត់ នឹងមានប្រសិទ្ធិភាពដោយគ្មានកំណត់។ ដូចគ្នានេះផងដែរ ការសម្ងាត់នឹងផុតកំណត់ដោយស្វ័យប្រវត្តិនៅពេលព័ត៌មានសម្ងាត់នោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ទោះបីជាការកំណត់នៅក្នុង

[38] មាត្រា៣៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[39] មាត្រា៣៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[40] មាត្រា៣៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កិច្ចសន្យារក្សាព័ត៌មានសម្ងាត់ ជាពេលវេលាដែលគ្មានកំណត់មួយក៏ដោយ ប្រសិនបើនៅពេលដែលព័ត៌មាននេះបានក្លាយជាសាធារណៈ លក្ខខណ្ឌនៃការរក្សាការសម្ងាត់ទៅលើព័ត៌មាននោះ នឹងលែងមានទៀត។[41]

ការសម្ងាត់ដែលកើតមានឡើងក្នុងអំឡុងពេលក្រោយនៃការចុះកិច្ចសន្យារក្សាព័ត៌មានសម្ងាត់ នោះមិនអាចចាត់ទុកជាព័ត៌មានសម្ងាត់ដែលគូរភាគីនៃកិច្ចសន្យាមានតួនាទីនិងរក្សាព័ត៌មាននោះទេ។

**២.ការអនុវត្តកិច្ចសន្យារក្សាព័ត៌មានសម្ងាត់**

ការអនុវត្តនៃ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់ កើតមានឡើងក្រោយពេលគូរភាគីនៃ កិច្ចសន្យារក្សាព័ត៌មានសម្ងាត់នេះ បានធ្វើការព្រមព្រៀងគ្នាទៅលើលក្ខខណ្ឌដែលបានកំណត់ទាំងអស់នៅក្នុងកិច្ចសន្យាដែលមានពិភាក្សានឹងកែប្រែរួច សម្រេចយកចំណុចណាមួយដែលគូរភាគីទទួលយកបានទាំងសងខាងយល់ព្រម និងធ្វើការព្រមព្រៀងបង្កើតនូវកិច្ចសន្យារក្សាព័ត៌មានសម្ងាត់នេះឡើង។

**២.១.ករណីយកិច្ចនៃកិច្ចសន្យារក្សាព័ត៌មានសម្ងាត់**

យើងឃើញថាបន្ទាប់ពី មានការព្រមព្រៀងគ្នាទៅលើកិច្ចសន្យា នោះករណីយកិច្ចនៃការអនុវត្តទៅលើលក្ខខណ្ឌដែលមាននៅក្នុងកិច្ចសន្យានិងកើតមានឡើង ដែលតម្រូវឱ្យគូរភាគីនៃកិច្ចសន្យាដែលបានព្រមព្រៀងគ្នានោះអនុវត្តតាម។ នៅក្នុងកិច្ចសន្យារក្សាព័ត៌មានសម្ងាត់នេះដៃរភាគីដែលទទួលបាននូវព័ត៌មានសម្ងាត់មានករណីយកិច្ចអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា ដោយមិនអាចបង្ហើប ឬបញ្ចេញព័ត៌មានសម្ងាត់ណាមួយរបស់ម្ចាស់ព័ត៌មានសម្ងាត់ដែលបានមានការចែងហាមប្រាមនៅក្នុងកិច្ចសន្យា និងមិនអាចធ្វើការបង្ហាញ ឬយកទៅប្រើប្រាស់ជាប្រយោជន៍បានឡើយបើពុំមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មានសម្ងាត់នោះ។ ពោលគឺអ្នកទទួលបានព័ត៌មានសម្ងាត់នោះមិនអាចធ្វើការបង្ហាញ ឬបញ្ចេញជាសាធារណៈនូវព័ត៌មាន ដែលបានចាត់ទុកជាព័ត៌មានសម្ងាត់ ដែលបានចែងបញ្ជាក់ច្បាស់នៅក្នុងកិច្ចសន្យា មិនថាតាមមធ្យោបាយណាមួយ ដោយពុំមានការយល់ព្រម ពីម្ចាស់កម្មសិទ្ធិនៃព័ត៌មានសម្ងាត់នោះបានឡើយ។ ចំណែកម្ចាស់នៃព័ត៌មានសម្ងាត់មានសិទ្ធិក្នុងការហាមប្រាមទៅលើ ភាគីជាអ្នកទទួលបានព័ត៌មានសម្ងាត់នោះមិនអាចឱ្យមានការផ្សព្វផ្សាយព័ត៌មានសម្ងាត់របស់ខ្លួន ទៅតាមលក្ខខណ្ឌពេលវេលានៃកិច្ចសន្យាតែប៉ុណ្ណោះ ឬក្រោយពេលកិច្ចសន្យានោះនឹងត្រូវអស់សុពលភាពភាគីនៃម្ចាស់ព័ត៌មានសម្ងាត់ ពុំអាចធ្វើការដាក់គំនាបណាមួយ ឱ្យភាគីធ្វើការអនុវត្តបានតាមកិច្ចសន្យាបានទៀតឡើយ។

**២.២.អានុភាពនៃកិច្ចសន្យារក្សាព័ត៌មានសម្ងាត់**

កិច្ចសន្យារក្សាព័ត៌មានសម្ងាត់មានអានុភាព គ្រប់ដណ្តប់ទៅលើការអនុវត្ត របស់គូរភាគីនៃកិច្ចសន្យាទាំងសងខាង ពោលគឺទាំងភាគីទទួលបានព័ត៌មានសម្ងាត់ និងភាគីនៃម្ចាស់ព័ត៌មានសម្ងាត់នេះ។ ចំពោះភាគី

[41] កិច្ចសន្យារក្សាការសម្ងាត់(Non-Disclosure Agreement)

នៃកិច្ចសន្យាដែលជា ម្ចាស់ព័ត៌មានសម្ងាត់មាន អានុភាពក្នុងការឱ្យភាគីម្ខាងទៀត ដែលជាអ្នកទទួលបាននូវព័ត៌មានសម្ងាត់ ធ្វើការអនុវត្តនូវកាតព្វកិច្ចរក្សានូវព័ត៌មានសម្ងាត់ទាំងឡាយណាដែលខ្លួន និងភាគីនៃអ្នកទទួលព័ត៌មានបានធ្វើការព្រមព្រៀងចាត់ទុកជាព័ត៌មានសម្ងាត់។ ប្រសិនបើភាគីនៃកិច្ចសន្យាដែលជាអ្នកទទួលបានព័ត៌មានសម្ងាត់ ធ្វើការអនុវត្តខុសនូវលក្ខខណ្ឌដែលបានព្រមព្រៀងនៅក្នុងកិច្ចសន្យារក្សាព័ត៌មានសម្ងាត់ នោះភាគីនៃកិច្ចសន្យា ដែលជាម្ចាស់នៃព័ត៌មានសម្ងាត់នោះមានសិទ្ធិក្នុងការទាមទារឱ្យអនុវត្តដោយបង្ខំទៅលើភាគីដែលជាអ្នកទទួលបានព័ត៌មានសម្ងាត់នោះ ដោយដាច់ខាតភាគីនេះត្រូវតែរក្សាការសម្ងាត់របស់ខ្លួន។ ម្យ៉ាងវិញទៀតប្រសិនបើភាគីនៃកិច្ចសន្យា ដែលជាអ្នកទទួលបានព័ត៌មានសម្ងាត់ បានធ្វើឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែល ជាម្ចាស់នៃព័ត៌មានសម្ងាត់យ៉ាងធ្ងន់ធ្ងរនោះ ដោយសារមិនអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាដែលតម្រូវឱ្យ ភាគីនេះរក្សានូវការសម្ងាត់របស់ភាគីម្ចាស់ព័ត៌មានសម្ងាត់ នោះភាគីជាម្ចាស់នៃព័ត៌មានសម្ងាត់ មានសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាតរបស់ខ្លួន ដែលបានកើតឡើងដោយសារការមិនអនុវត្តទៅតាមកិច្ចសន្យា របស់ភាគីទទួលបានព័ត៌មានសម្ងាត់នោះ។ ចំណែកគូរភាគីនៃកិច្ចសន្យាដែលជាអ្នកទទួលបានព័ត៌មាន មានសិទ្ធិក្នុងការជំទាស់ទៅលើការអនុវត្តទាមទារនូវការរក្សាព័ត៌មានសម្ងាត់ណាដែលមិនមានចែងក្នុងលក្ខខណ្ឌនៃកិច្ចសន្យារក្សាព័ត៌មានសម្ងាត់ដែលបានធ្វើឡើងនោះ។ ម្យ៉ាងទៀត អ្នកដែលទទួលបានព័ត៌មានសម្ងាត់មិនមានកាតព្វកិច្ច ក្នុងការរក្សាការសម្ងាត់ណាដែលកើតឡើងក្រោយពេលកិច្ចសន្យាបានបង្កើតឡើយ។ អំឡុងពេលនៃការរក្សាព័ត៌មានសម្ងាត់នេះផងដែល គូរភាគីដែលជាអ្នកទទួលព័ត៌មានសម្ងាត់ក៏មានសិទ្ធិក្នុងការបញ្ចេញព័ត៌មានសម្ងាត់ ដែលបានចែងឱ្យរក្សាការពារនៅក្នុងកិច្ចសន្យាក្នុងករណី៖

- ព័ត៌មានដែលមានជាសាធារណៈរួចហើយ
- ព័ត៌មានដែលត្រូវបានបង្ហាញដោយម្ចាស់នៃព័ត៌មានសម្ងាត់ចំពោះអ្នកមុនពេលអ្នកចុះហត្ថលេខាលើកិច្ចសន្យារក្សាព័ត៌មានសម្ងាត់
- ព័ត៌មានដែលបានស្គាល់ ឬធ្លាប់ឃើញពីប្រភពផ្សេងទៀត
- ប្រសិនបើទាក់ទងទៅនឹងអំពីបទល្មើសព្រហ្មទណ្ឌ
- ប្រសិនបើអ្នកផ្តល់ភស្តុតាង គយឬអាជ្ញាធរ។[42]

នៅក្នុងកិច្ចព្រមព្រៀងជាធម្មតាមានវិធានដែលអនុញ្ញាតឱ្យអ្នកពិភាក្សាអំពីព័ត៌មានសម្ងាត់នេះជាមួយទីប្រឹក្សាច្បាប់និងគ្រួសារជិតស្និទ្ធរបស់អ្នក។

[42] កិច្ចសន្យារក្សាការសម្ងាត់(Non-Disclosure Agreement)

## ផ្នែកទី២៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្នុងការអនុវត្តកិច្ចសន្យាពាណិជ្ជកម្ម

នៅក្នុងការអនុវត្តកិច្ចសន្យាពាណិជ្ជកម្មជាទូទៅនាពេលបច្ចុប្បន្ន បានប្រើប្រាស់នូវប្បញ្ញត្តិដែលមានក្នុងច្បាប់ក្រមរដ្ឋប្បវេណីយកមកអនុវត្ត ព្រោះនៅក្នុងវិស័យពាណិជ្ជកម្មនេះពុំទាន់មានច្បាប់សម្រាប់ប្រើប្រាស់ជាឯករាជ្យឡើយ។ ជាក់ស្តែងការអនុវត្តរាល់កិច្ចសន្យាគឺ ស្ថិតនៅក្នុងទម្រង់ច្បាប់បញ្ញត្តិ នៃក្រមរដ្ឋប្បវេណីស្ទើរតែទាំងស្រុង ពោលគឺអនុវត្តទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា ដែលមានការព្រមព្រៀងគ្នារវាងគូរភាគី។ នៅក្នុងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ដើម្បីជាសុវត្ថិភាព និង ជាប្រយោជន៏ដល់ម្ចាស់ព័ត៌មានសម្ងាត់ នៅក្នុងកិច្ចសន្យាពាណិជ្ជកម្មគេតែងកំណត់លក្ខខណ្ឌដែល តម្រូវឱ្យមានការរក្សាជាការសម្ងាត់នូវព័ត៌មានដែលចាត់ទុកថាមានតម្លៃពាណិជ្ជកម្ម ដែលមិនអាចបញ្ចេញជាសាធារណៈ ឬជាឯកជនដោយ អាចនាំឱ្យមានការខាត់បង់ប្រយោជន៏ដល់ម្ចាស់ព័ត៌មានសម្ងាត់នោះ ទុកជាអាថ៌កំបាំង ឬមិនអាចយកទៅប្រើប្រាស់ជាប្រយោជន៏ផ្ទាល់ខ្លួនបានឡើយ ប្រសិនបើគ្មានការអនុញ្ញាតផ្តល់សិទ្ធិពីម្ចាស់នៃព័ត៌មានសម្ងាត់នោះ។

**កថាខណ្ឌ១៖ កិច្ចសន្យារក្សាការសម្ងាត់** ( mutual nondisclosure agreement)

កិច្ចសន្យារក្សាការសម្ងាតកើតឡើងនៅពេលដៃគូរអាជីវកម្ម ធ្វើការព្រមព្រៀងរក្សាព័ត៌មានសម្ងាត់របស់ដៃគូរបស់ខ្លួននៅក្នុងពេលដែលធ្វើការសហការអាជីវកម្មជាមួយគ្នា។ ជាទូទៅកិច្ចសន្យារក្សាការសម្ងាត់ត្រូវបានចុះហត្ថលេខាពេល ដែលដៃគូរអាជីវកម្មមានការព្រមព្រៀងសម្រេច និងមានគោលបំណងការពារនូវការសម្ងាត់អាជីវកម្មនោះ។[43]

**១.ព័ត៌មានសម្ងាត់**

ព័ត៌មានដែលមានទទួលបានការការពារនៅក្នុងកិច្ចសន្យានេះ គឺជារាល់ព័ត៌មានដែលមានលក្ខណៈឯកជន ព័ត៌មានដែលមានការការពារពីកម្មសិទ្ធិបញ្ញា ដែលច្បាប់បានកំណត់ទុកថាជាព័ត៌មានសម្ងាត់របស់របស់បុគ្គល ឬក្រុមណាមួយ ហើយច្បាប់មានការការពារទៅលើព័ត៌មាននោះ។ ជាពិសេស ព័ត៌មានដែលបានបញ្ចេញជាសាធារណៈ ដែលមនុស្សគ្រប់រូបបានដឹងជាសាធារណៈ គឺមិនអាចចាត់ទុកថាជាព័ត៌មានសម្ងាត់បានឡើយ។ ម្យ៉ាងវិញទៀតព័ត៌មានដែលផុតអាជ្ញាយុកាលនៃការការពារនៅក្នុងប្បញ្ញត្តិច្បាប់ក៏មិនអាចចាត់ទុកជាព័ត៌មានសម្ងាត់បានឡើយ។

**២.ថេរវេលា**

បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង មិនមាននូវការកំណត់ពេលវេលា នៃការការពារច្បាស់លាស់ណាមួយទេ ប៉ុន្តែកិច្ចសន្យានេះអាចបញ្ចប់ក្រោយពេលការសហការអាជីវកម្មត្រូវបានបញ្ចប់។ ប៉ុន្តែកាតព្វកិច្ចនៃការរក្សាការ

[43] កិច្ចសន្យារក្សាការសម្ងាត់ (mutual nondisclosure agreement)

សម្ងាត់នៅតែមានដរាបណាព័ត៌មានសម្ងាត់នោះនៅតែស្ថិតក្នុងតម្លៃពាណិជ្ជកម្មដែលមានការការពារ និងរក្សាជាសម្ងាត់។[44]

**កថាខណ្ឌ២៖ លក្ខខណ្ឌក្នុងការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម**

នៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម ចាំបាច់បំផុតសម្រាប់ការការពារដល់ផលប្រយោជន៍ម្ចាស់ជាកម្មសិទ្ធិនៃម៉ាក់ ក្រុមហ៊ុន សហគ្រាស ឬអាជីវកម្មផ្សេង ត្រូវមានកំណត់នូវលក្ខខណ្ឌ ឱ្យដៃគូសហការអាជីវកម្មរបស់ខ្លួនរក្សានូវព័ត៌មានសម្ងាត់ដែលអាចចាត់ទុក ថាជាអាវុធនៃការប្រកួតប្រជែងនៅលើទីផ្សារ និងជាយន្តការនៃការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្មរបស់ខ្លួន ដើម្បីជៀសផុតពីការប្រកួតប្រជែងដោយមិនស្មោះត្រង់ របស់ដៃគូប្រកួតប្រជែង ដែលនាំឱ្យមានផលប៉ះពាល់ ផលប្រយោជន៍អាជីវកម្មទាំងមូល។ សម្រាប់ការកំណត់លក្ខខណ្ឌក្នុងកិច្ចសន្យាពាណិជ្ជកម្មនេះដែរ ការកំណត់នៃការរក្សាការពារការសម្ងាត់ពាណិជ្ជកម្មនេះ ត្រូវកំណត់នូវសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងលក្ខខណ្ឌនៃការបាត់បង់សិទ្ធិប្រើប្រាស់ព័ត៌មានសម្ងាត់ និងសិទ្ធិក្នុងការប្រើប្រាស់ព័ត៌មានសម្ងាត់នៅក្នុងកាលៈទេសៈផ្សេងៗ ព្រមទាំងពេលវេលានៃការការពារព័ត៌មានសម្ងាត់នេះផងដែរ។

**១.សិទ្ធិក្នុងការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម**

ភាគីនៃកិច្ចសន្យាដែលជាអ្នកទទួលបានព័ត៌មានសម្ងាត់ មានសិទ្ធិក្នុងការប្រើប្រាស់ព័ត៌មានសម្ងាត់ ប៉ុន្តែមិនមានលក្ខណៈពេញលេញនោះទេ ពោលគឺអាចប្រើប្រាស់បាននៅក្នុងកម្រិតមួយដែលនៅក្នុងកិច្ចសន្យាបានកំណត់ដែលនិង ផ្តល់ផលប្រយោជន៍ដល់ភាគីនៃកិច្ចសន្យា ព្រមទាំងមិនលើសពីលក្ខខណ្ឌដែលបានចែងនៅក្នុងកិច្ចសន្យា។ ការប្រើប្រាស់សិទ្ធិសម្រាប់ប្រើប្រាស់នូវ ព័ត៌មានសម្ងាត់ពាណិជ្ជកម្មដែលទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា គឺបានន័យថាការប្រើប្រាស់សិទ្ធិនេះគឺមានការអនុញ្ញាត ឬយល់ស្របពីម្ចាស់កម្មសិទ្ធិព័ត៌មានសម្ងាត់ ក្នុងកម្រិតដែលមិនមានការប៉ះពាល់ដល់ការសម្ងាត់នោះ ពោលគឺធានាបាននូវការរក្សាការពារទៅលើការសម្ងាត់ពាណិជ្ជកម្មនោះ និងមិនបែកធ្លាយក្រោមរូបភាពណាមួយឡើយ។ **ឧទាហរណ៍៖** រោងចក្រតម្លើងគ្រឿងយានយន្តមួយ បានចុះនូវកិច្ចព្រមព្រៀងសហការ ជាមួយក្រុមហ៊ុនផលិតនិងលក់រថយន្តមួយ ដែលក្នុងកិច្ចព្រមព្រៀងក្រុមហ៊ុនផលិតនិងលក់រថយន្ត ព្រមព្រៀងគ្នាដោយឱ្យរោងចក្រតម្លើងគ្រឿងម៉ាស៊ីន តម្លើងរថយន្តដែលជាការច្នៃរចនាបទ ទៅលើរថយន្តម៉ាក់ថ្មីរបស់ខ្លួន ហេតុនេះក្នុងកិច្ចសន្យានេះគឺតម្រូវមិនឱ្យខាងរោងចក្រតម្លើងគ្រឿងយន្ត យកព័ត៌មាននៃការ ផលិតរថយន្តថ្មីនោះផ្សព្វផ្សាយទៅក្រៅបានឡើង។ ចំពោះសិទ្ធិក្នុងការប្រើប្រាស់ព័ត៌មានសម្ងាត់ រោងចក្រអាចមានសិទ្ធិប្រើប្រាស់សម្រាប់ តែតម្លើងរថយន្តលក់យានយន្តមួយនេះតែប៉ុណ្ណោះ ដោយមិនអាចយកម៉ូត រចនាបទ ឬទិន្នន័យនៃការផលិតនេះទៅប្រើប្រាស់ក្នុងការតម្លើងយានយន្តឱ្យក្រុមហ៊ុនផ្សេង ដែលមិនមានស្ថិតក្នុងកិច្ចសន្យានេះឡើយ។

[44] កិច្ចសន្យារក្សាការសម្ងាត់ (mutual nondisclosure agreement)

### ២. កាតព្វកិច្ចក្នុងការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម

ដោយនៅក្នុងកិច្ចសន្យាមានលក្ខខណ្ឌនៃការការពារ ព្រមទាំងមានការទទួលយល់ព្រម ពីភាគីទាំងសងខាងនៃកិច្ចសន្យាហើយនោះ វាបង្កើតបានមកនៅកាតព្វកិច្ច ដែលតម្រូវឱ្យភាគីនៃកិច្ចសន្យាចាំបាច់ត្រូវតែអនុវត្ត។ ការអនុវត្តកាតព្វកិច្ចនេះដៃគូរនៃកិច្ចសន្យាមិនអាចធ្វើការបង្ហើប ឬបង្ហាញនូវព័ត៌មានសម្ងាត់ដែលត្រូវការពារជាប្រយោជន៍នោះទៅឱ្យតតិយជន ដែលមិនមានពាក់ព័ន្ធនៅក្នុងកិច្ចសន្យា ឬជាបុគ្គលដែលជាចំណោមមនុស្សដែលនៅក្នុងកិច្ចសន្យាមានការហាមមិនឱ្យបង្ហើបនូវព័ត៌មានសម្ងាត់នោះឡើយ។ កាតព្វកិច្ចនេះក៏ភាគីនៃកិច្ចសន្យាមិនអាច ធ្វើការបញ្ចេញនូវព័ត៌មាននេះជាសាធារណៈបានឡើយ ទោះបីតាមមធ្យោបាយផ្សព្វផ្សាយណាមួយបានដែរ ព្រោះវាជាការដែលនាំឱ្យខូចប្រយោជន៍យ៉ាងខ្លាំងទៅ លើម្ចាស់កម្មសិទ្ធិនៃព័ត៌មានសម្ងាត់នោះ ព្រោះវានាំឱ្យមានការកើតឡើងនៅការប្រកួតប្រជែងដោយមិនស្មោះត្រង់កើតមានឡើង។ ម្យ៉ាងវិញទៀតបុគ្គលជាភាគីនៃកិច្ចសន្យាមិនអាចប្រើប្រាស់ព័ត៌មានសម្ងាត់នោះ ដើម្បីយកមកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនបានឡើយ ឬយកព័ត៌មានសម្ងាត់នោះមក ប្រើប្រាស់ក្រោមរូបភាពណាមួយ ដោយពុំមានការអនុញ្ញាត ពីម្ចាស់កម្មសិទ្ធិនៃព័ត៌មានសម្ងាត់នោះ បានឡើយ។ ប្រសិនបើមានការបែកធ្លាយនូវព័ត៌មានសម្ងាត់ ដោយប្រការណាមួយដែលបណ្តាលមកពីការមិនគោរពនូវលក្ខខណ្ឌ នៃកិច្ចសន្យារបស់ភាគីដោយបញ្ចេញនូវព័ត៌មានសម្ងាត់ ទៅឱ្យបុគ្គល ឬផ្សព្វផ្សាយជាសាធារណៈ នោះភាគីនៃកិច្ចសន្យាមានកាតព្វកិច្ចក្នុងការទទួលខុសត្រូវលើការខូចខាតដែលខ្លួនបានបង្កទៅលើភាគីដែល ជាម្ចាស់កម្មសិទ្ធិនៃព័ត៌មានសម្ងាត់នោះនិង សងជាសំណងខូចខាតទៅតាមលក្ខខណ្ឌដែលមាននៃកិច្ចសន្យា និងទៅតាមនិងប្បញ្ញត្តិនៃច្បាប់។[45] **ឧទាហរណ៏៖** ក្រុមហ៊ុនម៉ៅការសំណង់ និងក្រុមហ៊ុនលក់ផ្ទះល្វែង បានចុះកិច្ចសន្យាព្រមព្រៀងសហការធ្វើពាណិជ្ជកម្មរួមគ្នា ដោយឱ្យក្រុមហ៊ុនម៉ៅការសំណង់ធ្វើការសាងសង់ផ្ទះ នៅក្នុងគម្រោងរបស់ខ្លួន។ មុននិង អាចសាងសង់បាន ក្រុមហ៊ុនលក់ផ្ទះល្វែងត្រូវបង្ហាញនូវគម្រោង ប្លង់ ម៉ូត រចនាសម្ព័ន្ធ និងទិន្នន័យផ្សេងៗ ដែរលទាក់ទងនិងដំណើរការសាងសង់នោះទៅឱ្យក្រុមហ៊ុនម៉ៅការសំណង់។ នៅក្នុងករណីនេះក្រុមហ៊ុនម៉ៅការសំណង់មិនអាចធ្វើការបង្ហាញគម្រោង ឬយកគម្រោងនេះទៅប្រើប្រាស់ បម្រើសេវាកម្មសម្រាប់តតិយជន ឬដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនបានឡើយ ពោលគឺអាចប្រើប្រាស់វាសម្រាប់តែការសាងសង់ ឱ្យក្រុមហ៊ុនលក់ផ្ទះល្វែងមួយនេះតែប៉ណ្ណោះ។ ចំពោះការបញ្ចេញនូវព័ត៌មានទាំងនោះទៅឱ្យតតិយជន ជាសាធារណៈ ឬប្រើប្រាស់ក្នុងគោលបំណង់ផលប្រយោជន៍ផ្ទាល់ខ្លួន ក្រុមហ៊ុនលក់ផ្ទះល្វែងមានសិទ្ធិក្នុងការទាមទារឱ្យក្រុមហ៊ុនម៉ៅការសំណង់នូវការទទួលខុសត្រូវចំពោះមុខច្បាប់ និងទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា ហេតុនេះក្រុមហ៊ុនត្រូវទទួលមុខចំពោះបញ្ញត្តិច្បាប់ចំពោះទង្វើរបស់ខ្លួន ព្រមទាំងធ្វើការសងទៅតាមសំណងដែលបានកំណត់នៅក្នុងកិច្ចសន្យា ឬច្បាប់។

[45] គោលការណ៍មាត្រា៣៩៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ផ្នែកទី៣៖ យន្តការការពារការសម្ងាត់ពាណិជ្ជកម្មក្រោយបញ្ចប់កិច្ចសន្យាពាណិជ្ជកម្ម

នៅក្រោយពេលបញ្ចប់នូវ កិច្ចសន្យាពាណិជ្ជកម្មណាមួយ ក៏មិនបានធ្វើឲ្យកាតព្វកិច្ចការពារព័ត៌មានសម្ងាត់នោះ ផុតរលុតនោះដែរ ពោលនៅក្នុងកិច្ចសន្យាត្រូវមានការកំណត់នូវលក្ខខណ្ឌដែលតម្រូវឱ្យមានការបន្តនូវការរក្សាព័ត៌មានសម្ងាត់បើទោះជាកិច្ចសន្យានៃកិច្ចសហការគ្នាត្រូវបានបញ្ចប់ ឬ រំលាយនូវកិច្ចសន្យានោះក៏ដោយ។

### កថាខណ្ឌទី១៖ កិច្ចព្រមព្រៀងមិនមានការប្រកួតប្រជែង( NoncompeteAgreement )

ក្រោយពីកិច្ចព្រមព្រៀង សហការអាជីវកម្មត្រូវបានបញ្ចប់ ភាគីនៃកិច្ចសន្យាត្រូវធ្វើការព្រមព្រៀងមួយទៀតនៃកិច្ចសន្យាមិនមានការប្រកួតប្រជែង ដែលក្នុងកិច្ចសន្យាមិនមានការប្រកួតប្រជែងត្រូវធ្វើឡើងដោយមានការយល់ស្របពី ភាគីអាជីវកម្មទាំងសងខាង ដោយផ្អែកលើកម្មវត្ថុនៃកិច្ចសន្យាដោយមានលក្ខណៈសមមូល។ កិច្ចសន្យាព្រមព្រៀងមិនមានការប្រកួតប្រជែងគឺ ជាកិច្ចសន្យាដែលភាគី បានចុះហត្ថលេខាសម្រេចនូវលក្ខខណ្ឌមិនធ្វើការប្រកួតប្រជែងក្នុងវិស័យពាណិជ្ជកម្មតែមួយក្រោយពីចប់កិច្ចសន្យាពាណិជ្ជកម្ម។[46]

#### ១. កម្មវត្ថុ

កម្មវត្ថុនៃកិច្ចសន្យា គឺជាលក្ខខណ្ឌគ្រឹះមួយនៅក្នុងការបង្កើត ដោយត្រូវកំណត់ឱ្យជាក់លាក់ដើម្បីដឹងពីគោលបំណងរបស់ខ្លួន ហើយកម្មវត្ថុនោះត្រូវតែអាចធ្វើទៅបាន ពោលគឺត្រូវតែមានលទ្ធភាពក្នុងការអនុវត្ត។ យ៉ាងណាមិញ កម្មវត្ថុនៃកិច្ចសន្យាត្រូវកំណត់ឱ្យស្របនិងប្បញ្ញត្តិច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ។ ហេតុនេះកិច្ចព្រមព្រៀងមិនមានការប្រកួតប្រជែង គឺត្រូវមានភាពសមហេតុដោយអាចឱ្យភាគីអនុវត្តបាន ដែលស្របទៅនិង ប្បញ្ញត្តិច្បាប់ និងសណ្តាប់ធ្នាប់សង្គម ។ ដោយនៅក្នុងកិច្ចព្រមព្រៀងត្រូវកំណត់ពីសេរីភាពសមហេតុផល ព្រមទាំងលក្ខខណ្ឌដែលមិនមានការកេងប្រវ័ញ្ច ឬយកចំណេញពីភាគីម្ខាងទៀត ពោលគឺត្រូវដាក់លក្ខខណ្ឌក្នុងទម្រង់ដែលឱ្យភាគីម្ខាងទៀតធ្វើការអនុវត្តដោយមិនមានការបាត់បង់ផលប្រយោជន៍ របស់ភាគីណាឡើយ។

#### ២.ការកំណត់ក្នុងកិច្ចព្រមព្រៀងមិនមានការប្រកួតប្រជែង

ការកំណត់ទៅលើកិច្ចព្រមព្រៀងមិនមានការរប្រកួតប្រជែងនៅពេលដែលដៃគូរ បានធ្វើការចាកចេញពីអាជីវកម្ម គឺអាច រារាំងអតីតដៃគូមិនឱ្យធ្វើអាជីវកម្មស្រដៀងគ្នានៅក្នុងទីតាំងណាមួយ ដែលមើលទៅអាចចាត់ទុកជាការប្រកួតប្រជែង។ ម្យ៉ាងវិញទៀតនៅ ក្នុងកិច្ចព្រមព្រៀងនេះក៏អាចធ្វើការ កំណត់ទៅលើពេលវេលា ដែលហាមឃាត់មិនឱ្យគូភាគីធ្វើអាជីវកម្មដដែល ឬអាជីវកម្មដែលអាចចាត់ទុកជាការប្រកួតប្រជែង នៅក្នុងថេរវេលាសមហេតុផលណាមួយ។ ឧទាហរណ៍៖ កិច្ចព្រមព្រៀងមិនប្រកួតប្រជែងដែល រារាំងអតីតដៃគូពីការធ្វើជំនួញ

[46] កិច្ចសន្យាមិនប្រកួតប្រជែង(Non-Compete Agreement )

ដែលមានការប្រកួតប្រជែងដោយផ្ទាល់ក្នុងចម្ងាយ ២០ ម៉ាយល៍រយៈពេល ២ ឆ្នាំគឺសមហេតុផលជាងកិច្ចព្រមព្រៀងមួយដែលរារាំងអតីតដៃគូមិនឱ្យប្រកួតប្រជែងក្នុងរដ្ឋទាំងមូលអស់រយៈពេល ១០ ឆ្នាំ។[47]

**៣. កិច្ចព្រមព្រៀងមិនមានការប្រកួតប្រជែង**

កិច្ចព្រមព្រៀងមានអានុភាពទៅលើភាគី នៃកិច្ចសន្យាទៅតាមលក្ខខណ្ឌដែល បានកំណត់ដែលនៅក្នុងកិច្ចសន្យានោះរហូតដល់ ផុតរលត់នូវកិច្ចសន្យានេះ ឬអាចអស់សុពលភាពនៅពេលដែល កិច្ចសន្យានេះត្រូវបានរំលាយ ឬមោឃភាពដោយ ហេតុផលមានវិការៈ ឬហេតុផលផ្ទុយពីច្បាប់ផ្សេងៗ។ កិច្ចព្រមព្រៀងនេះចង់បង្ហាញកាតព្វកិច្ចដល់គូភាគីឱ្យមាន ការអនុវត្តទៅតាមលក្ខខណ្ឌដោយមិនប្រកួតប្រជែង ឬរក្សាជដែលនូវការសម្ងាត់នោះ។ ហើយកិច្ចព្រមព្រៀងនេះផងដែរ ក៏មានអនុភាព ឱ្យគូភាគីមានកាតព្វកិច្ចទទួលខុសត្រូវ នៅពេលដែលខ្លួនប្រព្រឹត្តខុសទៅនឹងកិច្ចសន្យា។

[47] កិច្ចសន្យាមិនប្រកួតប្រជែង(Non-Compete Agreement)

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ការសម្ងាត់ពាណិជ្ជកម្ម គឺជាប្រភេទព័ត៌មានដែលត្រូវបានគេចាត់ទុកថា មានតម្លៃពាណិជ្ជកម្ម ពោលគឺជាគោលចំហររបស់ពាណិជ្ជកម្ម ឬជាផ្នែកដែលធ្វើឱ្យពាណិជ្ជកម្មមានដំណើរការ។ ការសម្ងាត់ពាណិជ្ជកម្មមួយចំនួនទទួលបានការការការពារដោយបញ្ញត្តិច្បាប់ ដូចជារូបមន្តនៃការនូវការផលិតគ្រឿងបច្ចេកវិទ្យាអេឡិចត្រូនិច ព្រោះម្ចាស់ស្នាដៃតែងធ្វើការចុះបញ្ជីទៅលើស្នាដៃនោះ ដើម្បីឱ្យមានការការពារពីសំណាក់ច្បាប់ជាតិ និងអន្តរជាតិ។ ព័ត៌មានផ្សេងទៀតដែលយើងអាចចាត់ទុកថាជា ប្រភេទព័ត៌មានសម្ងាត់ពាណិជ្ជកម្មដែល ចាំបាច់ត្រូវមានការការពារ មានដូចជា៖ កំណត់ត្រាអាជីវកម្មនិងផែនការ ព័ត៌មានហិរញ្ញវត្ថុ អាថ៌កំបាំងពាណិជ្ជកម្ម និងការស្រាវជ្រាវលើអ្វីមួយជាដើម គំនិតនៃការច្នៃប្រឌិត និងគំនិតផលិតផល ទិន្នន័យបច្ចេកទេស ឬ ការរចនា ព័ត៌មានលម្អិតអំពីកិច្ចសន្យា ឬបញ្ជីដៃគូ ការលក់នាំមុខ និង ប្រភេទព័ត៌មានលម្អិតអតិថិជន ឬ រចនាសម្ព័ន្ធតម្លៃ ឬការបញ្ចុះតម្លៃ។ល។ នៅក្នុងនោះផងដែរ ព័ត៌មានមួយចំនួន ក៏គេមិនបានចាត់ទុកជាព័ត៌មានសម្ងាត់ពាណិជ្ជកម្មឡើយ គឺរាល់ព័ត៌មានដែលគេបានបញ្ចេញជាសាធារណៈ។ ការការពារការសម្ងាត់ពាណិជ្ជកម្មនេះគឺ គេការពារដោយប្រើនីតិវិធីនៃកិច្ចសន្យា ដោយក្នុងនោះគេត្រូវចែងពីលក្ខខណ្ឌនៃការការពារព័ត៌មាននោះ យ៉ាងមានភាពរឹតត្បិតទៅ លើការអនុវត្តនិងសិទ្ធិផ្សេងៗនៃការប្រើប្រាស់ព័ត៌មានសម្ងាត់ពាណិជ្ជកម្ម។ ចំណែកឯ ការប្រើប្រាស់នូវនីតិវិធីកិច្ចសន្យាក្នុងការការពារការសម្ងាត់ពាណិជ្ជកម្មនេះដែរ យើងឃើញថាមាន កិច្ចសន្យា ២ប្រភេទ គឺកិច្ចសន្យាការងារ និងកិច្ចសន្យាពាណិជ្ជកម្ម ដែល វាជាប្រភេទកិច្ចសន្យាដ៏សំខាន់ដែលគេតែងតែយកមកប្រើនៅក្នុងវិស័យពាណិជ្ជកម្ម ជាពិសេសក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម។ ជាងនេះទៅទៀត ការការពារការសម្ងាត់ពាណិជ្ជកម្មនៅក្នុងកិច្ចសន្យាការងារ បានកើតឡើងក្នុងពេលដែលបុគ្គលិកបានចូលបម្រើការឱ្យក្រុមហ៊ុន ឬសហគ្រាសណាមួយ ដែលមានធ្វើការចុះហត្ថលេខាលើកិច្ចសន្យាការងារដែលមានចែងនូវ លក្ខខណ្ឌផ្សេងៗក្នុងដំណើរការបម្រើការងារ ដែលក្នុងចំណោមលក្ខខណ្ឌទាំងនោះនិយោជកគឺ ចាំបាច់ត្រូវកំណត់ពីការការពារការសម្ងាត់ពាណិជ្ជកម្មនោះទាំងក្នុងអំឡុងពេលធ្វើការ និងក្រោយការឈប់បម្រើការឱ្យក្រុមហ៊ុនរបស់និយោជក។ នៅក្នុងអំឡុងពេលបម្រើការងារឱ្យនិយោជក និយោជិតដាច់ខាតមិនអាចបង្ហាញនូវ ទិន្នន័យ បញ្ជី គម្រោងការ ឬការអនុវត្តផ្សេងៗរបស់ក្រុមហ៊ុនទៅក្រៅបានឡើយ។ សម្រាប់នៅក្រោយពេលបញ្ចប់នូវកិច្ចសន្យាការងារវិញ និយោជកដើម្បីការពារការសម្ងាត់ពាណិជ្ជកម្មរបស់ខ្លួនត្រូវបង្កើតនូវកិច្ចសន្យាមួយទៀតជាមួយនិយោជិតគឺ កិច្ចសន្យាមិនចូលរួមប្រកួតប្រជែង នៅក្នុងកិច្ចសន្យានេះតម្រូវឱ្យនិយោជិតមិនអាចធ្វើការនៅ មុខជំនាញដែលជាមួយនិយោជកថ្មី ដោយមានការកំណត់នូវរយៈពេលច្បាស់លាស់មួយ ឬមិនឱ្យមានការបង្ហាញព័ត៌មានសម្ងាត់ពាណិជ្ជកម្មផ្សេងតាម វិធីណាមួយ។ចំណែកនៅក្នុង

កិច្ចសន្យាពាណិជ្ជកម្មវិញ គេការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ដោយការបង្កើតកិច្ចសន្យារក្សាការសម្ងាត់ ដែលតម្រូវឱ្យដៃគូពាណិជ្ជកម្ម រក្សានូវការសម្ងាត់នោះ។ កិច្ចសន្យារក្សាការសម្ងាត់នេះត្រូវធ្វើឡើងនៅក្នុង ដំណាក់កាលនៃការចរចា ទៅលើការសហការពាណិជ្ជកម្មជាមួយដៃគូ ដែលភាគីអាជីវករមិនអាចបង្ហើបនូវ ព័ត៌មានសម្ងាត់នោះទេ បើទោះជាការចរចារលើអាជីវកម្មនោះបានសម្រេចក្តី មិនសម្រេចក្តី។ នៅដំណាក់កាល នៃការសហការគ្នាក្នុងការធ្វើអាជីវកម្ម អាជីវករបានបង្កើតនូវកិច្ចសន្យាមួយទៀត គឺការរក្សាព័ត៌មានសម្ងាត់ដូច គ្នា ប៉ុន្តែក្រោយលក្ខខណ្ឌការពារនៅក្នុងអំឡុងពេលមានការសហការអាជិវកម្មជាមួយគ្នា ពោលគឺក្នុងអំឡុង ពេលដែលកិច្ចសន្យាពាណិជ្ជកម្មកំពុងមានដំណើរការ។ ក្រោយការបញ្ចប់នូវកិច្ចសន្យាពាណិជ្ជកម្ម អាជីវករធ្វើ ការបង្កើតនូវកិច្ចសន្យាព្រមព្រៀងមិនចូលរួមប្រកួតប្រជែង ដើម្បីធ្វើការការពារលើព័ត៌មានសម្ងាត់ពាណិជ្ជកម្ម។ ការកំណត់ទៅលើកិច្ចព្រមព្រៀងមិនមានការរប្រកួតប្រជែងនៅពេលដែលដៃគូបានចាកចេញពីអាជីវកម្ម គឺអាច រារាំងអតីតដៃគូមិនឱ្យធ្វើអាជីវកម្ម ស្រដៀងគ្នានៅក្នុងទីតាំងណាមួយ ដែលមើលទៅអាចចាត់ទុកជាការប្រកួត ប្រជែង។ ម្យ៉ាងវិញទៀតនៅ ក្នុងកិច្ចព្រមព្រៀងនេះក៏អាចធ្វើការ កំណត់ទៅលើពេលវេលា ដែលហាមឃាត់មិន ឱ្យគូភាគីធ្វើអាជីវកម្មដដែល ឬអាជីវកម្មដែលអាចចាត់ទុកជាការប្រកួតប្រជែង នៅក្នុថេរវេលាសមហេតុផល ណាមួយ។បើទោះជាមានការការពារនៅក្នុងកិច្ចសន្យាទាំងនេះក្តី ប៉ុន្តែមានករណីលើកលែងមួយចំនួនដែល ព័ត៌មានសម្ងាត់ អាចធ្វើការបង្ហាញដោយដៃគូរនៃកិច្ចសន្យាបាន ដែលក្នុងនោះមានដូចជា៖ ព័ត៌មានសម្ងាត់ ដែលបានក្លាយជាលក្ខណៈសាធារណៈ បង្ហាញជាភស្តុតាង ពាក់ពន្ធ័នឹងបទល្មើសព្រហ្មទណ្ឌ។

# ឯកសារយោង

## ១ .ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តៈ

### ក.ច្បាប់ចូលជាធរមានៈ


- ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចុះលេខ ជស/រកម/០៣៩៧/០១ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧
- ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចុះលេខ នស/រកម/១២០៧/០៣០ រដ្ឋសភាអនុម័តដាក់ឲ្យប្រើប្រាស់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧
- AGREEMENT ON TRADE-RELATED ASPCTS OF INTELLECTUAL PROPERTY RIGHT


### ខ.សេចក្តីព្រាងច្បាប់ៈ


- អត្ថបទព្រៀងច្បាប់ស្តីពីព័ត៌មានសម្ងាត់ និងការផ្តល់អាជ្ញាប័ណ្ណបង្ខំសម្រាប់សុខភាពសាធារណៈ និងការសម្ងាត់ពាណិជ្ជកម្មអត្ថបទត្រៀមលើកទី២ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧
- សេចក្តីព្រាងច្បាប់ស្តីពីច្បាប់កិច្ចសន្យាណិជ្ជកម្មឆ្នាំ២០០៩ ដោយក្រសួងពាណិជ្ជកម្ម,ខែតុលា ឆ្នាំ២០០១៩


## ២.សៀវភៅ និងអត្ថបទផ្សេងៗ


- សុិនចេឡា អេមប៉ាសុីៈ ច្បាប់ការពារការសម្ងាត់ពាណិជ្ជកម្មៈ ករណីសិក្សានៅLatvia ដេប៉ាដឺម៉ង់ផ្នែកច្បាប់នៃសាកលវិទ្យាល័យលុន ឆ្នាំ ២០០៧។ <http://lup.lub.lu.se/luur/download?func=downloadFile&recordOId=1555294&fileOId=1563611>
- IPR-Helpdeskៈ ច្បាប់នៃការការពារការសម្ងាត់ពាណិជ្ជកម្ម ឆ្នាំ ២០០៦ (The Legal Protection of Trade Secrets) <https://www.av-asesores.com/upload/335.PDF>
- ហ្គ្រែវីស ហ្សូសេៈ វិធីការពារការសម្ងាត់ពាណិជ្ជកម្មបន្ទាប់ពីការចាកចេញរបស់និយោជិត ឆ្នាំ ២០១៨ (How to Protect Trade Secrets Following the Departure of a key Employee) <https://www.lexology.com/library/detail.aspx?g=16f4791a-a95f-4eb7-912f-3e45c845b888>
- ហ្គេស ធីណាៈ ការការពារការសម្ងាត់ពាណិជ្ជកម្មដោយប្រើប្រាស់កិច្ចសន្យា ឆ្នាំ២០១៦ ផ្សាយដោយបណ្ណាល័យច្បាប់ហ្គេសការងារ (Protecting Trade Secrets Using Employment Agreement) <https://gehreslaw.com/protecting-trade-secrets-using-employment-agreements/>

- ហាំម៉ល យ៉ូសែប និងខូលីស ជេស៊ី៖ ការការពារការសម្ងាត់ពាណិជ្ជកម្មនិងព័ត៌មានសម្ងាត់របស់និយោជក(Protection of Employers´ Trade Secrets and Confidential Information) ឆ្នាំ ២០១០<http://files.dorsey.com/files/upload/tradesecretsconfidential.pdf>
- ផ្លលឡឺ ឡូរ៉ា៖ ការសម្ងាត់ពាណិជ្ជកម្មនិងនិយោជិតជំនាញនៅក្នុងវិស័យបច្ចេកវិទ្យា ឆ្នាំ ១៩៨៣ សាលាច្បាប់នៃសាកលវិទ្យាល័យវ៉ាស៊ីនតោន (Trade Secrets and Skilled Employee in ComputerIndustry)<https://openscholarship.wustl.edu/cgi/viewcontent.cgi?article=2320&context=law_lawreview>
- South-East Asia IRP SME HELPDESK៖ ការការពារការសម្ងាត់ពាណិជ្ជកម្មនៅតំបន់អាស៊ីអាគ្នេយ៍(Protecting Your Trade Secret in South-East Asia)ឆ្នាំ ២០១៦ <https://www.southeastasia-iprhelpdesk.eu/sites/default/files/publications/Trade-Secrets-English.pdf>
- អ្នកនិពន្ធមេធាវី FindLaw៖ កិច្ចព្រមព្រៀងដោយបង្ខំក្នុងការមិនប្រកួតប្រជែង ឆ្នាំ២០១៧ ផ្សាយដោយ FindLaw <https://corporate.findlaw.com/business-operations/enforceable-covenants-not-to-compete.html>
- កម្មសិទ្ធិបញ្ញា(Intellectual Property Right) http://www.metheavy.com/File/Media/Intellectual%20Property%20Rights_Eng.pdf
- ការសម្ងាត់ពាណិជ្ជកម្ម https://www.wipo.int/export/sites/www/sme/en/documents/pdf/ip_panorama_4_learning_points.pdf

## ៣.គេហទំព័រ

- ការការពារការសម្ងាត់នៅកម្ពុជា <https://www.southeastasia-iprhelpdesk.eu>
- កម្មសិទ្ធិបញ្ញា៖ការការពារនិងការចូលជាធរមាន(Intelletual Property: protection and enforcement) <https://www.wto.org>
- មាត្រា៣៩ នៃកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា <https://www.wto.org>
- មូលដ្ឋានគ្រឹះនៃការសម្ងាត់ពាណិជ្ជកម្ម <https://www.wipo.int/tradesecrets/en/tradesecrets_faqs.html#protection>

- យុទ្ធសាស្ត្រ១០យ៉ាងក្នុងការការពារការសម្ងាត់ពាណិជ្ជកម្ម(Ten Strategies For Trade Secret Protection) <https://corporate.findlaw.com>
- ការការពារការសម្ងាត់ពាណិជ្ជកម្មក្រោយការចាកចេញរបស់និយោជិត(Protecting Trade Secrets when Employees Depart) <https://gowlingwlg.com/en/insightsresources/articles/2017/protecting-trade-secrets-when-employees-depart/>

- កិច្ចសន្យារក្សាការសម្ងាត់ (Non-disclosure Agreement) <https://www.rocketlawyer.com/article/nda-101:-what-is-a-non-disclosure-agreement.rl>
- កិច្ចសន្យារក្សាការសម្ងាត់ (Non-disclosure Agreement) < https://www.warnergoodman.co.uk/site/blog/news/what-can-i-disclose-after-signing-a-nondisclosure-agreement-nda>
4. In respect of any acts in respect of specific objects embodying protected subject matter which become infringing under the terms of legislation in conformity with this Agreement, and which were commenced, or in respect of which a significant investment was made, before the date of acceptance of the WTO Agreement by that Member, any Member may provide for a limitation of the remedies available to the right holder as to the continued performance of such acts after the date of application

of this Agreement for that Member. In such cases the Member shall, however, at least provide for the payment of equitable remuneration.

5. A Member is not obliged to apply the provisions of Article 11 and of paragraph 4 of Article 14 with respect to originals or copies purchased prior to the date of application of this Agreement for that Member.

6. Members shall not be required to apply Article 31, or the requirement in paragraph 1 of Article 27 that patent rights shall be enjoyable without discrimination as to the field of technology, to use without the authorization of the right holder where authorization for such use was granted by the government before the date this Agreement became known.

7. In the case of intellectual property rights for which protection is conditional upon registration, applications for protection which are pending on the date of application of this Agreement for the Member in question shall be permitted to be amended to claim any enhanced protection provided under the provisions of this Agreement. Such amendments shall not include new matter.

8. Where a Member does not make available as of the date of entry into force of the WTO Agreement patent protection for pharmaceutical and agricultural chemical products commensurate with its obligations under Article 27, that Member shall:

(a) notwithstanding the provisions of Part VI, provide as from the date of entry into force of the WTO Agreement a means by which applications for patents for such inventions can be filed;

(b) apply to these applications, as of the date of application of this Agreement, the criteria for patentability as laid down in this Agreement as if those criteria were being applied on the date of filing in that Member or, where priority is available and claimed, the priority date of the application; and

(c) provide patent protection in accordance with this Agreement as from the grant of the patent and for the remainder of the patent term, counted from the filing date in accordance with Article 33 of this Agreement, for those of these applications that meet the criteria for protection referred to in subparagraph (b).

9. Where a product is the subject of a patent application in a Member in accordance with paragraph 8(a), exclusive marketing rights shall be granted, notwithstanding the provisions of Part VI, for a period of five years after obtaining marketing approval in that Member or until a product patent is granted or rejected in that Member, whichever period is shorter, provided that, subsequent to the entry into force of the WTO Agreement, a patent application has been filed and a patent granted for that product in another Member and marketing approval obtained in such other Member.

### *Article 71*

*Review and Amendment*

1. The Council for TRIPS shall review the implementation of this Agreement after the expiration of the transitional period referred to in paragraph 2 of Article 65. The Council shall, having regard to the experience gained in its implementation, review it two years after that date, and at identical intervals thereafter. The Council may also undertake reviews in the light of any relevant new developments which might warrant modification or amendment of this Agreement.

2. Amendments merely serving the purpose of adjusting to higher levels of protection of intellectual property rights achieved, and in force, in other multilateral agreements and accepted under those agreements by all Members of the WTO may be referred to the Ministerial Conference for

action in accordance with paragraph 6 of Article X of the WTO Agreement on the basis of a consensus proposal from the Council for TRIPS.

### *Article 72*

*Reservations*

Reservations may not be entered in respect of any of the provisions of this Agreement without the consent of the other Members.

### *Article 73*

*Security Exceptions*

Nothing in this Agreement shall be construed:

(a) to require a Member to furnish any information the disclosure of which it considers contrary to its essential security interests; or

(b) to prevent a Member from taking any action which it considers necessary for the protection of its essential security interests;

(i) relating to fissionable materials or the materials from which they are derived;

(ii) relating to the traffic in arms, ammunition and implements of war and to such traffic in other goods and materials as is carried on directly or indirectly for the purpose of supplying a military establishment;

(iii) taken in time of war or other emergency in international relations; or

(c) to prevent a Member from taking any action in pursuance of its obligations under the United Nations Charter for the maintenance of international peace and security.

**អត្ថបទពង្រៀងលើកទី ២ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧**

# ច្បាប់ស្តីពី ព័ត៌មានសម្ងាត់ និង ការផ្តល់អាជ្ញាប័ណ្ណបង្ខំសម្រាប់សុខភាពសាធារណៈ និងការសម្ងាត់ពាណិជ្ជកម្ម

## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១~. គោលបំណង

ច្បាប់នេះ ផ្តល់ការការពារដល់ព័ត៌មានសម្ងាត់ និង ការសម្ងាត់ពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់នេះ និង មាត្រា ៣៩ នៃកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញារបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ច្បាប់នេះ ផ្តល់ផងដែរនូវអនុភាពដល់សេចក្តីសម្រេចស្តីពីការអនុវត្តន៏កថាខ័ណ្ឌទី ៦ នៃសេចក្តីប្រកាសទីក្រុង ដូហា ស្តីពីកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា និងសុខភាពសាធារណៈ ។

**មាត្រា ២_. បញ្ញាត្តិច្បាប់រដ្ឋប្បវេណី**

ច្បាប់នេះ មិនប៉ះពាល់ ជាទូទៅ ឬដោយជាក់លាក់ដល់អនុភាពគតិយុត្តិនៃបទប្បញ្ញត្តិណាមួយដែលចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលក្រោមបទប្បញ្ញត្តិទាំងនោះកាតព្វកិច្ចនៃការរក្សាការសម្ងាត់កើតឡើងទាក់ទិនទៅនឹងការទទួលបាន ការបង្កើបបង្ហាញ ឬការប្រើប្រាស់ព័ត៌មានសម្ងាត់ ។

**មាត្រា ៣_. យុត្តាធិការ**

តុលាការមានសមត្ថកិច្ច ត្រូវមានយុត្តាធិការទៅលើវិវាទដែលពាក់ព័ន្ធនឹងការអនុវត្តន៏ច្បាប់នេះ ។

**មាត្រា ៤_.ការពន្យាពេលនៃការអនុវត្តន៏**

ផ្នែកទី១ ដល់ ផ្នែកទី ៣ នៃច្បាប់នេះ ត្រូវរង់ចាំរហូតដល់ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ ទើបអនុវត្ត ស្របតាមកថាខណ្ឌទី ១ នៃមាត្រា ៦៦ នៃសេចក្តីសម្រេចស្តីពីការពន្យាអំឡុងពេលអន្តរកាលសម្រាប់ប្រទេសជាសមាជិកដែលមានការអភិវឌ្ឍន៍តិចតួច របស់ក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៥ លុះត្រាតែ:

ក- អង្គការពាណិជ្ជកម្មពិភពលោកប្រកាសថា ព្រះរាជាណាចក្រកម្ពុជាលែងជាប្រទេសដែលមានការអភិវឌ្ឍន៍តិចទៀតហើយ ។ ឬ

ខ- គណៈរដ្ឋមន្ត្រីប្រកាសអោយអនុវត្តផ្នែកទី១ ដល់ ផ្នែកទី៣ នៃច្បាប់នេះ ។

# ផ្នែកទី ២
# ព័ត៌មានសម្ងាត់ សម្រាប់វិញ្ញាបនប័ត្រអនុញ្ញាត្តិឱ្យចែកចាយ លក់ផលិតផលឱសថ និងផលិតផលគីមីកសិកម្ម

## មាត្រា ៥~. និយមន័យ

នៅពេលប្រើក្នុងផ្នែកទី ២ នៃច្បាប់នេះ:

"សារធាតុសកម្ម" មានន័យថាជាម៉ូលេគួល ឬ អ៊ីយ៉ុង តែមិនរាប់បញ្ចូលសមាសភាគបន្ថែមនៃម៉ូលេគូលដែលបណ្តាលអោយឱសថក្លាយជាអែស្ទែរ និង អំបិល (រួមបញ្ចូលទាំងអំបិលមានសារធាតុអ៊ីដ្រូសែន ឬសារធាតុគីមីពាក់ព័ន្ធ) ឬ និទ្ទស្សវត្ថុគ្មានកូវ៉ាឡង់ផ្សេងទៀត (ដូចជាសមាសធាតុសាំញ៉ាំបណ្តុំម៉ូលេគូល និង ក្លារ៉ែត) នៃម៉ូលលេគូល ដែលទ្រទ្រង់សំរាប់សកម្មភាពសរីរសាស្ត្រ និង ឱសថវិទ្យានៃសារធាតុឪសថ ។

"អង្គធាតុគីមីថ្មី" មានន័យថា:

- សម្រាប់ផលិតផលឱសថ វាជាឱសថដែល មិនមានសារធាតុសកម្មណាមួយ ដែលបានត្រូវប្រើក្នុងផលិតផលឱសថណាមួយឡើយ ។
- សម្រាប់ផលិតផលគីមីកសិកម្ម [និយមន័យនឹងត្រូវបញ្ចូលនាពេលក្រោយ ] ។

"កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា" គឺជាសកម្មភាពពិសេស ឬ យកចិត្តទុកដាក់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដែលមានវិសាលភាពធំ និង ប្រើពេលយូរ ក្នុងការបង្កើតទិន្នន័យពិសោធន៏ជាសម្ងាត់ ឬ ទិន្នន័យដ៏ទៃទៀត ។

"ការប្រើប្រាស់ក្នុងពាណិជ្ជកម្មដោយមិនស្មោះត្រង់" មានន័យថា ជាការប្រើប្រាស់ ឬបំលែងទិន្នន័យពិសោធន៏ជាសម្ងាត់ ឬ ទិន្នន័យដ៏ទៃទៀត ដោយមិនស្មោះត្រង់ ដើម្បីទទួលបានផលប្រយោជន៏ ។

## មាត្រា ៦.. ការការពារព័ត៌មានសម្ងាត់

១- រដ្ឋមន្ត្រីទទួលបន្ទុក ត្រូវផ្តល់ការការពារទល់នឹងការប្រើប្រាស់ទិន្នន័យពិសោធន៍ជាសម្ងាត់ ឬទិន្នន័យដ៏ទៃទៀតដោយបុគ្គលដ៏ទៀត ក្នុងពាណិជ្ជកម្មដោយមិនស្មោះត្រង់ ដែលអ្នកដាក់ពាក្យស្នើសុំបាន ដាក់ជូនពិនិត្យ ក្នុងពេលបំពេញតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងទទួលបន្ទុកនោះ ដើម្បីទទួលបាន វិញ្ញាបនប័ត្រអនុញ្ញាតឱ្យចែកចាយលក់ផលិតផលឱសថ ឬផលិតផលគីមីកសិកម្ម ដែលមានប្រើប្រាស់ អង្គធាតុធាតុគីមីថ្មី បើសិនជាការបង្កើតទិន្នន័យខាងលើនេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ។

២- ក្នុងកំឡុងពេល ៥ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានវិញ្ញាបនប័ត្រអនុញ្ញាតិឱ្យ ចែកចាយលក់ផលិតផលឱសថ ឬផលិតផលគីមីកសិកម្មដែលមានអង្គធាតុធាតុគីមីថ្មី ក្រសួងទទួលបន្ទុក មិនត្រូវផ្តល់ការយល់ព្រមទៅលើពាក្យស្នើសុំវិញ្ញាបនប័ត្រអនុញ្ញាត្តិឱ្យចែកចាយលក់របស់បុគ្គលម្នាក់ផ្សេង ទៀត ដែលបានប្រើប្រាស់ទិន្នន័យដែលទទួលបានការពារស្របតាមកថាខ័ណ្ឌទី ១ ខាងលើ ដោយគ្មាន ការយល់ព្រមពីអ្នកដាក់ពាក្យស្នើសុំដើមឡើយ ។ នៅពេលប្រើក្នុងកថាខ័ណ្ឌនេះ ពាក្យថា "វិញ្ញាបនប័ត្រ អនុញ្ញាត្តិឱ្យចែកចាយលក់នៅលើទីផ្សារ" សំដៅទៅលើវិញ្ញាបនប័ត្រណាមួយ ដែលអនុញ្ញាត្តិឱ្យចែកចាយ លក់ផលិតផលឱសថ ឬផលិតផលគីមីកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣- ក្រសួងទទួលបន្ទុក មិនត្រូវបង្ហើបបង្ហាញទិន្នន័យដែលចែងក្នុងកថាខ័ណ្ឌទី ១ ខាងលើនេះ ឡើយ លើកលែងតែក្នុងករណីខាងក្រោម:

ក- ក្នុងករណីចាំបាច់ដើម្បីការពារផលប្រយោជន៍សាធារណៈ ប៉ុន្តែការបង្ហើបបង្ហាញណាមួយ ត្រូវកំរិតត្រឹមតែផ្នែកនៃទិន្នន័យដែលចាំបាច់សំរាប់គោលដៅនេះតែប៉ុណ្ណោះ ។ និង

ខ- តែក្នុងករណីដែលមានចាត់វិធានការធានាថា ទិន្នន័យទាំងនោះ នឹងទទួលបានការការពារ ទល់នឹងការប្រើប្រាស់ក្នុងពាណិជ្ជកម្មដោយមិនស្មោះត្រង់ ។

៤-	យោងតាមមាត្រា ៤ និង ១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនប័ត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម មុននឹងចេញវិញ្ញាបនប័ត្រអនុញ្ញាតិ្តឱ្យចែកចាយលក់ផលិតផលឱសថ ឬ ផលិតផលគីមីកសិកម្ម ក្រសួងទទួលបន្ទុក ត្រូវធ្វើការស្រាវជ្រាវរកប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ឱ្យដោយព្រះរាជាណាចក្រកម្ពុជា ហើយក្នុងករណីមានប្រកាសនីយបត្រតក្កកម្មណាមួយ ដែលទាក់ទិនទៅនឹងផលិតផលឱសថ ឬ ផលិតផលគីមីកសិកម្ម ត្រូវបានចេញឱ្យទៅបុគ្គលណាម្នាក់ក្រៅពីអ្នកដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្រអនុញ្ញាតិ្តឱ្យចែកចាយលក់រួចហើយ ពាក្យសុំវិញ្ញាបនប័ត្រអនុញ្ញាតិ្តឱ្យចែកចាយលក់ខាងលើនេះ នឹងមិនត្រូវបានគេយកពិចារណាផ្តល់ជូនទេ រហូតដល់កាលបរិច្ឆេទផុតសុពលភាពនៃប្រកាសនីយបត្រតក្កកម្មមួយនោះ ។

៥- ទោះបីជាមានបទប្បញ្ញតិចែងក្នុងកថាខ័ណ្ឌទី ១ ទី ២ និង ទី ៤ នៃមាត្រានេះក្តី ក្រសួងទទួលបន្ទុក ត្រូវបានទទួលការអនុញ្ញាតិឱ្យប្រើទិន្នន័យនៃការពិសោធន៍ព្យាបាល និង ទិន្នន័យដ៏ទៃទៀតដែលបានដាក់ជូនឱ្យពិនិត្យដោយបុគ្គលណាម្នាក់ នៅពេលផ្តល់ឱ្យនូវអាជ្ញាប័ណ្ណបង្ខំ ឬអាជ្ញាប័ណ្ណមិនស្ម័គ្រចិត្តសំរាប់ផលិតផលឱសថ ឬ ផលិតផលគីមីកសិកម្មណាមួយ ដោយអនុលោមតាមផ្នែកទី ៣ នៃច្បាប់នេះ។

## ផ្នែកទី ៣
## បទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាប័ណ្ណបង្ខំសំរាប់ការនាំចូល
## សេចក្តីប្រកាសទីក្រុង ដូហា ស្តីពីសុខភាព

### មាត្រា ៧_. គោលបំណង

ផ្នែកទី ៣ នៃច្បាប់នេះ នឹងផ្តល់សុពលភាពដល់បទប្បញ្ញត្តិស្តីពីប្រទេសនាំចូល ដែលមានចែងនៅក្នុងសេចក្តីសម្រេចស្តីពីការអនុវត្តកថាខ័ណ្ឌទី ៦ នៃសេចក្តីប្រកាស ទីក្រុង ដូហា ស្តីពីកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា និង សុខភាពសាធារណៈ ដែលអនុម័តដោយអគ្គក្រុមប្រឹក្សារបស់អង្គការពាណិជ្ជកម្មពិភពលោក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៣ ។

## មាត្រា ៨.. និយមន័យ

នៅក្នុងផ្នែកទី ៣ និង ទី ៤ នៃច្បាប់នេះ:

ក- "សេចក្ដីសម្រេច" មានន័យថាជាសេចក្ដីសម្រេចស្ដីពីការអនុវត្តន៍កថាខណ្ឌទី ៦ នៃសេចក្ដីប្រកាស ទីក្រុង ដូហា ស្ដីពីកិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា និង សុខភាពសាធារណ: ដែលអនុម័តដោយអគ្គក្រុមប្រឹក្សាអង្គការពាណិជ្ជកម្មពិភពលោក ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៣ ។

ខ-"ប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល" គឺជា

១-ប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដែលមានការអភិវឌ្ឍន៍តិចតួច ។

២-ប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកណាមួយ ដែលបានជូនដំណឹងជាលាយល័ក្ខណអក្សរទៅក្រុមប្រឹក្សាទទួលបន្ទុកកិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា អំពីបំណងរបស់ខ្លួនក្នុងការប្រើប្រាស់ប្រព័ន្ធជាប្រទេសនាំចូល ដូចដែលមានចែងនៅក្នុងសេចក្ដីសម្រេច ។ និង

៣-ប្រទេសណាមួយ ដែលមិនមែនជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ប៉ុន្តែបានផ្ដល់ការបង្ហាញតាមការទូតជូនទៅរដ្ឋមន្ត្រីថា ខ្លួននឹងអនុវត្តតាមប្រព័ន្ធនេះ ហើយបានដាក់ផ្សាយនៅក្នុងគេហទំព័រសាធារណៈមួយនូវការជូនដំណឹងដែលតម្រូវក្នុងចំណុច (ខ) នៃកថាខ័ណ្ឌទី ១ និង ចំណុច (ក) នៃកថាខណ្ឌទី ២ នៃសេចក្ដីសម្រេច ។

គ- "រដ្ឋមន្ត្រី" រួមមានរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬរដ្ឋមន្ត្រីដ៏ទៃទៀតណាម្នាក់ ដែលត្រូវបានចាត់តាំងដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងគោលដៅផ្ដល់សុពលភាពដល់ផ្នែកនេះ ត្រូវមានសិទ្ធិអំណាចអនុញ្ញាតការនាំចូលក្រោមមាត្រា ១០ ។

ឃ-"ផលិតផលឱសថ" គឺជាផលិតផលដែលទទួលបានប្រកាសនីយបត្រតក្កកម្មណាមួយ ឬជាផលិតផលដែលត្រូវផលិតក្រោមដំណើការផលិតដែលទទួលបានប្រកាសនីយបត្រតក្កកម្មក្នុងវិស័យឱសថសាស្ត្រ ដែលត្រូវការដើម្បីដោះស្រាយបញ្ហាសុខភាពសាធារណៈ ដែលបានទទួលស្គាល់នៅក្រោមសេចក្តីប្រកាសស្តីពីកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា និង សុខភាពសាធារណៈ ដែលបានអនុម័តនៅទីក្រុង ដូហា នៃប្រទេស កាតា ។

ង- "ប្រព័ន្ធ" គឺជាដំណើការ និង/ឬ វិធានការ ដែលមានចែងកំណត់ក្នុងសេចក្តីសម្រេច ។

ច- "ប្រទេសជាសមាជិក" គឺជាប្រទេសសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ។

## មាត្រា ៩~. ការពន្យាការអនុវត្តន៍ប្រកាសនីយបត្រតក្កកម្មឱសថ

មាត្រា ៤ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចែងថា ផលិតផលឱសថ មិនត្រូវបានការការពារដោយប្រកាសនីយបត្រតក្កកម្ម រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ យោងតាមសេចក្តីប្រកាសស្តីពីកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា និងសុខភាពសារធារណៈនៃសន្និសិទ្ទថ្នាក់រដ្ឋមន្ត្រីរបស់អង្គការពាណិជ្ជកម្មពិភពលោក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុង ដូហា នៃប្រទេស កាតា ។ ដោយយោងតាមផ្នែកទី ១ និង ផ្នែកទី២ នៃច្បាប់នេះ រដ្ឋមន្ត្រីអាចអនុញ្ញាតអោយធ្វើការនាំចូលផលិតផលឱសថមកក្នុងព្រះរាជាណាចក្រកម្ពុជា រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ តាមខ្លឹមសារ និង លក្ខខណ្ឌអ្វីមួយក៏ដោយ តែគ្មានត្រូវបង់ថ្លៃឈ្នួល ។

## មាត្រា ១០~. អាជ្ញាប័ណ្ណ

(ក) - ដោយគ្មានកំហិតទៅលើខ្លឹមសារទូទៅនៃមាត្រា ៩ ខាងលើ ពាក្យស្នើសុំរបស់:

១- បុគ្គលណាម្នាក់មុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ដែលមានបំនងនាំចូលផលិតផលឱសថ ស្របទៅតាមសេចក្តីសម្រេចដើម្បីបំពេញតាមរាល់ការតំរូវតាមផ្លូវច្បាប់នៃប្រទេសនាំចេញ ឬដោយមានហេតុផលដ៏ទៃទៀតណាមួយ ។ ឬ

២-បុគ្គលណាម្នាក់ក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ដែលសុំការអនុញ្ញាតិនាំចូលផលិតផលឱសថក្រោមប្រកាសនីយបត្រតក្កកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ឬ ក្រោមប្រកាសនីយបត្រតក្កកម្ម ក្នុងប្រទេសជាសមាជិកណាមួយ ដែលមានសក្តានុពលនាំចេញ

រដ្ឋមន្ត្រីអាចផ្តល់អាជ្ញាប័ណ្ណ (ហៅកាត់ថា "អាជ្ញាប័ណ្ណ") ជូនដល់បុគ្គលនោះ (ហៅកាត់ថា "អ្នកទទួលអាជ្ញាប័ណ្ណ") ដើម្បីនាំចូលផលិតផលឱសថទាំងឡាយនោះ ពីប្រទេសនាំចេញជាសមាជិកមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនចាំបាច់ទទួលការយល់ព្រមពីម្ចាស់សិទ្ធិប្រកាសនីយបត្រតក្កកម្ម តែត្រូវគោរពតាមការអនុញ្ញាតិរបស់ប្រទេសនាំចេញជាសមាជិក ។

ខ-អាជ្ញាប័ណ្ណត្រូវមានឈ្មោះរបស់ផលិតផលឱសថនោះ និង ការប៉ាន់ស្មានបរិមាណនៃផលិតផលឱសថ ដែលត្រូវនាំចូលក្នុងអណត្តិនៃអាជ្ញាប័ណ្ណ ក៏ប៉ុន្តែការប៉ាន់ស្មាននេះ អាចធ្វើក្រោមទម្រង់អ្វីក៏បាន (រួមទាំងតែគ្មានក៏រិតតែចំពោះ ចំនួនឱសថដែលត្រូវការ ឬចំនួនអ្នកជំងឺ ដែលតម្រូវអោយទទួលថ្នាំព្យាបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា) ហើយការប៉ាន់ស្មានដែលត្រូវផ្តល់ឱ្យនេះ មិនត្រូវក៏រិតលើបរិមាណនៃផលិតផលឱសថដែលត្រូវការជាចាំបាច់នៅក្នុងព្រះរាជាណាចក្រម្ពុជា ក្នុងការដោះស្រាយបញ្ហាសុខភាពសាធារណៈដែលផលិតផលឱសថទាំងនោះត្រូវបានគ្រោងដោះស្រាយបញ្ហាឡើយ ។

គ-រដ្ឋមន្ត្រីអាចកំណត់ថាៈ (១) មានស្ថានភាពគ្រោះអាសន្ន ឬ ស្ថានភាពជាបន្ទាន់បំផុតសំរាប់ជាតិកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាក់ទិនទៅនឹងបញ្ហាសុខភាពសាធារណៈ ដែលការនាំចូលបានស្នើសុំត្រូវបានគ្រោងសំដៅដើម្បីដោះស្រាយបញ្ហា ឬ (២) ការនាំចូលដែលបានស្នើសុំ ត្រូវបានគ្រោងក្នុងគោលដៅ

បរិវេសាធារណៈមិនមែនពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រោយពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ និង ទោះបីជាមានបទប្បញ្ញត្តិអ្វីផ្ទុយថែងក្នុងច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្មក្តី ហើយប្រសិនបើរដ្ឋមន្ត្រីកំណត់បែបនោះ រាល់ការតំរូវសម្រាប់ការចរចារជាមុនសម្រាប់អាជ្ញាប័ណ្ណ រវាងអ្នកដាក់ពាក្យសុំជាមួយនឹងម្ចាស់សិទ្ធិប្រកាសនីយបត្រតក្កកម្ម ត្រូវតែលើកលែងចោល ។ នៅក្នុងករណីនេះ រដ្ឋមន្ត្រីត្រូវកត់ត្រាបញ្ហានេះចូលក្នុងអាជ្ញាប័ណ្ណអោយច្បាស់ ដើម្បីអាចឱ្យអាជ្ញាធរនៃប្រទេសនាំចេញជាសមាជិកនោះ អាចយកមកធ្វើជាមូលដ្ឋានបាន ។

## មាត្រា ១១_. ការជូនដំណឹងទៅអង្គការពាណិជ្ជកម្មពិភពលោក

មុននឹងចាប់ផ្តើមធ្វើការនាំចូលក្រោមអាជ្ញាប័ណ្ណ រដ្ឋមន្ត្រីត្រូវជូនដំណឹងទៅក្រុមប្រឹក្សាទទួលបន្ទុកកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញារបស់អង្គការពាណិជ្ជកម្មពិភពលោកអំពីៈ

ក- ការផ្តល់ឱ្យ ឬ មានបំណងផ្តល់ឱ្យនូវអាជ្ញាប័ណ្ណបង្ខំ ឬអាជ្ញាប័ណ្ណប្រើប្រាស់សំរាប់រដ្ឋាភិបាល ដោយអនុលោមតាមបទប្បញ្ញត្តិនានានៃសេចក្តីសម្រេច ។ និង

ខ- ឈ្មោះរបស់ផលិតផលឱសថ និងការប៉ាន់ស្មានបរិមាណនៃផលិតផលឱសថ ដែលរំពឹងថានឹងនាំចូលក្រោមអាជ្ញាប័ណ្ណ ។

## មាត្រា ១២_. គ្មានកំណត់ថ្លៃឈ្នួលត្រូវបង់

មុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ អាជ្ញាប័ណ្ណដែលបានផ្តល់ឱ្យស្របតាមផ្នែកទី ៤ នៃច្បាប់នេះ មិនត្រូវជាកម្មវត្ថុនៃការបង់ថ្លៃឈ្នួល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងផលិតផលឱសថ ដែលបាននាំចូលឡើយ ។

ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ តទៅ អាជ្ញាប័ណ្ណដែលបានផ្តល់ឱ្យស្របតាមផ្នែកទី ៤ នៃច្បាប់នេះ មិនត្រូវជាកម្មវត្ថុនៃការបង់ថ្លៃឈ្នួលជូនទៅម្ចាស់សិទ្ធិប្រកាសនីយបត្រតក្កកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងផលិតផលឱសថ ដែលបានបង់ថ្លៃឈ្នួលនៅក្នុងប្រទេសនាំចេញជាសមាជិកស្របតាមកថាខ័ណ្ឌទី ៣ នៃសេចក្តីសម្រេចរួចមកហើយ ។

## មាត្រា ១៣~. វិញ្ញាបនប័ត្រអនុញ្ញាត្តិឱ្យចែកចាយលក់

ទោះបីមានបទប្បញ្ញត្តិចែងក្នុងផ្នែកទី ១ និង ផ្នែកទី ២ នៃច្បាប់នេះក្តី អាជ្ញាប័ណ្ណដែលផ្តល់ឱ្យអនុលោមតាមផ្នែកទី ៤ ត្រូវអនុញ្ញត្តិឱ្យរដ្ឋមន្ត្រីផ្តល់ការអនុញ្ញត្តិលើវិញ្ញាបនប័ត្រអនុញ្ញាត្តិឱ្យចែកចាយលក់ជាបន្ទាន់ និងការចុះបញ្ជីផលិតផលឱសថជាកម្មវត្ថុនោះ ។ បទប្បញ្ញត្តិនេះ មិនត្រូវប៉ះពាល់ដល់ការតំរូវនានារបស់ក្រសួងសុខាភិបាល ពាក់ព័ន្ធនឹងការវាយតម្លៃគុណភាព សុវត្ថិភាព និង ប្រសិទ្ធិភាពនៃផលិតផលឱសថទៅតាមវិធីអ្វីមួយដែលអាចកំណត់ដោយរដ្ឋមន្ត្រី ឬក្រសួងសុខាភិបាល ។

# ផ្នែកទី ៤
# បទប្បញ្ញត្តិស្តីពីការផ្តល់អាជ្ញាប័ណ្ណបង្ខំសំរាប់ការនាំចេញ
# សេចក្តីប្រកាសទីក្រុង ដូហា ស្តីពីសុខភាព

## មាត្រា ១៤~. គោលបំណង

ផ្នែកទី ៤ នៃច្បាប់នេះ នឹងផ្តល់សុពលភាពដល់បទប្បញ្ញាត្តិស្តីពីប្រទេសនាំចេញ ដែលមានចែងនៅក្នុងសេចក្តីសម្រេចស្តីពីការអនុវត្តកថាខ័ណ្ឌទី ៦ នៃសេចក្តីប្រកាសទីក្រុង ដូហា ស្តីពីកិច្ចព្រមព្រៀង

ស្ដីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា និង សុខភាពសាធារណៈ ដែលបានអនុម័ត ដោយអគ្គក្រុមប្រឹក្សារបស់អង្គការពាណិជ្ជកម្មពិភពលោក ចុះថ្ងៃទី៣0 ខែ សីហា ឆ្នាំ ២00៣ ។

## មាត្រា ១៥-. អាជ្ញាប័ណ្ណ

ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ តទៅ និង យោងទៅតាមបទប្បញ្ញត្តិនៃផ្នែកទី ៤ នៃច្បាប់នេះ ស្ដីពីការដាក់ពាក្យស្នើសុំរបស់បុគ្គលណាម្នាក់(ហៅកាត់ថា"អ្នកដាក់ពាក្យស្នើសុំ") រដ្ឋមន្ត្រី អាចផ្ដល់អាជ្ញាបណ្ណ័ (ហៅកាត់ថា "អាជ្ញាប័ណ្ណ") ទៅអោយបុគ្គលនោះ (ហៅកាត់ថា "ម្ចាស់អាជ្ញាប័ណ្ណ") ឱ្យប្រើប្រាស់កម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្ម ដែលពាក់ពន្ធ័នឹងផលិតផលឱសថ ឬ ផលិតផល រួមទាំង ដំណើការដែលទទួលបានប្រកាសនីយបត្រតក្កកម្ម ដែលពាក់ពន្ធ័នឹងផលិតផលឱសថ ឬ ផលិតផលផងដែរ ក្នុងគោលបំណងផលិត ប្រើប្រាស់ (គិតទាំងការពិសោធន៏នៅក្រៅស្រុក និង ក្នុងស្រុក និងការអនុញ្ញាត តាមច្បាប់) ការដាក់តាំង សម្រាប់លក់ឬនាំចេញ ការផ្គត់ផ្គង់សំរាប់នាំចេញ និងការនាំចេញផលិតផលឱសថ ទាំងនោះ ទៅកាន់ប្រទេសជាសមាជិក ដែលមានសិទ្ធិនាំចូលណាមួយ ។

## មាត្រា ១៦-. ពាក្យស្នើសុំ

ក-ពាក្យស្នើសុំ ត្រូវមានគ្រប់ព័ត៌មានចាំបាច់ទាំងអស់ ទៅតាមការកំណត់របស់រដ្ឋមន្ត្រី ដែលបង្ហាញ ថា រាល់ការតំរូវទាំងអស់ក្នុងផ្នែកនេះ ត្រូវបានបំពេញ ឬនឹងត្រូវបំពេញ។

ខ-ពាក្យស្នើសុំ អាចមានទាំងការបង្ហាញរបស់ប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល ឬប្រទេស ណាមួយថា គេត្រូវការផលិតផលឱសថ ដើម្បីដោះស្រាយគ្រោះអាសន្នរបស់ជាតិ ឬស្ថានភាពបន្ទាន់បំផុត ដ៏ទៃទៀត ឬសម្រាប់បំរើសាធារណៈមិនមែនបែបលក្ខណៈពាណិជ្ជកម្មទេ ។ នៅក្នុងករណីនេះ ពាក្យស្នើសុំ នឹងត្រូវសន្មត់ថា ស្ថានភាពទាំងនោះ កំពុងកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅដើម្បី

ឱ្យមាននីតិវិធីក្នុងការផ្តល់អាជ្ញាប័ណ្ណសម្រាប់អនុវត្ត ក្នុងចំណោមនីតិវិធីទាំងនោះ មានទាំងការលើកលែងចោលនូវការតំរូវឱ្យមានការចរចារជាមុនរវាងអ្នកដាក់ពាក្យស្នើសុំជាមួយនឹងម្ចាស់ប្រកាសនីយបត្រតក្កកម្ម ។

គ-ប្រសិនបើពាក្យស្នើសុំត្រូវបានដាក់ជូនពិនិត្យ ដោយឬក្នុងនាមនៃប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល ឬប្រទេសណាមួយ ពេលនោះរដ្ឋមន្ត្រីអាចសន្មត់ថា ផលិតផលឱសថជាកម្មវត្ថុនៅក្នុងពាក្យស្នើសុំនោះ គឺជាតំរូវការចាំបាច់ សម្រាប់ដោះស្រាយតំរូវការខាងសុខភាពសាធារណៈរបស់ប្រទេសជាសមាជិក ឬ ប្រទេសណាមួយនោះ ។ ក្នុងករណីដែលពាក្យស្នើសុំ មិនត្រូវបានដាក់ជូនដោយ ឬក្នុងនាមនៃអាជ្ញាធររបស់រដ្ឋាភិបាលនៃប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល ឬប្រទេសណាមួយ ក៏ប៉ុន្តែបើសិនអ្នកដាក់ពាក្យស្នើសុំ អាចបង្ហាញនូវភស្តុតាងថា ការផ្តល់អាជ្ញាប័ណ្ណបង្ខំមកខ្លួនដោយ ប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល ឬប្រទេសណាមួយនោះ ជាភស្តុតាងមានលក្ខណៈគ្រប់គ្រាន់ ក្នុងការគាំទ្រអ្នកដាក់ពាក្យស្នើសុំបែបនោះ ពេលនោះរដ្ឋមន្ត្រីអាចសន្មត់ថា ផលិតផលឱសថជាកម្មវត្ថុ នៅក្នុងពាក្យស្នើសុំនោះ គឺជាតំរូវការចាំបាច់ សម្រាប់ដោះស្រាយតំរូវការសុខភាពសាធារណៈរបស់ ប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល ឬប្រទេសណាមួយនោះ ។ និង

ឃ-បើសិនជាប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល មិនមែនជាប្រទេសសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកដែលមានការអភិវឌ្ឍន៍តិចតួចទេ ពាក្យស្នើសុំត្រូវមានដាក់ភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃសេចក្តីជូនដំណឹងរបស់ប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូលនោះ ជូនអង្គការពាណិជ្ជកម្មពិភពលោក អំពីបំណងរបស់ខ្លួនក្នុងការអនុវត្តន៏តាមប្រព័ន្ធជាប្រទេសនាំចូល ។

### មាត្រា ១៧~. លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

ក-បរិមាណនៃផលិតផលឱសថក្រោមអាជ្ញាប័ណ្ណ ត្រូវកំហិតត្រឹមតែចំនួនចាំបាច់ ដើម្បីដោះស្រាយតំរូវការនៃប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល និងប្រទេសណាមួយ គិតទាំងសម្រាប់យកទៅប្រើក្នុងផលិតកម្មដែលធ្វើឡើងក្នុងគោលដៅនៃការពិសោធន៏ និងក្នុងការពិនិត្យផ្ដល់ការអនុញ្ញាតតាមផ្លូវច្បាប់ ។ ការនាំចេញផលិតផលឱសថដែលធ្វើឡើងក្រោមអាជ្ញាប័ណ្ណ ត្រូវកំរិតតែសម្រាប់ប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល ឬប្រទេសណាមួយ និងប្រទេសជាច្រើន ដែលស្វះស្វែងរកការពិសោធន៏ ឬការអនុញ្ញាតិតាមផ្លូវច្បាប់តែប៉ុណ្ណោះ ។

ខ-ផលិតផលឱសថទាំងអស់ដែលនាំចេញក្រោមអាជ្ញាប័ណ្ណ ត្រូវមានកំណត់អត្តសញ្ញាណអោយច្បាស់ដោយពាក់ស្លាកសញ្ញា និងសញ្ញាសំគាល់ ថាជាផលិតឱសថស្ថិតនៅក្រោមប្រព័ន្ធ ។ ផលិតផលឱសថដែលបាននាំចេញ ត្រូវបង្ហាញនូវលក្ខណៈខុសផ្លែកពីគេ ដោយការវេចខ្ចប់ជាពិសេស និង/ឬការដាក់ពណ៌ និងការកំណត់រូបរាងនៃផលិតផលខ្លួនឯង ក៏ប៉ុន្តែការធ្វើឱ្យមានលក្ខណៈខុសផ្លែកបែបនេះគឺគួរតែធ្វើតាមដែលអាចធ្វើទៅកើត ហើយមិនត្រូវប៉ះពាល់ខ្លាំងទៅលើតម្លៃផលិតផលឡើយ ។ និង

គ-មុនពេលបញ្ជូនផលិតផលឱសថសម្រាប់ធ្វើការនាំចេញ អ្នកទទួលអាជ្ញាប័ណ្ណត្រូវដាក់ផ្សាយនៅលើគេហទំព័ររបស់ខ្លួន ឬ គេហទំព័រណាមួយដែលបង្កើតឡើងដោយអង្គការពាណិជ្ជកម្មពិភពលោកសម្រាប់គោលដៅនេះ អំពីៈ

១-បរិមាណនៃផលិតផលឱសថ ដែលនឹងត្រូវផ្គត់ផ្គង់ទៅគោលដៅនីមួយៗ ។ និង

២-លក្ខណៈខុសផ្លែកពីគេ ដូចដែលតំរូវឱ្យធ្វើក្រោមចំណុច (ខ) នៃផ្នែកទី ៤ ខាងលើ ។

Comment [LS1]: Find the one which is correct. Where refer to section 4 (b)?

**មាត្រា ១៨.. ការជូនដំណឹង**

រដ្ឋមន្ត្រី ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញា ឬធ្វើយ៉ាងណាឱ្យក្រុមប្រឹក្សាទទួលបន្ទុកលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទិននឹងទិដ្ឋភាពនៃសិទ្ធិលើកម្មសិទ្ធិបញ្ញាបានទទួលការជូនដំណឹង តាមរយៈបណ្តាញទំនាក់ទំនងសមស្របមួយ អំពីអាជ្ញាប័ណ្ណដែលបានផ្តល់ឱ្យ ក្រោមផ្នែកទី ២ នេះ ។ សេចក្តីជូនដំណឹងនេះត្រូវមាន:

ក-ឈ្មោះ និង អាសយដ្ឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណ

ខ-ផលិតផលឱសថ ដែលអាជ្ញាប័ណ្ណផ្តល់ឱ្យ

គ-បរិមាណផលិតផលឱសថ ដែលអាជ្ញាប័ណ្ណផ្តល់ឱ្យ

ឃ-ប្រទេសដែលផលិតផលឱសថនឹងត្រូវនាំចេញ

ង-អណត្តិនៃអាជ្ញាប័ណ្ណ

ច-អាសយដ្ឋានគេហទំព័រ សម្រាប់អ្នកទទួលអាជ្ញាប័ណ្ណចុះផ្សាយព័ត៌មានដែលតម្រូវដោយសេចក្តីសម្រេច និង

ង-លក្ខខណ្ឌដទៃទៀតដែលភ្ជាប់ជាមួយនឹងអ្នកទទួលអាជ្ញាប័ណ្ណ ។

**មាត្រា ១៩៉. ការកំណត់ថ្លៃឈ្នួល**

ក្នុងការកំណត់ថ្លៃឈ្នួលជូនម្ចាស់ប្រកាសនីយបត្រតក្កកម្ម ស្របតាមមាត្រា ១២ ខាងលើ និង មាត្រា ៥៧ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម

ដែលពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណណាមួយដែលផ្តល់ឱ្យក្រោមមាត្រា (២) រដ្ឋមន្ត្រីត្រូវគិតពិចារណាដល់តម្លៃសេដ្ឋកិច្ចនៃការផ្តល់ការអនុញ្ញាតទៅឱ្យប្រទេសជាសមាជិកដែលមានសិទ្ធិនាំចូល និងប្រទេសណាមួយ ។

**មាត្រា ២០.. វិញ្ញាបនប័ត្រអនុញ្ញាត្តិឱ្យចែកចាយលក់**

ទោះបីជាមានបទប្បញ្ញត្តិផ្ទុយណាមួយចែងក្នុងផ្នែកទី ១ និង ផ្នែកទី ២ នៃច្បាប់នេះក្តី ពាក់ព័ន្ធទៅនឹងការការពារទិន្នន័យដែលបានដាក់ជូនពិនិត្យសម្រាប់គោលដៅតាមផ្លូវច្បាប់ ការចុះបញ្ជី ឬការអនុញ្ញាតឱ្យចែកចាយលក់នូវផលិតផលឱសថ ក្រោមអាជ្ញាប័ណ្ណមួយ មិនត្រូវបានរារាំង ឬបង្អាក់ដំណើរ ឬពន្យាពេល ដោយសារតែការទាមទារសិទ្ធិលើទិន្នន័យ ឬសិទ្ធិផ្តាច់មុខលើទីផ្សារ ដែលសំអាងទៅលើការដាក់ជូននូវទិន្នន័យតាមផ្លូវច្បាប់របស់ម្ចាស់ប្រកាសនីយបត្រតក្កកម្ម (ការសម្ងាត់ ឬទិន្នន័យផ្សេងទៀត) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬតំបន់ផ្សេងទៀត ។ បទប្បញ្ញត្តិនេះ មិនត្រូវប៉ះពាល់ដល់ការតំរូវនានារបស់ក្រសួងសុខាភិបាល ពាក់ព័ន្ធនឹងការវាយតម្លៃគុណភាព សុវត្ថិភាព និង ប្រសិទ្ធិភាពនៃផលិតផលឱសថឡើយ ។

**មាត្រា ២១.. ការលប់ចោលអាជ្ញាប័ណ្ណ**

អំណាចក្នុងការពិនិត្យឡើងវិញ និងលុបចោលអាជ្ញាប័ណ្ណ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រី ។ សិទ្ធិសុំពិនិត្យឡើងវិញតាមផ្លូវតុលាការទៅលើនិរន្តភាពជាបន្តនៃអ្នកទទួលអាជ្ញាប័ណ្ណ មិនអាចធ្វើទៅបានឡើយ លើកលែងតែរដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចជាដំបូង ទៅលើសំណើសុំឱ្យលុបអាជ្ញាប័ណ្ណចោល ។

## ផ្នែកទី ៥
## ការសម្ងាត់ពាណិជ្ជកម្ម

## មាត្រា ២២.. និយមន័យ

ក្នុងច្បាប់នេះ ពាក្យ:

"មានលក្ខណៈផ្ទុយទៅនឹងការអនុវត្តពាណិជ្ជកម្មដោយស្មោះត្រង់" មានន័យថា យ៉ាងហោចណាស់ជាការប្រព្រឹត្ត ដូចជាការរំលោភបំពានលើកិច្ចសន្យា ការរំលោភបំពានលើការរក្សាការសម្ងាត់ និង ការសមគំនិតក្នុងការរំលោភបំពាន រួមទាំងអំពើចារកិច្ចពាណិជ្ជកម្មដោយប្រើមធ្យោបាយអេឡិចត្រូនិច ឬមធ្យោបាយផ្សេងៗទៀត ព្រមទាំងការទទួលបាន ការបង្ហើបបង្ហាញ ឬការប្រើប្រាស់ព័ត៌មានសម្ងាត់ ដូចជាការសម្ងាត់ពាណិជ្ជកម្មធ្វើឡើងដោយតតីយជនដែលបានដឹង ឬមានការធ្វេសប្រហែសយ៉ាងធ្ងន់ធ្ងរបណ្តាលឱ្យខកខានមិនបានដឹងហើយថា ការប្រព្រឹត្តិបែបនេះមានពាក់ព័ន្ធទៅនឹងការទទួលបាន ការបង្ហើបបង្ហាញ ឬ ការប្រើប្រាស់នោះ។

"ការសម្ងាត់ពាណិជ្ជកម្ម" គឺជាព័តិមានដែលៈ

ក-សម្ងាត់នៅក្នុងន័យថា នៅក្នុងទំរង់ទាំងមូល ឬជារូបសណ្ឋានជាក់លាក់ និងបង្គុំសមាសភាពរបស់វា គេមិនទាន់បានដឹងស្គាល់ជាទូទៅក្នុងចំណោម ឬមិនងាយនឹងអាចធ្លាយឱ្យដឹងឮដល់បុគ្គលដែលស្ថិតនៅក្នុងជួរក្រុម ដែលជាធម្មតាទាក់ទិនទៅនឹងប្រភេទនៃព័តិមានបែបនេះ ។

ខ-មានតម្លៃពាណិជ្ជកម្មពិតប្រាកដ ឬតម្លៃពាណិជ្ជកម្មជាសក្តានុពល ដោយសារតែភាពជាសម្ងាត់របស់វា ។ និង

គ-ជាកម្មវត្ថុនៃជំហាននៃការរក្សាជាសម្ងាត់ដ៏សមស្របទៅតាមស្ថានភាព ដោយបុគ្គលដែលមានសិទ្ធិគ្រប់គ្រងពិត៍មាននោះ ដោយស្របច្បាប់ ។

"ព័តិមាន" សំរាប់គោលបំណងនៃការឱ្យនិយមន័យនៃការសម្ងាត់ពាណិជ្ជកម្ម "ព័តិមាន" រួមមានព័តិមានដែលបង្កើតបានជា ឬមាននៅក្នុង ឬរួមបញ្ចូលជា (ប៉ុន្តែមិនកម្រិតតែចំពោះ) រូបមន្ត គំរូ ផែនការ ឬផែនការ

ផលិតផល ការព្យាករណ៍ទីផ្សា យុទ្ធសាស្ត្រ បញ្ជីអតិថិជន ទិន្នន័យគណនីលក់ គិតទាំងបរិមាណលក់ របាយការណ៍ហិរញ្ញវត្ថុ បញ្ជីគណនេយ្យ ការចង់ក្រងអ្វីមួយ វិធីសាស្ត្រ បច្ចេកទេស ដំណើរការផលិតផលិតផល កម្មវិធីកំព្យូទ័រ មធ្យោបាយ ឬ យន្តការជាបច្ចេកទេល ឬមិនមែនបច្ចេកទេស ឬទិន្នន័យថ្លៃដើម ឬ គំនូសបង្ហាញ ឬ វិធីសាស្ត្រអាជីវកម្ម និង ប្រភពផ្គត់ផ្គង់វត្ថុធាតុដើម ។

"បុគ្គល" មានន័យថា រូបវន្តបុគ្គល ក្រុមហ៊ុន អាជីវកម្មទទួលភារៈគ្រប់គ្រង ក្រុមហ៊ុនជួញដូរដីធ្លី អង្គការ អណត្តិ ក្រុមហ៊ុនសហកម្មសិទ្ធិ សមាគម ក្រុមហ៊ុនរួមទុន រដ្ឋាភិបាល ភ្នាក់ងារ ឬស្ថាប័នរដ្ឋាភិបាល ឬ នីតិបុគ្គល ឬក្រុមហ៊ុនពាណិជ្ជកម្មផ្សេងទៀត ។

## មាត្រា ២៣៊.ចំណេះដឹងដែលទទួលបានក្នុងពេលបំពេញមុខងារ

គ្មានបទប្បញ្ញត្តិចែងក្នុងច្បាប់នេះ មានគោលដៅកំណត់ការទទួលខុសត្រូវ ចំពោះការទទួលបានការបង្កើបបង្ហាញ ឬការប្រើប្រាស់ព័ត៌មាន ដែលទទួលបានដោយបុគ្គលណាម្នាក់ ក្នុងពេលបំពេញមុខងាររបស់គាត់ ប្រសិនចំណេះដឹងដែលគាត់ទទួលបានបែបនោះ មានកំរិតមិនលើសពីអ្វីដែលជួយធ្វើឱ្យចំរើនខាងចំណេះដឹងផ្ទាល់ខ្លួន ឬជំនាញ ឬបទពិសោធន៍ ឬចំណេះពីការហ្វឹកហាត់របស់បុគ្គលតែប៉ណ្ណោះ ។

## មាត្រា ២៤៊. ការទទួលបានព័ត៌មានមិនស្របច្បាប់

១- បុគ្គលដែលកាន់កាប់ការសម្ងាត់ពាណិជ្ជកម្មស្របច្បាប់ មានសិទ្ធិចាត់វិធានការប្រឆាំងទល់នឹងបុគ្គលណាដែលទទួលបានការសម្ងាត់ពាណិជ្ជកម្មនោះដោយមិនស្របច្បាប់ ផ្ទុយទៅនឹងការអនុវត្តន៏ពាណិជ្ជកម្មដោយស្មោះត្រង់ ។

២- ការសម្ងាត់ពាណិជ្ជកម្មដែលទទួលបានមានលក្ខណៈមិនផ្ទុយទៅនឹងការអនុវត្តពាណិជ្ជកម្មដោយស្មោះត្រង់ បើសិនជាវាត្រូវបានបង្កើតឡើងដោយឯករាជ្យ ឬបានមកដោយវិស្វកម្មបញ្ច្រាស់ ។

## មាត្រា ២៥~. ការប្រើប្រាស់ ឬការបង្កើបបង្ហាញព័ត៌មានមិនស្របច្បាប់

បុគ្គលដែលកាន់កាប់ការសម្ងាត់ពាណិជ្ជកម្មស្របច្បាប់ មានសិទ្ធិចាត់វិធានការប្រឆាំងទល់នឹងបុគ្គលណាដែលបង្កើបបង្ហាញ ឬប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម មានលក្ខណៈផ្ទុយទៅនឹងការអនុវត្តពាណិជ្ជកម្មដោយស្មោះត្រង់ បើសិនជាអ្នកបង្កើបបង្ហាញ ឬអ្នកប្រើប្រាស់នោះ បានដឹង ឬគួរតែបានដឹងថា ខ្លួនគ្មានការអនុញ្ញាតស្របច្បាប់ អោយធ្វើការបង្កើបបង្ហាញ ឬប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មបែបនោះឡើយ ។

## មាត្រា ២៦~. ដីកាតុលាការ

១- ក្នុងករណីដែលតុលាការដែលកំពុងធ្វើចំនាត់ការ ក្រោមមាត្រា ២៤ និង មាត្រា ២៥ កំណត់បានថាបុគ្គលណាម្នាក់ដែលគ្មានការអនុញ្ញាតិពេញលក្ខណៈច្បាប់ ទទួលបាន ឬបង្កើបបង្ហាញ ឬប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម ផ្ទុយទៅនឹងការអនុវត្តន៏ពាណិជ្ជកម្មដោយស្មោះត្រង់ តុលាការអាចចាត់វិធានការណាមួយដូចខាងក្រោមៈ

ក-ចេញដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចជាអចិន្ត្រៃយ

ខ-បង្គាប់ឱ្យផ្តល់សំណងលើការខូចខាតជាក់ស្តែង

គ-បង្គាប់ឱ្យចុងចម្លើយផ្តល់ជូនដើមបណ្តឹងនូវគណនីទឹកប្រាក់នៃប្រាក់ចំណេញ ដែលខ្លួនបានចំណេញ ឬ នឹងទទួលចំណេញក្រោយមកទៀត ពីការទទួលបាន ការបង្កើបបង្ហាញ ឬការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មមិនស្របច្បាប់ ។ និង

ឃ- ចេញដីកាណាមួយផ្សេងទៀត ដែលតុលាការយល់ថាសមស្រប ។

២- នៅពេលដែលទទួលបានពាក្យស្នើសុំ តុលាការអាចលុបចោលដីកាសម្រេចបណ្តោះអាសន្ន បើសិនជាការសម្ងាត់ពាណិជ្ជកម្មនោះ ឈប់លែងមានភាពជាសម្ងាត់ទៀតហើយ ប៉ុន្តែដីកាបណ្តោះអាសន្ននោះ ក៏អាចរក្សានៅបន្តទៀត សម្រាប់រយៈពេលបន្ថែមទៀត ឬក្នុងអំឡុងពេល ដែលតុលាការពិចារណាឃើញថា សមស្របដើម្បីលុបបំបាត់ផលប្រយោជន៍ពាណិជ្ជកម្មណាមួយ ដែលចុងចម្លើយអាចទទួលបានពីការទទួលបាន ការបង្ហើបបង្ហាញ ឬការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្មមិនស្របច្បាប់បែបនោះ ។

៣- នៅពេលបង្គាប់ឱ្យផ្តល់សំណងលើការខូចខាតជាក់ស្តែង ដែលដើមបណ្តឹងបានទទួលរងការខូចខាត តុលាការត្រូវគិតដល់កត្តាខាងក្រោម:

ក- ការសាហ៊ុយចំណាយទៅលើការវិនិយោគដែលកើតឡើង ក្នុងពេលទទួលបាន សិរិតសំរាង និងការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម ។

ខ- បង្គាប់ឱ្យធ្វើការបង់ប្រាក់កំរៃជើងសារ ជំនួសសំណងលើការខាតបង់ប្រាក់ចំណេញរបស់ដើមបណ្តឹង ។

៤- តុលាការអាចបង្គាប់ឱ្យចុងចម្លើយបង់ជូនដើមបណ្តឹងនូវកំរៃសេវាមេធាវីដ៏សមរម្យមួយ ។

**មាត្រា ២៧_.ការទទួលបាន ការបង្ហើបបង្ហាញ ឬការប្រើប្រាស់ដោយស្មោះត្រង់**

បុគ្គលណាម្នាក់ ដែលទទួលបាន បង្ហើបបង្ហាញ ឬប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម ដោយស្មោះត្រង់ តែក្រោយមកបានដឹងថា បុគ្គលម្នាក់ទៀតដែលជាម្ចាស់សិទ្ធិលើផលប្រយោជន៍នៃការសម្ងាត់ពាណិជ្ជកម្ម

ត្រូវបានគេរំលោភសិទ្ធិដោយមិនស្របច្បាប់ បុគ្គលនោះ ឬ បុគ្គលដែលជាម្ចាស់សិទ្ធិលើផលប្រយោជន៍នោះ អាចស្នើសុំទៅតុលាការ ដើម្បីប្រកាសសិទ្ធិរបស់ភាគី ។

**មាត្រា ២៨_.សិទ្ធិការពារខ្លួន**

ក្នុងដំណើរការនិតិវិធីក្រោមច្បាប់នេះ ចុងចម្លើយមិនត្រូវទទួលខុសត្រូវចំពោះដើមបណ្តឹង បើសិនជាចុងចម្លើយអាចបំភ្លឺតុលាការបានថា ការផ្តោតការយកចិត្តទុកដាក់ទៅលើផលប្រយោជន៍សាធារណៈជាទូទៅមានឧត្តមភាពជាងការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម ជាពិសេសអាចបញ្ជាក់ថា ការបង្កើបបង្ហាញនោះមានសំអាងដោយហេតុផលនៃសុខភាព ឬ សុវត្ថិភាពសាធារណៈ ពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ ការតាក់តែង ឬការប្រើប្រាស់ការសម្ងាត់ពាណិជ្ជកម្ម ។

**មាត្រា ២៩_. រក្សាការពារការសម្ងាត់**

ក្នុងដំណើរការនីតិវិធីក្រោមច្បាប់នេះ តុលាការអាចចេញបញ្ជាគ្រប់ពេលទៅតាមការស្នើសុំបង្គាប់ឱ្យរក្សាការពារការសម្ងាត់ពាណិជ្ជកម្មដែលជាកម្មវត្ថុ ក្នុងអំឡុងពេលនៃដំណើការជំរះក្តី តាមរយៈមធ្យោបាយអ្វីមួយ ។

**មាត្រា ៣០_.ការបាត់បង់ការការពារការសម្ងាត់ពាណិជ្ជកម្ម**

អំឡុងពេលនៃការការពារការសម្ងាត់ពាណិជ្ជកម្ម អាចមានរយៈពេលយូរទៅតាមរយៈពេលដែលលក្ខខណ្ឌនៃនិយមន័យនៃការសម្ងាត់ពាណិជ្ជកម្មក្នុងមាត្រា ២២ នៅតែបន្តមានបែបនោះ ។

**មាត្រា ៣១_.ការប្រគល់សិទ្ធិលើការសម្ងាត់ពាណិជ្ជកម្ម**

បុគ្គលដែលកាន់កាប់ការសម្ងាត់ពាណិជ្ជកម្មស្របច្បាប់ អាចប្រគល់សិទ្ធិលើការសម្ងាត់ពាណិជ្ជកម្មមួយផ្នែកឬទាំងមូល និង ជាទូទៅឬកំហិតជាក់លាក់ទៅតាមតំបន់ និងផ្តល់ផលប្រយោជន៏នៃសិទ្ធិលើការសម្ងាត់ពាណិជ្ជកម្ម តាមរយៈអាជ្ញាប័ណ្ណ ឬវិធីផ្សេងទៀត ។

**មាត្រា ៣២~.ការផុតរលត់អាជ្ញាយុកាល**

បណ្តឹងដែលពាក់ព័ន្ធនឹងការទទួលបាន ឬបង្ហើបបង្ហាញ ឬប្រើប្រាស់ព័តិមានសម្ងាត់ ដែលផ្ទុយទៅនឹងការអនុវត្តន៏ពាណិជ្ជកម្មដោយស្មោះត្រង់ និងដោយគ្មានការអនុញ្ញាតិពេញច្បាប់ មានអាជ្ញាយុកាលរយៈពេលពីរ (២) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលការទទួលបាន ការបង្ហើបបង្ហាញ ការប្រើប្រាស់នោះត្រូវបានគេរកឃើញទៅតាមករណីរបស់វា ឬបើខិតខំយកចិត្តទុកដាក់ត្រឹមត្រូវ គួរតែបានរកឃើញ ។

**មាត្រា ៣៣~.ការដោះស្រាយវិវាទដ៏ទៃទៀត**

ភាគីនៃវិវាទដែលពាក់ព័ន្ធនឹងការសម្ងាត់ពាណិជ្ជកម្ម អាចព្រមព្រៀងគ្នាលើកទៅដោះស្រាយតាមរយៈការផ្សះផ្សា ឬសន្ធានកម្ម ឬមជ្ឈត្តកម្មនូវវិវាទណាមួយដែលបានកើតឡើង ឬអាចកើតឡើងរវាងគ្នាពាក់ព័ន្ធទៅនឹងព័តិមានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម ក្រោមវិសាលភាពនៃច្បាប់នេះ ដោយអនុលោមតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

3

ក្រសួងពាណិជ្ជកម្ម

3

# សេចក្តីព្រាង

# ច្បាប់

## ស្តីពី

# កិច្ចសន្យាពាណិជ្ជកម្ម

តុលា ឆ្នាំ ២០០៩

Shared By Chim Vanntha Laws Page

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._ គោលដៅ**

ច្បាប់នេះមានគោលដៅបង្កើតវិធានពិសេសនៃកិច្ចសន្យាពាណិជ្ជកម្មដែលអាចជួយពាណិជ្ជករកម្ពុជាក្នុងការអភិវឌ្ឍន៍និងបង្កភាពងាយស្រួលក្នុងទំនាក់ទំនាក់ពាណិជ្ជកម្ម ដើម្បីជម្រុញសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២._ វិសាលភាព**

ក- ច្បាប់នេះអនុវត្តចំពោះកិច្ចសន្យាដែលបានបង្កើតឡើងរវាង ៖
-ពាណិជ្ជករនិងពាណិជ្ជករនៅក្នុងវង្វង់សកម្មភាពពាណិជ្ជកម្មនានារបស់ខ្លួនប៉ុណ្ណោះ លើកលែងតែមាន បញ្ញត្តិចែងផ្សេងនៅក្នុងច្បាប់នេះ។
-រវាងពាណិជ្ជករជាមួយបេសកជនរបស់ស្ថានទូត កុងស៊ុល ភ្នាក់ងាររដ្ឋាភិបាលបរទេស អង្គការអន្តរជាតិឬមូលនិធិអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានាដែលបានបង្កើតឡើងនិងទទួលស្គាល់ដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ខ- ច្បាប់នេះមិនអនុវត្តចំពោះកិច្ចសន្យាណាដែលបានបង្កើតឡើងដោយ ៖
-ពាណិជ្ជករនិងពាណិជ្ជករក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន ឬក្នុងគ្រួសារ ទោះភាគីម្ខាងទៀតបានដឹងឬមិនបានដឹងក្តី។ កិច្ចសន្យានោះចាត់ទុកជាកិច្ចសន្យាពុំមានគោលបំណងផ្នែកពាណិជ្ជកម្មឡើយ។
-ពាណិជ្ជករនិងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្ថាប័នរដ្ឋាភិបាល ឬបុគ្គលដែលតែងតាំងដោយអាជ្ញាធរសាធារណៈ ដោយយោងតាមច្បាប់ និងបទដ្ឋានគតិយុត្តនានា ដែលនៅជាធរមាន។

គ- ក្នុងករណីដែលកិច្ចសន្យាពិសេសមិនបានចាត់ទុកជាកិច្ចសន្យាពាណិជ្ជកម្មដោយសារវាមិនស្ថិតក្នុងប្រភេទណាមួយដែលមានចែងនៅក្នុងជំពូកទី ៤ រហូតដល់ជំពូកទី១៣ ប៉ុន្តែវាត្រូវបានអនុវត្តដោយពាណិជ្ជករ បទប្បញ្ញត្តិនៃជំពូកទី ១ ជំពូកទី ២ ជំពូកទី ៣ ជំពូកទី១៤ និងជំពូក ទី ១៥ នៃច្បាប់នេះត្រូវអនុវត្តលើកិច្ចសន្យាពិសេសនោះ។

**មាត្រា ៣._ និយមន័យ**

ក្នុងខ្លឹមសារនៃច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមាននិយមន័យដូចខាងក្រោម ៖

ក- **កាតព្វកិច្ច** គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីររូបដោយអោយបុគ្គលម្នាក់ដែលបានកំណត់មានកាតព្វកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។ កាតព្វកិច្ចត្រូវបានបង្កើតឡើងដោយផ្អែកលើឆន្ទៈរបស់ភាគីនៃកិច្ចសន្យា ដើម្បីបង្កើតអានុភាពគតិយុត្តិ។

ខ- **កិច្ចសន្យា** គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រម បង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។

គ- **ពាណិជ្ជកម្ម** ត្រូវបានបកស្រាយឱ្យបានទូលាយដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះជាមានកិច្ចសន្យាឬគ្មានកិច្ចសន្យាក៏ដោយ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម មានជាអាទិ៍ ៖ កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយ តំណាងឬទីភ្នាក់ងារពាណិជ្ជកម្ម ការទិញលក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬសម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារនិងធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក ។

ឃ- **ពាណិជ្ជករ** គឺជារូបវន្តបុគ្គលដែលធ្វើពាណិជ្ជកិច្ចលក្ខណៈជាសហគ្រាសឯកបុគ្គល/រូបវន្តបុគ្គលពីរឬច្រើនរូប ឬនីតិបុគ្គលដែលធ្វើពាណិជ្ជកិច្ចមានលក្ខណៈជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ឬនីតិបុគ្គលដែលធ្វើពាណិជ្ជកិច្ចមានលក្ខណៈជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ឬក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

ង- **បុគ្គល**នៅក្នុងខ្លឹមសារនៃច្បាប់នេះនិងយោងតាមវិធានទូទៅនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែលនៅជាធរមាន អាចជារូបវន្តបុគ្គលដែលចុះកិច្ចសន្យាដោយផ្ទាល់ ឬជានីតិបុគ្គលដែលត្រូវចុះកិច្ចសន្យាតាមរយៈអ្នកតំណាងរបស់ខ្លួន។

ច- **មូលនិធិពាណិជ្ជកម្ម** ត្រូវបានកាន់កាប់ដោយពាណិជ្ជករណាម្នាក់ដែលរួមមាន ÷

- ចលនៈទ្រព្យ ដូចជាទំនិញនិងទ្រព្យអរូបីដែលបានចែងនៅក្នុងច្បាប់ ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ហើយត្រូវបានប្រើប្រាស់សម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម
- កម្មសិទ្ធិបញ្ញា
- សិទ្ធិលើចលនៈទ្រព្យ
- សិទ្ធិប្រត្យក្សលើអចលនៈទ្រព្យ (លើកលែងកម្មសិទ្ធិគ្មានពេលកំណត់)
- សិទ្ធិលើអតិថិជន
- សិទ្ធិលើការគ្រប់គ្រងនិងលើកម្មករ
- ភាគហ៊ុន និងភាគទុន និង
- រាល់សិទ្ធិ ឬទំនិញទាំងឡាយដែលបានរៀបរាប់ខាងលើ នៅពេលដែលត្រូវបានគេចាត់ទុកថាជាសិទ្ធិ ឬទំនិញក្នុងពេលអនាគត។

ឆ- **ករណីប្រធានសក្តិ**គឺករណីដែលទាក់ទងនឹងអគ្គីភ័យ សង្គ្រាម ចលាចលគ្រោះធម្មជាតិ អំពើរបស់អាជ្ញាធរសាធារណៈ ឬសកម្មភាព ឬហេតុការណ៍ដែលបណ្ដាលមកពីហឹង្សាក្នុងសង្គម ឬធម្មជាតិដែលមិនអាចអន្តរាគមន៍ដោយភ្នាក់ងារណាមួយដែលមិនអាចព្យាករណ៍ទុកមុន ឬទប់ទល់បាននិងមិនអាចព្យាយាមដោះស្រាយបាន។

ជ- **មជ្ឈត្តការឬវេទិការមជ្ឈត្តកម្ម** នៅក្នុងច្បាប់នេះត្រូវយោងទៅច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ឈ- **លិខិតយថាភូត**គឺជាលិខិតសាការី ឬឯកសារមួយ ដែលត្រូវបានបញ្ជាក់ដោយអាជ្ញាធរសាធារណៈដែលពាក់ព័ន្ធ ឬដោយបុគ្គលឬដោយស្ថាប័នដែលមានសមត្ថកិច្ចក្នុងគោលបំណងធ្វើជាភស្តុតាងបញ្ជាក់សុពលភាពរបស់វា និង/ឬ ជាភស្តុតាងសម្រាប់ប្រឆាំងទល់នឹងតតិយជន។

ញ- **ទំនិញ**គឺរាល់វត្ថុទាំងឡាយដែលផ្ញើចលនានៅពេលកំណត់អត្តសញ្ញាណរបស់វានៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម រួមមាន ÷ រ៉ែ កសិផល សាច់ឬសត្វ សម្ភារៈផ្គត់ផ្គង់ វត្ថុធាតុដើម ឬផលិតផលសម្រេច។

ដ- **ទ្រព្យ** គឺជាបណ្តុំនៃកម្មសិទ្ធិដែលរួមមានភាគហ៊ុនឬភាគទុន ទំនិញដែលជាទ្រព្យរូបីយ៍ និងអរូបីយ៍ដែលជាកម្មសិទ្ធិពិតប្រាកដនិងផ្ទាល់របស់ពាណិជ្ជករ។

ឋ- **ទ្រព្យរូបីយ៍** គឺជាទ្រព្យទាំងឡាយណាដែលមានរូបរាងច្បាស់លាស់ ទោះបីវាអាចជាទ្រព្យពិតប្រាកដឬផ្ទាល់ខ្លួនក្តី។

ឌ- **ទ្រព្យអរូបីយ៍** គឺជាទ្រព្យដែលត្រូវបានបង្កើតឡើងដោយសិទ្ធិ។

ឍ- **អចលនទ្រព្យ** រួមមាន ÷ ដី ឬវត្ថុដែលជាប់នៅលើដី ដូចជា អាគារ សំណង់ ដំណាំ ដើមឈើ ។ល។

ណ- **កម្មសិទ្ធិបញ្ញា** រួមមាន ÷
- ប្រកាសនីយបត្រតក្កកម្ម
- វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍
- គំនូរឧស្សាហកម្ម
- សិទ្ធិអ្នកនិពន្ធ និង
- ម៉ាក។

និយមន័យនៃកម្មសិទ្ធិបញ្ញាខាងលើ ត្រូវអនុលោមតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងច្បាប់ស្តីពីម៉ាក ពាណិជ្ជ-នាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

ត- **វិធានទូទៅនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែលនៅជាធរមាន** រួមមាន ÷ វិធាន គោលការណ៍ និយមន័យដែលបានចែងនៅក្នុងច្បាប់និងបទដ្ឋានគតិយុត្តនានា ដែលនៅជាធរមាននិងមិនមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ។

**មាត្រា ៤.- ភាពប្រតិបត្តិជាមួយច្បាប់នានា**

កិច្ចសន្យាពាណិជ្ជកម្មត្រូវចាត់ទុកជាច្បាប់របស់ភាគី បើសិនជាស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងវិធានទូទៅនានានៃច្បាប់ដែលនៅជាធរមានទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា។

នៅពេលដែលពុំមានខចែងនៅក្នុងច្បាប់នេះទេ វិធានទូទៅនានានៃក្រមរដ្ឋប្បវេណីនិងច្បាប់ផ្សេងៗទៀតដែលនៅជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាដែលទាក់ទងនឹងកាតព្វកិច្ចនិងកិច្ចសន្យាត្រូវអនុវត្តចំពោះគ្រប់កិច្ចសន្យាពាណិជ្ជកម្មទាំងអស់។

បទដ្ឋានគតិយុត្តនានាអាចត្រូវរៀបចំនិងអនុម័តដើម្បីផ្តល់ការណែនាំក្នុងការអនុវត្តន៍ប្រភេទកិច្ចសន្យាពិសេសនានាដែលមាននៅក្នុងច្បាប់នេះ។ ផ្ទុយមកវិញ ការខ្វះខាតបទដ្ឋានគតិយុត្តពិសេសទាំងនោះមិនអាចរារាំងក្នុងការអនុវត្តន៍បទប្បញ្ញត្តិនៅក្នុងច្បាប់នេះបានឡើយ។

## ជំពូកទី ២
## ការបង្កើត និងការអនុវត្តន៍កិច្ចសន្យាពាណិជ្ជកម្ម
### ផ្នែកទី ១
### ការបង្កើតកិច្ចសន្យាពាណិជ្ជកម្ម

**មាត្រា ៥._ សំណើ និង ស្វីការ**

កិច្ចសន្យាពាណិជ្ជកម្មត្រូវបានបង្កើតឡើងនៅពេលដែលសំណើនិងស្វីការត្រូវគ្នា។

បទប្បញ្ញត្តិនិងគោលការណ៍នៃក្រមរដ្ឋប្បវេណីដែលទាក់ទងនឹងការបង្កើតកិច្ចសន្យាត្រូវបានអនុវត្តចំពោះកិច្ចសន្យាពាណិជ្ជកម្មទាំងអស់ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងនៅក្នុងច្បាប់នេះ។

**មាត្រា ៦._ លក្ខខណ្ឌតម្រូវនានាសម្រាប់បង្កើតកិច្ចសន្យាពាណិជ្ជកម្ម**

កិច្ចសន្យាពាណិជ្ជកម្មអាចត្រូវបានបង្កើតឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ។

កិច្ចសន្យាពាណិជ្ជកម្មត្រូវសរសេរជាលាយលក្ខណ៍អក្សរ បើសិនជា ÷

- កិច្ចសន្យានោះជាកិច្ចសន្យាដែលត្រូវចុះហត្ថលេខាដោយភាគី ឬដែលស្ថិតនៅក្នុងការផ្លាស់ប្តូរលិខិតស្នាម
- កិច្ចសន្យានោះធ្វើឡើងដោយមធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលទទួលស្គាល់ដោយច្បាប់ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីកិច្ចសន្យា ឬ

- កិច្ចសន្យានោះជាពាក្យទាមទារ ឬពាក្យឆ្លើយតបរបស់គូភាគីលើកិច្ច-សន្យាដែលមានស្រាប់ ។

**មាត្រា ៧.- លិខិតយថាភូត**

ថ្វីបើមានបទប្បញ្ញត្តិនៃមាត្រា ៦ ក៏ដោយ ក្នុងករណីផ្ទេរកម្មសិទ្ធិលើអចលនទ្រព្យ កិច្ចសន្យាពាណិជ្ជកម្មមានសុពលភាពនៅពេលកិច្ចសន្យានោះត្រូវបានបញ្ជាក់ជាលិខិតយថាភូត។

លិខិតយថាភូតបង្កើតឱ្យកិច្ចសន្យាមានសុពលភាពនិងដើម្បីតតាំងទៅនឹងតតិយជន។

## ផ្នែកទី ២
## ការអនុវត្តន៍កិច្ចសន្យា និងការមិនអនុវត្តន៍កិច្ចសន្យា

**មាត្រា ៨.- ភាតព្វកិច្ចនៃកិច្ចសន្យា**

ភាគីនៃកិច្ចសន្យាពាណិជ្ជកម្មមួយត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របតាមខចែងនៃកិច្ចសន្យា និងតាមគោលការណ៍សុចរិត។

ការអនុវត្តន៍និងការមិនអនុវត្តន៍កិច្ចសន្យាពាណិជ្ជកម្ម ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនិងគោលការណ៍នានានៃក្រមរដ្ឋប្បវេណី លើកលែងតែមានបញ្ញត្តិនៅក្នុងច្បាប់នេះដែលចែងពីកិច្ចសន្យាពាណិជ្ជកម្មពិសេស។

**មាត្រា ៩.- នវកម្ម ឧបាទេសកម្ម និងអនុប្បទាន**

នវកម្ម ឧបាទេសកម្ម អនុប្បទានលើការកាត់បំណុល អនុប្បទានសិទ្ធិលើបំណុល និងអនុប្បទានឋានៈក្នុងកិច្ចសន្យាដែលទាក់ទងនឹងកិច្ចសន្យាពាណិជ្ជកម្ម ត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី លើកលែងតែមានបញ្ញត្តិនៅក្នុងច្បាប់នេះដែលចែងពីកិច្ចសន្យាពាណិជ្ជកម្មពិសេស។

**មាត្រា ១០.- ករណីប្រធានសក្តិ អាជ្ញាយុកាល និងការរលត់ភាតព្វកិច្ច**

ក- ភាគីនៃកិច្ចសន្យាពាណិជ្ជកម្ម មិនត្រូវទទួលខុសត្រូវចំពោះការខូចខាត ឬការខកខានផ្នែកណាមួយ ឬការពន្យាពេលអនុវត្តកិច្ចសន្យា ឬបំពេញតាមខចែងនៃកិច្ចសន្យាពាណិជ្ជកម្មដោយសារករណីប្រធានសក្តិដូចបានចែងនៅក្នុង មាត្រា ៣ ឡើយ។